**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Économiques

Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# ការគ្រប់គ្រងរដ្ឋបាលឃុំស្វាយទាប ស្រុកចំការលើ ខេត្តកំពង់ចាម

ស្រាវជ្រាវចាប់ពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ រហូតដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ លោក **ឆាត ម៉េងសៀង**

ណែនាំដោយ

លោកគ្រូ **ឈាន មុនា**


ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**

ជំនាន់ទី១៧ (អាហារូបករណ៍)

ឆ្នាំចូលសិក្សា ២០២០

ឆ្នាំសរសេរសារណា ២០២៤

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **ឆាត ម៉េងសៀង** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ផ្នែករដ្ឋបាលសាធារណៈ ឆ្នាំទី៤ ក្រុម P4B03 ជំនាន់ទី ១៧ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ឆ្នាំសិក្សា ២០២៣-២០២៤។

សូមក្រាបថ្វាយបង្គំដោយគោរពថ្លែងអំណរគុណ និងកតញ្ញូតាធម៌ ការដឹងគុណយ៉ាងជ្រាលជ្រៅជូនចំពោះ៖

លោកឪពុក អ្នកម្តាយ ទាំងពីរដែលលោកជាអ្នកមានគុណយ៉ាងធំធេងចំពោះកូនដែលមានតម្លៃពុំអាចកាត់ថ្លៃបានព្រោះលោកទាំងពីរបានផ្តល់កំណើត ចិញ្ចឹមបីបាច់ថែរក្សា អប់រំទូន្មានប្រៀនប្រដៅដាស់តឿន ក្រើនរំឭកស្មារតីកូនៗរាល់ថ្ងៃ ផ្តល់ការស្រឡាញ់ ការថ្នាក់ថ្នម ផ្តល់ភាពកក់ក្តៅ និងការរស់នៅប្រកបដោយសេចក្តីថ្លៃថ្នូរ ជាពិសេស ទំនុកបម្រុងការសិក្សាគ្រប់យ៉ាងតាំងពីមត្តេយ្យសិក្សារហូតដល់ឧត្តមសិក្សានេះ។

ឯកឧត្តមបណ្ឌិត **លុយ ចន្ណា** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច  សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោកគ្រូ អ្នកគ្រូ សាស្រ្តាចារ្យគ្រប់រូបដែលបានយកចិត្តទុកដាក់ដោយទំនួលខុសត្រូវខ្ពស់ចំពោះការសិក្សារបស់និស្សិតទាំងអស់ដោយពុំគិតពីបញ្ហាការលំបាកអ្វីឡើយ ផ្ទុយទៅវិញលោកតែងតែដាស់តឿនក្រើនរំលឹក អប់រំទូន្មានប្រៀនប្រដៅស្មារតីនិស្សិតគ្រប់រូបឱ្យខិតខំប្រឹងប្រែងយកចិត្តទុកដាក់សិក្សាស្វែងរកចំណេះវិជ្ជាមកដាក់ក្នុងខ្លួន និងពង្រឹងខ្លួនឯងធ្វើយ៉ាងណាឱ្យក្លាយទៅជាមនុស្សម្នាក់ដែលមានគុណធម៌ និងសមត្ថភាពពេញលេញដែលសង្គមត្រូវការ។

ជាពិសេស សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់លោកគ្រូ **ឈាន មុណា** ដែលបានចំណាយពេលដ៏មានតម្លៃដឹកនាំ និងសម្របសម្រួលដល់ដំណើរការ នៃការសរសេរសារណានេះតាំងពីការចាប់ផ្តើម រហូតដល់ទីបញ្ចប់សព្វគ្រប់ និងទទួលបានជោគជ័យ។

លោកមេឃុំ **តឺខ យ៉ាត** សមាជិកក្រុមប្រឹក្សាឃុំ និងស្មៀនឃុំ **លី ស៊ីដា** ដែលបានជួយសម្របសម្រួលក្នុងការផ្តល់ឯកសារ និងណែនាំពន្យល់ពីស្ថានភាពទូទៅជាក់ស្តែងនៃការគ្រប់គ្រងរដ្ឋបាលរបស់ឃុំ ស្វាយទាប។

ជាចុងក្រោយខ្ញុំបាទសូមបួងសួងវត្ថុស័ក្តិសិទ្ធិបានថែរក្សា លោកឪពុកអ្នកម្តាយ ឯកឧត្តមសាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច និងមិត្តនិស្សិតទាំងអស់គ្នាមានសុខភាពល្អ សំណាងល្អសម្រេចបានជោគជ័យគ្រប់ភារកិច្ច។

# អារម្ភកថា

ការសិក្សាស្រាវជ្រាវទៅលើប្រធានបទ «**ការគ្រប់គ្រងរដ្ឋបាល ឃុំស្វាយទាប ស្រុកចំការលើ ខេត្តកំពង់ចាម**» គឺជាការកកើតឡើងដោយភាពខិតខំប្រឹងប្រែងព្យាយាមរបស់ខ្ញុំបាទរហូតបានសម្រេចចេញជារូបរាងសារណានេះឡើង។

ជាការពិតណាស់ ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់មានសារៈសំខាន់ណាស់នៅក្នុងការចូលរួមចំណែកនៃការអភិវឌ្ឍសង្គមជាតិ ព្រោះបានលើកកម្ពស់ផ្នែក ផ្តល់សេវាសាធារណៈ បង្កើនសុខុមាលភាពប្រជាពលរដ្ឋ និងឆ្លើយតបទៅតាមតម្រូវការរបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាន ជាពិសេសធ្វើឱ្យរដ្ឋាភិបាលនិងប្រជាពលរដ្ឋកាន់តែមានភាពជិតស្និទ្ធនឹងគ្នាថែមទៀត មិនតែប៉ុណ្ណោះរដ្ឋាភិបាលបានយល់ច្បាស់ពីប្រជាពលរដ្ឋថាតើពួកគាត់ចង់បានអ្វី និងមិនចង់បានអ្វីដើម្បីងាយស្រួលដោះស្រាយបញ្ហាជូនពួកគាត់ទាន់ពេលវេលាផងដែរ។

វត្ថុបំណងនៃការសិក្សាស្រាវជ្រាវទៅលើប្រធានបទនេះ គឺធ្វើឡើងដើម្បីសិក្សាឈ្វេងយល់ពីរបៀបនៃការគ្រប់គ្រងដឹកនាំដំណើរការ និងការប្រព្រឹត្តទៅនៃរដ្ឋបាលឃុំស្វាយទាប ថាតើដំណើរការប្រព្រឹត្តទៅយ៉ាងដូចម្តេច? ក្រោយពីការទទួលបាននូវបទពិសោធន៍ នៃការសិក្សាស្រាវជ្រាវទៅលើប្រធានបទនេះរួចមកធ្វើឱ្យខ្ញុំបានយល់ដឹង និងកាន់តែស៊ីជម្រៅច្បាស់លាស់ជាងមុនពាក់ព័ន្ធទៅនឹងការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ជាលក្ខណៈជាក់ស្តែងតែម្តងដែលកន្លងមកនោះយើងធ្លាប់សិក្សាតែទ្រឹស្តីប៉ុណ្ណោះ។ សមិទ្ធផលមួយនេះអាចសម្រេចទៅបានដោយអាស្រ័យមានការសម្របសម្រួលជួយជ្រោមជ្រែងលើកស្ទួយពីសំណាក់សាស្ត្រាចារ្យដឹកនាំលោកគ្រូទទួលបន្ទុក មេឃុំ ស្មៀន មិត្តភក្តិរួមជំនាន់ ក្នុងការផ្តល់អនុសាសន៍ណែនាំចង្អុលបង្ហាញផ្លូវកែសម្រួលពាក្យពេចន៍រចនាបទអត្ថន័យខ្លឹមសារអក្ខរាវិរុទ្ធ ដែលបានធ្វើឱ្យអត្ថបទស្រាវជ្រាវមួយនេះសម្រេចបានជាលទ្ធផលដែលអាចទទួលយកបាន។ ទោះបីជាការខិតខំប្រឹងប្រែងព្យាយាមកែខៃយ៉ាងហ្មត់ចត់ច្បាស់លាស់សាចុះសាឡើងម្តងហើយម្តងទៀត យ៉ាងណាក៏ដោយក៏មិនគេចផុតពីការខុសឆ្គាំឆ្គងល្អៀងសេចក្តីអត្ថន័យអត្ថរសមិនសមទំនងចន្លោះប្រហោងគ្រប់ជ្រុងជ្រោយដោយមាននៅក្នុងទំព័រណាមួយជាក់ជាពុំខានឡើយ។ អាស្រ័យដូចនេះហើយ ខ្ញុំបាទរង់ចាំស្វាគមន៍ទទួលនូវរាល់ការរិះគន់ការផ្តល់មតិយោបល់ក្នុងអត្ថន័យស្ថាបនា និងការកែលម្អដោយក្តីសោមនស្សរីករាយពីសំណាក់សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ សិស្សនិស្សិត មិត្តអ្នកអាន និងអ្នកសិក្សាស្រាវជ្រាវ ជាពិសេសពីសំណាក់គណៈកម្មការត្រួតពិនិត្យ និងវាយតម្លៃដើម្បីធ្វើការកែលម្អឱ្យមានភាពល្អប្រសើរឡើង។

ជាចុងក្រោយ ខ្ញុំបាទសង្ឃឹម និងជឿជាក់ថាកិច្ចការសារណាស្រាវជ្រាវមួយនេះនឹងអាចក្លាយជាការចូលរួមចំណែកមួយនៃចំណេះដឹង ដល់មិត្តនិស្សិតទាំងឡាយជាពិសេស គឺជាអ្នកចង់សិក្សាស្រាវជ្រាវនូវប្រធានបទនេះ

បន្តទៀតឬប្រធានបទស្រដៀងគ្នានេះ ព្រមទាំងជាទិន្នន័យជំនួយស្មារតីបន្ថែមសម្រាប់ការជួយបង្ហាញផ្លូវសម្រាប់មិត្តនិស្សិត និងសិស្សប្អូនជំនាន់ក្រោយៗ។

# មាតិកា

ទំព័រ

## សេចក្តីផ្តើម


១. លំនាំបញ្ហានៃការស្រាវជ្រាវ ........ ១

២. ចំណោទបញ្ហានៃការស្រាវជ្រាវ ........ ២

៣. គោលបំណងនៃការសិក្សាស្រាវជ្រាវ ........ ២

៤. ទំហំ និងដែនកំណត់នៃការសិក្សាស្រាវជ្រាវ ........ ៣

៥. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ ........ ៣

៦. វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ ........ ៤

៧. រចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវ ........ ៦


## ជំពូកទី១

## រំលឹកទ្រឹស្តី និងគោលការណ៍សំខាន់ៗ


**១.១. ប្រព័ន្ធគ្រប់គ្រងបែបវិមជ្ឈការនៅកម្ពុជា** ........ ៨

១.១.១. និយមន័យគ្រប់គ្រង ........ ៩

១.១.២. និយមន័យវិមជ្ឈការ ........ ៩

១.១.៣. មុខងារវិមជ្ឈការ ........ ៩

១.១.៤. លក្ខណៈពិសេសនៃវិមជ្ឈការ ........ ៩

១.១.៥. ទម្រង់ផ្សេងៗនៃវិមជ្ឈការ ........ ១០

**១.២. ការរៀបចំរដ្ឋបាលឃុំ សង្កាត់** ........ ១២

១.២.១. ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ........ ១២

១.២.២. រចនាសម្ព័ន្ធ និងតួនាទីក្រុមប្រឹក្សាឃុំ សង្កាត់ ........ ១៤

១.២.៣. តួនាទី មុខងារ និងអំណាចរបស់រដ្ឋបាលឃុំ សង្កាត់ ........ ១៥

**១.៣. កិច្ចការរដ្ឋបាលឃុំ សង្កាត់** ........ ១៧

១.៣.១. លិខិតបទដ្ឋានគតិយុត្តឃុំ សង្កាត់ ............ ១៧

១.៣.២. លិខិតរដ្ឋបាលឃុំ សង្កាត់ ............ ១៧

១.៣.៣. ការគ្រប់គ្រងបុគ្គលិក ឯកសារ និងសម្ភារបរិក្ខាររបស់ឃុំ សង្កាត់ ............ ១៩

១.៣.៤. ការរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ ............ ១៩

## ជំពូកទី២

## ដំណើរការគ្រប់គ្រងរដ្ឋបាលរបស់ឃុំស្វាយទាប

**២.១. ស្ថានភាពទូទៅ** ............ ២១

២.១.១. ស្ថានភាពភូមិសាស្ត្រ និងប្រជាសាស្ត្រ ............ ២១

២.១.២. ស្ថានភាពសេដ្ឋកិច្ច ............ ២១

**២.២. ការរៀបចំ និងការប្រព្រឹត្តិទៅរបស់រដ្ឋបាលឃុំ ស្វាយទាប** ............ ២២

២.២.១. សមាសភាពក្រុមប្រឹក្សាឃុំ ............ ២២

២.២.២. គណៈកម្មាធិការនានារបស់ឃុំស្វាយទាប ............ ២៣

**២.៣. ការអភិវឌ្ឍឃុំស្វាយទាប** ............ ២៦

២.៣.១. ផែនការអភិវឌ្ឍន៍ឃុំ ............ ២៦

២.៣.២. កម្មវិធីវិនិយោគរបស់ឃុំ ............ ២៩

**២.៤. កម្មវិធីអភិវឌ្ឍន៍មូលដ្ឋានរយៈពេលប្រាំឆ្នាំ** ............ ៣២

២.៤.១. ក្របខណ្ឌវិនិយោគ ............ ៣២

២.៤.២. ក្របខណ្ឌផ្តល់សេវារដ្ឋបាល ............ ៣៣

២.៤.៣. ការដាក់ចេញលិខិតបទដ្ឋានគតិយុត្តនានា ............ ៣៤

**២.៥. ការគ្រប់គ្រងហិរញ្ញវត្ថុរបស់ឃុំ** ............ ៣៤

២.៥.១. ការរៀបចំ និងអនុម័តថវិការបស់ឃុំ ............ ៣៤

២.៥.២. ចំណូលនិង ចំណាយថវិការបស់ឃុំ ............ ៣៤

២.៥.៣. ប្រព័ន្ធទូទាត់ និងគណនេយ្យឃុំ សង្កាត់ ............ ៣៧

**២.៦. ការតាមដាន និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍** ........ ៣៧

២.៦.១. យន្តការតាមដាន និងវាយតម្លៃ ........ ៣៧

២.៦.២. វិធីសាស្ត្រ តាមដាន និងវាយតម្លៃ ........ ៣៨

២.៦.៣. សូចនាករតាមដាន និងវាយតម្លៃ ........ ៣៨

## ជំពូកទី៣

## សមិទ្ធផលការងារ បញ្ហាប្រឈម និងដំណោះស្រាយ

**៣.១. សមិទ្ធផលការងាររបស់ឃុំស្វាយទាប** ........ ៤១

៣.១.១. ស្ថិតិប្រជាពលរដ្ឋ ........ ៤១

៣.១.២. ស្ថិតិក្រុមប្រឹក្សា និង បុគ្គលិក ........ ៤១

៣.១.៣. ដីកា សេចក្តីសម្រេច និងលិខិតរដ្ឋបាល ........ ៤១

៣.១.៤. កិច្ចប្រជុំក្រុមប្រឹក្សា និងគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ ........ ៤២

៣.១.៥. គម្រោងវិនិយោគដែលមានការសន្យាគាំទ្រដោយថវិកាឃុំ សង្កាត់ ........ ៤២

**៣.២. ស្ថានភាពនៅឃុំស្វាយទាប និងបញ្ហាប្រឈម** ........ ៤៣

៣.២.១. ស្ថានភាពសេដ្ឋកិច្ច ........ ៤៣

៣.២.២. ស្ថានភាពសង្គមកិច្ច ........ ៤៤

៣.២.៣. ស្ថានភាពនៃការគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន និងការប្រែប្រួលអាកាសធាតុ ........ ៤៥

៣.២.៤. ស្ថានភាពនៃការគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ........ ៤៦

**៣.៣. ដំណោះស្រាយ** ........ ៤៧

៣.៣.១. ការពង្រឹងលើវិស័យសេដ្ឋកិច្ច ........ ៤៧

៣.៣.២. ការពង្រឹងលើវិស័យសង្គមកិច្ច ........ ៤៧

៣.៣.៣. ការពង្រឹងលើការគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន និងការប្រែប្រួលអាកាសធាតុ ........ ៤៨

៣.៣.៤. ការពង្រឹងការគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ........ ៤៩

**៣.៤. ចក្ខុវិស័យរបស់ឃុំ** ........ ៥០

៣.៤.១. គោលបំណងអភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ច ........................................................................ ៥០

៣.៤.២. គោលបំណងអភិវឌ្ឍន៍ផ្នែកសង្គមកិច្ច ........................................................................ ៥០

៣.៤.៣. គោលបំណងអភិវឌ្ឍន៍ផ្នែកគ្រប់គ្រងដីធ្លីធនធានធម្មជាតិ បរិស្ថានបម្រែបម្រួលអាកាសធាតុ និងគ្រោះមហន្តរាយ........................................................................ ៥១

៣.៤.៤. គោលបំណងអភិវឌ្ឍន៍ផ្នែករដ្ឋបាលសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ.............................. ៥១

**សេចក្តីសន្និដ្ឋាន**........................................................................ ៥២

**អនុសាសន៍**........................................................................ ៥៤

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ប្រទេសកម្ពុជា ជាប្រទេសមួយបានឆ្លងកាត់សង្គ្រាមស៊ីវិលច្រើនលើកច្រើនសារ។ ដោយសារតែឆ្លងកាត់សង្គ្រាមដែលបានអូសបន្លាយប្រមាណបីទៅបួនទសវត្សរ៍ មិនត្រឹមតែបង្អាក់ការអភិវឌ្ឍនៅកម្ពុជាលើគ្រប់វិស័យប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានបំផ្លិចបំផ្លាញយ៉ាងធ្ងន់ធ្ងរនូវរចនាសម្ព័ន្ធ ប្រព័ន្ធនយោបាយ រដ្ឋបាល សង្គម សេដ្ឋកិច្ច វប្បធម៌ ប្រពៃណី និងទំនៀមទម្លាប់ ជាពិសេសនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យពីឆ្នាំ១៩៧៥ ដល់ដើមឆ្នាំ ១៩៧៩។ បន្ទាប់ពីប្រទេសកម្ពុជាបានចុះកិច្ចព្រមព្រៀងទីក្រុងប៉ារីស នាថ្ងៃទី២៣ ខែតុលា ឆ្នាំ ១៩៩១ រួមទាំង ផ្អែកលើគំនិតផ្តួចផ្តើម ក្នុងការសម្របសម្រួល ខាងនយោបាយ ពីសំណាក់ប្រមុខរាជរដ្ឋាភិបាល បានរៀបចំក្របខណ្ឌគោលនយោបាយ សម្រាប់បោះឆ្នោតនៅថ្នាក់ឃុំ សង្កាត់ និងការធ្វើវិមជ្ឈការ និងវិសហមជ្ឈការ នៅរដ្ឋបាល ថ្នាក់ក្រោមជាតិ ដោយត្រូវបានរៀបចំឡើងនាឆ្នាំ១៩៩៩ និងបានឈានទៅដល់រៀបចំច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដែលត្រូវបានរដ្ឋសភាអនុម័តនាខែ មករា ឆ្នាំ២០០១។ នៅឆ្នាំ២០០២ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ទូទាំងប្រទេស ចំនួន ១,៦២១ ឃុំ សង្កាត់ ត្រូវបានរៀបចំឡើងតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យសេរី ពហុបក្ស។ ចាប់ពីពេលនោះមក កំណែទម្រង់វិមជ្ឈការ និងវិសហវិមជ្ឈការ ត្រូវធ្វើឡើងនៅថ្នាក់ឃុំ សង្កាត់។ សមិទ្ធផលនៃកំណែទម្រង់ដែលបានសម្រេចបាននៅថ្នាក់ឃុំ សង្កាត់ បានជម្រុញ និងលើកទឹកចិត្តដល់រាជរដ្ឋាភិបាល ដើម្បីពង្រីកដំណើរការកំណែទម្រង់នេះរហូតដល់ថ្នាក់ក្រោមជាតិតាមរយៈការដាក់ចេញក្របខណ្ឌ យុទ្ធសាស្ត្រ កំណែទម្រង់វិមជ្ឈការ និងវិសហវិមជ្ឈការឆ្នាំ២០០៥។ ផ្អែកលើតម្រូវការកំណែទម្រង់នេះ រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ត្រូវបានធ្វើវិសោធនកម្ម ដោយបានរៀបចំដែនដីរដ្ឋបាលនៃព្រះរាជាណាចក្រកម្ពុជាចែកជា រាជធានីភ្នំពេញ និងខេត្ត។ រាជធានីភ្នំពេញចែកជា ខណ្ឌ ខណ្ឌចែកជា សង្កាត់ ខេត្តចែកជា ក្រុង និងស្រុក ក្រុងចែកជា សង្កាត់ ស្រុកចែកជា ឃុំ និងសង្កាត់ ប៉ុន្តែសង្កាត់ក្នុងស្រុកមិនទាន់មានឡើយ។

ក្នុងនោះដែរ ផ្នែកមួយដ៏សំខាន់គឺ រាជរដ្ឋាភិបាលបានដាក់ចេញនូវនយោបាយវិមជ្ឈការថ្នាក់ឃុំ សង្កាត់ ដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងជាទិសដៅអាទិភាពធ្វើកំណែទម្រង់រដ្ឋបាលសាធារណៈ។ ជាក់ស្តែងនាពេលបច្ចុប្បន្ននេះ រដ្ឋបាលឃុំ សង្កាត់ជាមណ្ឌលរដ្ឋបាលអនុវត្តន៍នយោបាយវិមជ្ឈការផង និងវិសហវិមជ្ឈការផង។ ក្នុងដំណើរការនេះ រាជរដ្ឋាភិបាលចាត់ទុកដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហវិមជ្ឈការគឺជាមធ្យោបាយដ៏មានប្រសិទ្ធភាពក្នុងការបង្វិតសេវាសាធារណៈឱ្យកាន់តែជិតប្រជាពលរដ្ឋ។ ក្នុងន័យនេះ ទិសដៅនៃកំណែទម្រង់វិមជ្ឈការ និងវិសហវិមជ្ឈការ គឺដើម្បីពង្រឹង និងពង្រីកលទ្ធិប្រជាធិបតេយ្យនៅមូលដ្ឋាន និងជម្រុញ ការអភិវឌ្ឍនៅមូលដ្ឋាន និងការកាត់បន្ថយភាពក្រីក្រ។ ពិសេសនឹងទទួលបាននូវផលប្រយោជន៍បីធំៗ

រួមមានផ្តល់លទ្ធភាពប្រជាពលរដ្ឋក្នុងការចូលរួមធ្វើសេចក្តីសម្រេចចិត្ត ប្រសិទ្ធភាពខ្ពស់នៃការផ្តល់សេវាសាធារណៈ និងការកៀរគរធនធាននៅមូលដ្ឋាន។ នយោបាយនេះ បានផ្តល់លទ្ធភាពខ្ពស់ទៅដល់ប្រជាពលរដ្ឋក្នុងការស្នើ និងការទទួលយកសេវា ប្រកបដោយប្រសិទ្ធភាព សាមញ្ញ រហ័សទាន់ចិត្ត តម្លាភាព គណនេយ្យភាព និងប្រសិទ្ធផលខ្ពស់។ នៅក្នុងន័យនេះ សិទ្ធិអំណាចជាមូលដ្ឋានដែលបានទទួលយកដោយក្រុមតំណាងប្រជាពលរដ្ឋមូលដ្ឋាន (ក្រុមប្រឹក្សាឃុំ សង្កាត់) ជាអ្នកដឹកនាំគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ដែលធ្វើសកម្មភាពបម្រើផលប្រយោជន៍ជូនសាធារណៈ ក្នុងកិច្ចការអភិវឌ្ឍដែលប្រជាពលរដ្ឋបានបោះឆ្នោតជាសកលដោយផ្ទាល់ ដើម្បីឈរជាតំណាង ការពារសិទ្ធិសេរីភាព និងផលប្រយោជន៍របស់ខ្លួនក្នុងមូលដ្ឋានឃុំ សង្កាត់។

ដោយសារការសង្កេតឃើញនូវទិដ្ឋភាពនៃការអនុវត្តកំណែទម្រង់រដ្ឋបាលសាធារណៈ បែបនេះហើយដែលជាចំណាប់អារម្មណ៍របស់ខ្ញុំ បានឈានដល់ការសម្រេចជ្រើសរើសយកប្រធានបទ "ការគ្រប់គ្រង រដ្ឋបាលឃុំស្វាយទាប ស្រុកចំការលើ ខេត្តកំពង់ចាម តាមបែបវិមជ្ឈការ" យកមកធ្វើការសិក្សាស្រាវជ្រាវ និងចងក្រងជាឯកសារ ដើម្បីសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ផ្នែករដ្ឋបាលសាធារណៈ និងដើម្បីស្វែងយល់កាន់តែច្បាស់លាស់អំពីការអនុវត្តនយោបាយវិមជ្ឈការនៅថ្នាក់រដ្ឋបាលឃុំ សង្កាត់ ក្នុងព្រះរាជាណាចក្រកម្ពុជាផងដែរ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

យោងតាមលំនាំបញ្ហា បានជម្រុញឱ្យក្រុមប្រឹក្សាឃុំស្វាយទាប ស្រុកចំការលើ ខេត្តកំពង់ចាម មានការទទួលខុសត្រូវលើការគ្រប់គ្រងលើកិច្ចការរដ្ឋបាល ការផ្តល់សេវាសាធារណៈ ការពារផលប្រយោជន៍ លើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងដោះស្រាយរាល់បញ្ហាប្រឈមក្នុងដែនសមត្ថកិច្ច តាំងនាមជាអ្នកដឹកនាំ និងជាអ្នកតំណាងប្រជាពលរដ្ឋ។ ដូច្នេះ ចំណុចសំខាន់នៃការស្រាវជ្រាវលើប្រធានបទស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំស្វាយទាប ស្រុកចំការលើ ខេត្តកំពង់ចាម តាមបែបវិមជ្ឈការ ផ្តោតសំខាន់លើបញ្ហាដូចខាងក្រោម៖

- ហេតុអ្វីបានជារដ្ឋបាលថ្នាក់ឃុំ សង្កាត់ត្រូវគ្រប់គ្រងតាមបែបវិមជ្ឈការ?
- តើរដ្ឋបាលឃុំស្វាយទាប បានអនុវត្តន៍តាមនយោបាយវិមជ្ឈការនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនបានដល់កម្រិតណា? មានតម្លាភាព គណនេយ្យភាព គុណភាព និងប្រសិទ្ធភាពដែរឬទេ?
- តើអាជ្ញាធរនៃរដ្ឋបាលឃុំស្វាយទាបបានចាត់វិធានការដោះស្រាយចំពោះបញ្ហាប្រឈមបែបណាខ្លះ ដើម្បីដោះស្រាយ និងកែលម្អបញ្ហាទាំងនោះឱ្យបានល្អប្រសើរ?

## ៣. គោលបំណងនៃការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើប្រធានបទនេះ មានគោលបំណង៖

- ឱ្យសាធារណជន និងប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានបានយល់ដឹងអំពីការគ្រប់គ្រងតាមបែបវិមជ្ឈការ និងតួនាទី ភារកិច្ច របៀបការងាររបស់អាជ្ញាធររដ្ឋបាលឃុំស្វាយទាប
- ស្វែងយល់អំពីការអនុវត្តនយោបាយវិមជ្ឈការក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលឃុំស្វាយទាប
- សិក្សាអំពីដំណើរការគ្រប់គ្រង និងរចនាសម្ព័ន្ធរបស់រដ្ឋបាលឃុំស្វាយទាប
- ស្វែងយល់អំពីប្រព័ន្ធអភិបាលកិច្ចល្អ និងរបៀបបម្រើសេវាសាធារណៈរបស់រដ្ឋបាលឃុំស្វាយទាប
- ស្វែងយល់អំពីសមិទ្ធផលដែលសម្រេចបាន វិធីសាស្ត្រក្នុងការដោះស្រាយបញ្ហាប្រឈម រួមទាំងការកំណត់ទិសដៅអនាគតរបស់រដ្ឋបាលឃុំស្វាយទាប
- រួមចំណែកក្នុងការកែលម្អនូវចំណុចខ្វះខាតដែលពាក់ព័ន្ធក្នុងការគ្រប់គ្រងរដ្ឋបាលឃុំ និងការជម្រុញកិច្ចអភិវឌ្ឍន៍សង្គមប្រកបទៅដោយប្រសិទ្ធភាព តាមរយៈការផ្តល់ជាអនុសាសន៍ល្អៗ។

## ៤. ទំហំ និងដែនកំណត់នៃការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើប្រធានបទនេះ មានដែនកំណត់ និងវិសាលភាពគ្រប់ដណ្តប់តែលើសកម្មភាពនៃការអនុវត្តការងាររបស់រដ្ឋបាលឃុំ ស្វាយទាប ស្រុកចំការលើ ខេត្តកំពង់ចាម ក្នុងឆ្នាំ ២០១៧ ដល់ ឆ្នាំ ២០២២ តែប៉ុណ្ណោះ។ ដូច្នេះហើយ ចំពោះប្រធានបទស្តីពី ការគ្រប់គ្រងរដ្ឋបាលឃុំស្វាយទាប ស្រុកចំការលើ ខេត្តកំពង់ចាម តាមបែបវិមជ្ឈការនេះ ខ្ញុំបាទសូមធ្វើការបកស្រាយ ទៅលើចំណុចមួយចំនួនដែលទាក់ទងជាមួយនឹងដំណើរការគ្រប់គ្រងរដ្ឋបាល សមិទ្ធផលដែលសម្រេចបាន បញ្ហាប្រឈម ទិសដៅអនាគត និងដំណោះស្រាយលើបញ្ហាផ្សេងៗរបស់រដ្ឋបាលឃុំស្វាយទាបរបស់ខ្ញុំបាទ។

## ៥. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

ជាទូទៅ ការសិក្សាស្រាវជ្រាវតែងតែមានគុណតម្លៃដល់អ្នកសិក្សាគ្រប់រូបលើប្រធានបទ ឬជំនាញដែលខ្លួនជ្រើសរើសមានន័យថាសារៈប្រយោជន៍នៃការសិក្សាស្រាវជ្រាវ ដំបូងគឺឱ្យអ្នកស្រាវជ្រាវបានយល់ដឹង និងចងចាំបានច្បាស់ ហើយកាន់តែលម្អិតលើប្រធានបទ បន្ទាប់មកវាក៏បានផ្តល់សារៈប្រយោជន៍ជាច្រើនទៀត ដល់អ្នកអាន និងសាធារណជនទាំងឡាយ ដែលបានអាននូវស្នាដៃស្រាវជ្រាវនេះ។ សារៈប្រយោជន៍ទាំងនេះ រួមមានជាអាទិ៍គឺៈ

### ក. ប្រយោជន៍សម្រាប់ប្រជាពលរដ្ឋមូលដ្ឋាន និងរដ្ឋបាលឃុំសាមី

- បានយល់ដឹងអំពីការអនុវត្តការងារ និងផែនការអភិវឌ្ឍន៍របស់រដ្ឋបាលឃុំ
- យល់ដឹងអំពីរបៀបការរៀបចំការងាររដ្ឋបាលមួយចំនួន
- អាចបង្ហាញអំពីការពេញចិត្ត ឬមិនពេញចិត្តចំពោះការដឹកនាំ និងការអនុវត្តការងាររបស់រដ្ឋបាលឃុំ
- បង្កើនការយល់ដឹងទាក់ទងការបម្រើសេវាសាធារណៈរបស់រដ្ឋបាលឃុំ
- យល់ដឹងអំពីតួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សាឃុំកាន់តែច្បាស់បន្ថែមទៀត

- រដ្ឋបាលឃុំបានបង្ហាញពីសក្តានុពល កិច្ចអភិវឌ្ឍន៍ និងសមិទ្ធផលដែលសម្រេចបាន
- បង្ហាញពីការយកចិត្តទុកដាក់របស់រដ្ឋបាលឃុំចំពោះប្រជាពលរដ្ឋក្នុងមូលដ្ឋាន
- រដ្ឋបាលឃុំសាមីដែលចុះធ្វើការសិក្សាស្រាវជ្រាវ ទទួលបានឯកសារសម្រាប់តម្កល់ទុកក្នុងសាលាឃុំ

**ខ. ប្រយោជន៍សម្រាប់និស្សិត**

- បានប្រតិបត្តិតាមទិសដៅរបស់សាកលវិទ្យាល័យ ក្នុងការបញ្ចប់ថ្នាក់បរិញ្ញាបត្របានដោយជោគជ័យ
- បានស្វែងយល់កាន់តែច្បាស់អំពីយន្តការ នៃការអនុវត្តនីតិវិធីក្នុងការបំពេញតួនាទី និងភារកិច្ចក្នុងរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានស្វែងយល់កាន់តែច្បាស់ពីយុទ្ធសាស្ត្រ ក្របខណ្ឌច្បាប់ និងគោលនយោបាយ ក្នុងការបម្រើសេវាសាធារណៈ និងអភិបាលកិច្ចល្អជូនប្រជាពលរដ្ឋ
- បានរួមចំណែកដោយផ្ទាល់ ក្នុងការជួយជម្រុញ និងលើកកម្ពស់ការផ្តល់សេវាឱ្យកាន់តែមានប្រសិទ្ធភាព

**គ. ប្រយោជន៍សម្រាប់សាកលវិទ្យាល័យ សាធារណជន និងប្រទេសជាតិ**

- សាកលវិទ្យាល័យទទួលបានឯកសារសម្រាប់តម្កល់ទុក
- មិត្តអ្នកអាន និងសាធារណជនអាចស្វែងយល់បន្ថែមពីទ្រឹស្តីមួយចំនួនពាក់ព័ន្ធក្នុងកិច្ចការស្រាវជ្រាវ នេះ និងយល់កាន់តែច្បាស់អំពីការអនុវត្តការងាររដ្ឋបាលឃុំ
- ឃុំមានការរីកចម្រើនដោយកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋបាលឃុំ ធ្វើឱ្យប្រទេសមានការរីកចម្រើន
- ការផ្តល់សេវាសាធារណៈបានល្អ ធ្វើឱ្យការងាររលូនទៅមុខស្របតាមគោលនយោបាយជាតិ
- បានបង្ហាញពីការចូលរួមអភិវឌ្ឍន៍ប្រទេសជាតិតាមរយៈការចូលរួមដែលមិនអាចខ្វះបានពីមូលដ្ឋាន។

## ៦. វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ

**ក. ក្របខណ្ឌនៃការសិក្សាស្រាវជ្រាវ**

ការសិក្សាស្រាវជ្រាវនេះ បានកំណត់លើការសិក្សាស្រាវជ្រាវនៅក្នុងការគ្រប់គ្រងរដ្ឋបាលឃុំស្វាយទាប ស្រុកចំការលើ ខេត្តកំពង់ចាម តាមបែបវិមជ្ឈការ ក្នុងឆ្នាំ២០១៧-២០២២ តែប៉ុណ្ណោះ។

**ខ. វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ**

ក្នុងការសិក្សាស្រាវជ្រាវលើប្រធានបទនេះ ខ្ញុំបាទជ្រើសរើសយកវិធីសាស្ត្រស្រាវជ្រាវចំនួន០៣បែបគឺ (១) វិធីសាស្ត្របែបរុករក (២) វិធីសាស្ត្របែបពិពណ៌នា និង(៣) វិធីសាស្ត្របែបប្រៀបធៀបវិភាគ។ មូលហេតុដែលខ្ញុំបាទជ្រើសរើសយកប្រធានបទនេះ ដោយសារមុននឹងសរសេរសារណាមួយឱ្យបានល្អ ត្រូវការឯកសារដែលមានស្រាប់ ការសម្ភាសន៍ផ្ទាល់ជាមួយមន្ត្រីពាក់ព័ន្ធ ការស្រង់យកទិន្នន័យ និងព័ត៌មានដើម្បីប្រៀបធៀប រួចធ្វើការវិភាគលើទ្រឹស្តី អត្ថបទគតិយុត្ត ទស្សនទានគោលនយោបាយវិមជ្ឈការ និងទស្សនទាននានា។

ហេតុដូច្នេះ ជាហេតុនាំឱ្យឈាន នៅដល់ការសម្រេចជ្រើសរើសយកវិធីសាស្ត្រសិក្សាស្រាវជ្រាវខាងលើ សម្រាប់ធ្វើការបន្ថែមឱ្យគ្នាទៅវិញទៅមក។

**ខ.១. ការប្រមូលទិន្នន័យ**

ដើម្បីឱ្យការសិក្សាស្រាវជ្រាវកាន់តែច្បាស់ ទិន្នន័យដែលត្រូវមានពីរប្រភេទគឺ ទិន្នន័យចម្បង និង ទិន្នន័យបន្ទាប់បន្សំ។ ទិន្នន័យចម្បងក្នុងន័យនេះ ខ្ញុំបាទ បានមកពីការចូលរួមផ្ទាល់ក្នុងការសម្ភាសន៍ជាមួយ ស្មៀនរបស់រដ្ឋបាលឃុំស្វាយទាប ស្រុកចំការលើ ខេត្តកំពង់ចាម មេប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំស្វាយទាប សម្ភាសន៍ជាមួយប្រជាពលរដ្ឋរស់នៅក្នុងឃុំស្វាយទាប ចំណែកទិន្នន័យបន្ទាប់បន្សំ បានតាមរយៈការប្រមូលផ្តុំ ឯកសារផ្សេងៗ ការពិភាក្សាទាក់ទងច្បាប់ អនុក្រឹត្យ សេចក្តីសម្រេច ហើយនិងគោលនយោបាយនានាដែល រាជរដ្ឋាភិបាលបានដាក់ចេញ ជាពិសេសចំពោះច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។

ព្រឹត្តិបត្រស្រាវជ្រាវ សារព័ត៌មាន ឯកសារពាក់ព័ន្ធ មួយចំនួនទៀតពីប្រព័ន្ធអ៊ីនធឺណែត (Internet) ព្រមទាំងការប្រឹក្សាយោបល់ពីសាស្ត្រាចារ្យណែនាំផងដែរ។

**ខ.២. ការវិភាគទិន្នន័យ**

ការវិភាគនោះគឺអាស្រ័យលើប្រភេទទិន្នន័យ ចំពោះទិន្នន័យចម្បង ការវិភាគធ្វើឡើងដោយហ្មត់ចត់ ទៅតាម ការពិភាក្សា ការស្ទង់មតិជាច្រើនលើកច្រើនសារមានភាពជាក់លាក់ ច្បាស់លាស់ ដើម្បីបញ្ជាក់ថា ការ បកស្រាយ ធ្វើឡើងអនុលោមតាមខ្លឹមសារដើមទាំងស្រុង ពុំមានការបញ្ចេញបញ្ចូល ឬបំផ្លើសព័ត៌មានឡើយ។ ហេតុដូច្នេះហើយ រដ្ឋធម្មនុញ្ញ ច្បាប់ អនុក្រឹត្យ សេចក្តីសម្រេច បទបញ្ជា យុទ្ធសាស្ត្រ គោលនយោបាយ កម្មវិធី អភិវឌ្ឍន៍ និង របាយការណ៍របស់រដ្ឋបាលឃុំស្វាយទាប ត្រូវបានលើកឡើងមកពិចារណា ឆ្លុះបញ្ចាំងជាមួយ ការអនុវត្តជាក់ស្តែង និងប្រៀបធៀបទៅនឹងទិន្នន័យដែលទទួលបានពីការសម្ភាសន៍ផ្ទាល់ពីមន្ត្រីរបស់រដ្ឋបាលឃុំ ស្វាយទាប ស្របតាមលក្ខណៈសត្យានុម័ត។ ចំណែកឯទិន្នន័យបន្ទាប់បន្សំ ដែលបានដកស្រង់ចេញពីឯកសារ ផ្សេងៗ សៀវភៅរបស់សាស្ត្រាចារ្យល្បីៗ សៀវភៅគំរូរបស់រៀមច្បងផ្សេងៗ ក៏ដូចជាមតិពន្យល់បន្ថែមរបស់ សាស្ត្រាចារ្យណែនាំសារណា ការវិភាគចាត់ទុកទិន្នន័យនេះជា ព័ត៌មានពិចារណាបំពេញបន្ថែមឱ្យខ្លឹមសារគោល នៃសារណាស្រាវជ្រាវនេះ។

**ខ.៣. វិធីសាស្ត្រវិភាគ**

ទិន្នន័យដែលប្រមូលបាន និងធ្វើការវិភាគលក្ខណៈបែបប្រៀបធៀប វិភាគ ដោយរកចំណុចវិជ្ជមាន និង អវិជ្ជមានដែលពាក់ព័ន្ធនឹងការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។ ការប្រៀបធៀប វិភាគរកចំណុចវិជ្ជមាន និង អវិជ្ជមាន ត្រូវផ្សារភ្ជាប់ជាមួយនឹងទ្រឹស្តីច្បាប់ ដែលកំពុងចូលជាធរមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា គោលនយោបាយរាជរដ្ឋាភិបាល ទ្រឹស្តីវិទ្យាសាស្ត្រ និងយុទ្ធសាស្ត្ររបស់ឃុំ សង្កាត់ ក្នុងការអនុវត្តការងារជាក់

ស្តែង ដែលពាក់ព័ន្ធ។ ក្នុងករណីមានភាពអវិជ្ជមានកើតឡើង វិធីសាស្ត្រវិភាគទិន្នន័យនេះ ក៏ត្រូវបានវិភាគស្វែងរក ដំណោះស្រាយ សមស្រប ដើម្បីដោះស្រាយបញ្ហាផ្សេងៗ ដែលកើតមានក្នុងរដ្ឋបាលឃុំ សង្កាត់ និងមូលដ្ឋាន។

## ៧. រចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវ

រចនាសម្ព័ន្ធស្រាវជ្រាវក្រោមប្រធានបទ "ការគ្រប់គ្រងរដ្ឋបាលឃុំស្វាយទាប ស្រុកចំការលើ ខេត្តកំពង់ចាមតាមបែបវិមជ្ឈការ" នេះ ត្រូវបានចងក្រងចែកចេញតាមប្លង់ដូចខាងក្រោមនេះ៖

- សេចក្តីថ្លែងអំណរគុណ៖ បរិយាយអំពីការគោរព ការដឹងគុណ និងការថ្លែងអំណរគុណចំពោះលោកអ្នកមានគុណទាំងពីរ ឯកឧត្តមសាកលវិទ្យាធិការ លោកសាស្ត្រាចារ្យណែនាំ មេឃុំ ស្មៀន មេភូមិ មិត្តភក្តិរួមជំនាន់ទាំងអស់ដែលបានរួមចំណែកយ៉ាងធំធេង និងជួយជម្រុញឱ្យខ្ញុំបាទ បានបញ្ចប់ការសិក្សាដោយជោគជ័យ។
- អារម្ភកថា៖ បរិយាយអំពីអារម្មណ៍ និងការយល់ឃើញចំពោះប្រធានបទដែលខ្ញុំបាទបានខិតខំស្រាវជ្រាវ រួមទាំងគំនិតមួយចំនួនទៀត។
- សេចក្តីផ្តើម៖ និយាយអំពីបញ្ហាដែលបានបង្ហាញពីចំណុចដំបូងបំផុតនៃប្រធានបទ ការកកើតឡើងដំបូងនៃការរៀបចំក្របខណ្ឌគោលនយោបាយសម្រាប់បោះឆ្នោតនៅថ្នាក់ឃុំ សង្កាត់ ការធ្វើវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិឆ្នាំ១៩៩៩។ ចំណោទបញ្ហា ដែលប្រមូលផ្តុំទៅដោយចម្ងល់ជាច្រើន ដែលទាក់ទងទៅនឹងលិខិតបទដ្ឋានគតិយុត្ត ការគ្រប់គ្រងរដ្ឋបាល ការអនុវត្តការងារ ជាពិសេសលើសេវាសាធារណៈ និងការដោះស្រាយចំពោះបញ្ហាផ្សេងៗ គោលបំណងនៃការស្រាវជ្រាវរបស់អត្ថបទទាំងមូល ទំហំ និងដែនកំណត់នៃការស្រាវជ្រាវដែលខ្ញុំបាទបានកំណត់ត្រឹម ឆ្នាំ២០១៧-២០២២ ប៉ុណ្ណោះ។ ហើយចំពោះសារៈសំខាន់នៃការស្រាវជ្រាវ គឺពិតជាល្អសម្រាប់ប្រជាពលរដ្ឋ ឃុំ សង្កាត់ និស្សិតសាកលវិទ្យាល័យ សាធារណជន និងប្រទេសជាតិ ដោយរួមមាន វិធីសាស្ត្រស្រាវជ្រាវដែលបង្ហាញពីវិធីសាស្ត្រ ក្នុងការប្រមូលព័ត៌មានជាមួយរដ្ឋបាលឃុំ មេប៉ុស្តិ៍ ប្រជាពលរដ្ឋ និងប្រព័ន្ធផ្សព្វផ្សាយផ្សេងៗ។
- ជំពូកទី១ រំលឹកទ្រឹស្តី និងគោលការណ៍សំខាន់ៗ៖ ជំពូកនេះបង្ហាញអំពីទ្រឹស្តីមួយចំនួនដែលពាក់ព័ន្ធនឹងប្រធានបទ ដែលមានដូចជា ប្រព័ន្ធវិមជ្ឈការនៅកម្ពុជា ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ រចនាសម្ព័ន្ធនៃរដ្ឋបាលឃុំ សង្កាត់ តួនាទី មុខងារ និងការទទួលខុសត្រូវរបស់រដ្ឋបាលឃុំ សង្កាត់ និងកិច្ចការរដ្ឋបាលរបស់ឃុំ សង្កាត់។

- ជំពូកទី២ ដំណើរការគ្រប់គ្រងរដ្ឋបាលឃុំស្វាយទាប៖ ជំពូកនេះបង្ហាញអំពី ស្ថានភាពទូទៅ ការរៀបចំ និងការប្រព្រឹត្តិទៅរបស់រដ្ឋបាលឃុំស្វាយទាប ផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល រួមទាំងការគ្រប់គ្រងហិរញ្ញវត្ថុរបស់ឃុំស្វាយទាប។
- ជំពូកទី៣ សមិទ្ធផល បញ្ហាប្រឈម និងដំណោះស្រាយ៖ ជំពូកនេះ បានលើកឡើងអំពី សមិទ្ធផលដែលរដ្ឋបាល ឃុំស្វាយទាប សម្រេចបាន បញ្ហាប្រឈម និងដំណោះស្រាយ រួមទាំងទិសដៅអនាគតរបស់រដ្ឋបាលឃុំស្វាយទាប បានដាក់ចេញ។
- សេចក្តីសន្និដ្ឋាន និងអនុសាសន៍៖ ផ្នែកនេះជាចំណុចចុងក្រោយនៃសារណានេះ ដោយសង្ខេបនូវរាល់លទ្ធផលទាំងអស់ ដែលទទួលបានពីការស្រាវជ្រាវ និងបង្ហាញពីអនុសាសន៍មួយចំនួនផងដែរ។

# ជំពូកទី១

## រំលឹកទ្រឹស្តី និង

## គោលការណ៍សំខាន់ៗ

# ជំពូកទី១
# រំលឹកទ្រឹស្តី និងគោលការណ៍សំខាន់ៗ

## ១.១. ប្រព័ន្ធគ្រប់គ្រងបែបវិមជ្ឈការនៅកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា មានឆន្ទៈក្នុងការអនុវត្តគោលនយោបាយវិមជ្ឈការ។ ដោយសារវិមជ្ឈការ ជាធាតុផ្សំសំខាន់ក្នុងការអនុវត្តនៃកម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាល។ ប្រព័ន្ធវិមជ្ឈការនៅកម្ពុជាមានគោលបំណងចម្បងបីយ៉ាង៖

១. ជម្រុញឱ្យមានដំណើរការលទ្ធិប្រជាធិបតេយ្យនិងការគ្រប់គ្រងបែបអភិបាលកិច្ចល្អនៅមូលដ្ឋាន ជម្រុញគុណភាពក្នុងការរស់នៅឱ្យកាន់តែល្អប្រសើររបស់ប្រជាពលរដ្ឋ។

២. ផ្តល់ឱកាសកាន់តែច្រើនឡើងដល់ប្រជាពលរដ្ឋក្នុងការសម្រេចចិត្តរៀបចំការអភិវឌ្ឍនៅមូលដ្ឋាន។

៣. ធានាការអភិវឌ្ឍប្រកបដោយចីរភាព រួមទាំងការបែងចែកនូវសេវាកម្មជាមូលដ្ឋានផ្សេងៗ។

រាជរដ្ឋាភិបាលកម្ពុជាយល់ឃើញថា វិមជ្ឈការ គឺជាមធ្យោបាយដ៏មានប្រសិទ្ធភាពបំផុតក្នុងការផ្គត់ផ្គង់សេចក្តីត្រូវការរបស់ប្រជារាស្ត្រ លើកកម្ពស់គុណភាពនៃជីវិតរស់នៅរបស់ប្រជារាស្ត្រ និងលើកកម្ពស់ការផ្តល់នូវសេវាកម្មចាំបាច់ដល់មូលដ្ឋានសមស្របទៅតាមតម្រូវការជាក់ស្តែងរបស់ខ្លួន។

ប្រព័ន្ធគ្រប់គ្រងបែបវិមជ្ឈការ គឺជាប្រព័ន្ធគ្រប់គ្រងមួយដែលរដ្ឋបាលកណ្តាលធ្វើការផ្ទេរអំណាច និងការទទួលខុសត្រូវមួយចំនួនឱ្យទៅអាជ្ញាធរមូលដ្ឋានចាត់ចែងបម្រើផលប្រយោជន៍ផ្ទាល់របស់មូលដ្ឋាននោះ។

វិមជ្ឈការមានគោលបំណង លើកកម្ពស់ការគ្រប់គ្រងតាមបែបប្រជាធិបតេយ្យ អភិបាលកិច្ចល្អ លើកកម្ពស់គុណភាពជីវភាពរស់នៅ និងការផ្តល់ជូននូវឱកាសកាន់តែច្រើនឡើងដល់ប្រជាពលរដ្ឋ ដើម្បីសម្រេចលើជោគវាសនា អនាគតរបស់ខ្លួនដោយខ្លួនឯង និងថែមទាំងធានាឱ្យមានការអភិវឌ្ឍមួយ ប្រកបដោយនិរន្តរភាព ព្រមទាំងការផ្តល់សេវាកម្មនានាជាមូលដ្ឋាន។

អំណាចរដ្ឋបាលក្នុងប្រព័ន្ធនេះ មានការទទួលស្គាល់នៅក្នុងរដ្ឋធម្មនុញ្ញ ឬច្បាប់ដូចជាអំណាចរបស់ក្រុមប្រឹក្សា រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ សុទ្ធតែជាអំណាចស្វ័យសម្រេចក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ហើយមានការទទួលស្គាល់ដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ ចំណែកសិទ្ធិអំណាចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ក៏មានការទទួលស្គាល់ដោយច្បាប់ស្តីពីការគ្រប់គ្រងឃុំ សង្កាត់ដែរ។[1]

[1] សាកលវិទ្យាល័យវេស្ទើន, *ប្រព័ន្ធគ្រប់គ្រងរដ្ឋបាល*, ឆ្នាំសិក្សា ២០១០-២០១១, ទំព័រ ៥។

### ១.១.១. និយមន័យគ្រប់គ្រង

គ្រប់គ្រង (កិ) ពាក្យនេះបានមកពីពាក្យថាគ្រប់+គ្រង

ដូចនេះពាក្យថាគ្រប់គ្រងមានន័យថា គឺជាដំណើរការនៃការអនុវត្ត ចាត់ចែង និងគ្រប់គ្រងការងារដើម្បីសម្រេចនូវគោលដៅរបស់អង្គភាព ឬស្ថាប័នណាមួយ ដោយមានទំនួលខុសត្រូវខ្ពស់ដើម្បីឱ្យការងារនោះមានប្រសិទ្ធិភាពល្អប្រសើរឡើង។[2]

### ១.១.២. និយមន័យវិមជ្ឈការ

វិមជ្ឈការ ជាការដែលរាជរដ្ឋាភិបាលប្រគល់ឱ្យក្រុមប្រឹក្សានូវភាពជាម្ចាស់លើមុខងារ សិទ្ធិអំណាច និងធនធាន ការទទួលខុសត្រូវ និងធនធាន (បុគ្គលិក ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិ) ដើម្បីឆ្លើយតបសេចក្តីត្រូវការរបស់មូលដ្ឋាល។ ក្រុមប្រឹក្សាត្រូវមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋមូលដ្ឋានលើបញ្ហាទាំងនោះ។[3]

### ១.១.៣. មុខងារវិមជ្ឈការ

វិមជ្ឈការមានមុខងារពីរខុសគ្នាគឺ៖

- មុខងារនៃធម្មានុរូបកម្មនៃអំណាចរបស់រដ្ឋ ពោលគឺនៅពេលធ្វើវិមជ្ឈការអំណាចរបស់រដ្ឋបង្ហាញឱ្យឃើញសេរីភាពនៃរូបនីយកម្ម និងរបបមួយមានលក្ខណៈប្រជាធិបតេយ្យ។ ហេតុនេះនយោបាយក្នុងការធ្វើវិមជ្ឈការរបស់រដ្ឋ គឺនយោបាយមួយចំណេញខាងស្មារតី ឬចិត្តសាស្ត្រ និយាយរួមអំណាចកណ្តាលត្រូវបានគោរពដោយប្រជាជន។
- មុខងារនៃការបំពេញចិត្តទាមទារចេញមកពីកម្លាំងនយោបាយ និងសង្គមដែលមិនត្រួតពិនិត្យដោយឧបករណ៍រដ្ឋ និងជាកម្លាំងដែលទាមទារសេរីភាពជាសមូហភាពមួយផ្នែក។

### ១.១.៤. លក្ខណៈពិសេសនៃវិមជ្ឈការ

បច្ចេកទេសនៃការគ្រប់គ្រងតាមនយោបាយវិមជ្ឈការមានលក្ខណៈពិសេសចំនួនបីគឺ៖

- បុគ្គលភាពគតិយុត្ត សំដៅដល់ប្រព័ន្ធវិមជ្ឈការដែលមានបុគ្គលភាពគតិយុត្តខុសពីរដ្ឋ។ ប្រព័ន្ធនេះ ជាប្រធាននៃនីតិខុសពីរដ្ឋ។ ប្រព័ន្ធទាំងនេះមានសិទ្ធិ និងកាតព្វកិច្ចផ្ទាល់ខ្លួន មានគោលដៅសិទ្ធិអំណាច និងទ្រព្យសម្បត្តិផ្ទាល់ខ្លួន (ថវិកា សម្ភារៈ និងធនធានមនុស្ស)។

[2] វចនានុក្រមខ្មែរ *សម្តេចព្រះសង្ឃរាជជួន ណាត។*

[3] ក្រសួងមហាផ្ទៃ សាលាជាតិរដ្ឋបាលមូលដ្ឋាន, *ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់*, ឆ្នាំ២០២២, ទំព័រ ១។

- សមត្ថកិច្ចផ្ទាល់ខ្លួន សំដៅដល់ប្រព័ន្ធវិមជ្ឈការខុសពីសមត្ថកិច្ចរដ្ឋ។ ពោលគឺមានលក្ខណៈគតិយុត្តពីរគឺៈ (១) មិនមែនជាសមត្ថកិច្ចជាគោលការណ៍ទេ ប៉ុន្តែជាសមត្ថកិច្ចដែលកំណត់ដោយច្បាប់និង (២) នៅពេលរដ្ឋកំណត់ភារកិច្ចឱ្យហើយ រដ្ឋមិនអាចចូលធ្វើអន្តរាគមន៍បានឡើយ។
- ការប្រើប្រាស់សមត្ថកិច្ចស្វយ័ត មានន័យថា គ្មានឋានានុក្រមទេ រវាងរដ្ឋនិងប្រព័ន្ធវិមជ្ឈការ។ គ្មានអំណាចបង្គាប់បញ្ជាទេ។ ប៉ុន្តែ ការត្រួតពិនិត្យរបស់អំណាចកណ្តាលនៅតែមាននូវឡើយ ព្រោះរដ្ឋនៅតែជារដ្ឋទោលដដែល។ ហើយស្វ័យភាពមិនមែនឯករាជភាពទេ ការត្រួតពិនិត្យនេះ ត្រូវធ្វើឡើងតាមរបៀបពីរយ៉ាងដែលអង្គការត្រួតពិនិត្យអាចជាអង្គការ តុលាការ ឬអាជ្ញាធររដ្ឋបាល។

### ១.១.៥. ទម្រង់ផ្សេងៗនៃវិមជ្ឈការ

ទម្រង់ផ្សេងៗនៃវិមជ្ឈការ មានការកំណត់ជាច្រើនប្រភេទទៅតាមការបោះពុម្ពផ្សាយរបស់បុគ្គលល្បីៗ និងស្ថាប័នផ្សេងៗលើសកលលោក ក្នុងការគ្រប់គ្រងរដ្ឋបាលសាធារណៈ។ ចំណែកឯការបោះពុម្ពផ្សាយរបស់ United Nation Development Program (UNDP) ត្រូវបានបកស្រាយយ៉ាងសាមញ្ញនៃទ្រឹស្តីវិមជ្ឈការដោយផ្តោតលើការគ្រប់គ្រងវិស័យសាធារណៈ។ ទម្រង់វិមជ្ឈការនីមួយៗ ត្រូវឈរលើគោលការណ៍អភិបាលកិច្ចល្អ និងអាស្រ័យតាមករណីពិសេសរបស់ប្រទេសនីមួយៗ។

#### ១.១.៤.១. វិមជ្ឈការរដ្ឋបាល

វិមជ្ឈការរដ្ឋបាល ត្រូវបានគេចាត់ទុកថាមានការទាក់ទងនឹងការអភិវឌ្ឍ គឺជាទម្រង់ទូទៅ និងត្រូវបានគេទទួលស្គាល់ថាជាទម្រង់វិមជ្ឈការ។ វិមជ្ឈការរដ្ឋបាល មានន័យថាជាការផ្ទេរការទទួលខុសត្រូវក្នុងការរៀបចំផែនការ ការគ្រប់គ្រង និងបែងចែកប្រភពប្រាក់វិភាជន៍ពីរាជរដ្ឋាភិបាល និងភ្នាក់ងារផ្សេងៗរបស់ខ្លួនឱ្យមូលដ្ឋានអង្គភាព ភ្នាក់ងាររាជរដ្ឋាភិបាលមូលដ្ឋាន ស្ថិតក្រោមបង្គាប់របស់រាជរដ្ឋាភិបាល។

គេអាចហៅថាវិមជ្ឈការរដ្ឋបាលថា វិមជ្ឈការដែនដីហើយ វិមជ្ឈការដែនដីនេះ ត្រូវបានធ្វើឡើងទៅលើនីតិបុគ្គលសាធារណៈដែនដី ដែលមានដែនដីវិសាលភាពទូលំទូលាយ ដូចជាខេត្តដែលហៅថា វិមជ្ឈការផ្តល់ទៅឱ្យអភិបាលកិច្ច ឬសមូហភាពដែនដីវិញ ដែលមិនផ្តោតលើអភិបាលកិច្ច ឬសមូហភាពមូលដ្ឋានទេ។ នីតិបុគ្គលសាធារណៈ ដែនដីគឺមានក្រុមប្រឹក្សាដែលកើតចេញពីការបោះឆ្នោត ហើយក្រុមប្រឹក្សានេះ ជាអ្នកបោះឆ្នោតជ្រើសរើសតាំងអ្នកតំណាងរបស់ខ្លួន ដែលជាទូទៅមានតួអង្គទាំងពីរនេះ មានភារកិច្ច តួនាទីដោយឡែកពីគ្នា ក្រុមប្រឹក្សាមានតួនាទីជាអ្នកចេញសេចក្តីសម្រេចនានា ហើយមេឃុំចៅសង្កាត់ជាអ្នកអនុវត្តន៍សេចក្តីសម្រេចនោះ។

### ១.១.៤.២. វិមជ្ឈការបច្ចេកទេស

វិមជ្ឈការអំពីមុខងារដែលសិទ្ធិអំណាចមានពីរប្រភេទ គឺវិមជ្ឈការបច្ចេកទេស និងវិមជ្ឈការសេវាកម្ម តម្រូវការឱ្យមានការធ្វើវិមជ្ឈការនៅថ្នាក់រដ្ឋបាល។

វិមជ្ឈការបច្ចេកទេស ជារបៀបគ្រប់គ្រងសេវាកម្មសាធារណៈដោយមានការផ្ទេរការទទួលខុសត្រូវអំពីសិទ្ធិអំណាចដឹកនាំគ្រប់គ្រងបច្ចេកទេសណាមួយឱ្យទៅអាជ្ញាធរមួយគ្រប់គ្រងទៅតាមច្បាប់ ក្នុងគោលបំណងបម្រើផលប្រយោជន៍ទូទៅឱ្យមានប្រសិទ្ធភាព។

ក្នុងបរិបទប្រទេសកម្ពុជា វិមជ្ឈការបច្ចេកទេសបានរៀបចំរួចរាល់ហើយ ពោលគឺដែលបានប្រគល់សិទ្ធិឱ្យគ្រប់គ្រងតាមបែបវិមជ្ឈការបច្ចេកទេសមានដូចជា អាជ្ញាធរកំចាត់មីន អាជ្ញាធរអប្សរា អាជ្ញាធរអគ្គិសនី។ល។

### ១.១.៤.៣. វិមជ្ឈការហិរញ្ញវត្ថុ និងសារពើពន្ធ

ការស្ថាបនានូវប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព ការគ្រប់គ្រងហិរញ្ញវត្ថុ គឺជាស្នូលនៃកំណែទម្រង់វិមជ្ឈការ និងវិសមជ្ឈការនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីធ្វើការសម្រេចចិត្តប្រើប្រាស់ធនធានផ្សេងៗ។

ការទទួលខុសត្រូវលើសារពើពន្ធ គឺជាធាតុផ្សំយ៉ាងសំខាន់នៃវិមជ្ឈការ ព្រោះថារដ្ឋបាលមូលដ្ឋានត្រូវមានប្រាក់ចំណូលគ្រប់គ្រាន់ (ប្រមូលនៅមូលដ្ឋាន និងបញ្ជូនពីថ្នាក់ជាតិ) ដើម្បីធ្វើការសម្រេចក្នុងការចំណាយ។

វិមជ្ឈការសារពើពន្ធមានទម្រង់ជាច្រើន ដែលសរុបជារួមមកមានដូចខាងក្រោមៈ

- ហិរញ្ញប្បទានផ្ទាល់ខ្លួន ឬការទូទាត់ចំណាយយកតាមថ្លៃពីអ្នកប្រើប្រាស់
- ការពង្រីកចំណូលនៅមូលដ្ឋាន តាមរយៈការយកពន្ធអាករ និងការយកថ្លៃដោយប្រយោល
- ការផ្ទេរហិរញ្ញប្បទានដែលមានលក្ខណៈអន្តររដ្ឋបាល និង
- ការផ្តល់អំណាចក្នុងការខ្ចីហិរញ្ញប្បទាន ដើម្បីបម្រើផលប្រយោជន៍នៅមូលដ្ឋាន។

### ១.១.៤.៤. វិមជ្ឈការនយោបាយ និងប្រជាធិបតេយ្យ

វិមជ្ឈការនយោបាយ ជាការផ្តល់ឱ្យប្រជាពលរដ្ឋទាំងឡាយធ្វើការបោះឆ្នោតជ្រើសរើសតាំងជាតំណាងប្រជាពលរដ្ឋនូវការផ្តល់សិទ្ធិអំណាចច្រើនជាងមុន ក្នុងការធ្វើសេចក្តីសម្រេចចិត្តជាសាធារណៈ។ ទាំងនេះជាការគាំទ្រឱ្យមានការផ្តាច់ចេញនូវអំណាចប្រមូលផ្តុំនៅថ្នាក់កណ្តាល។ ធ្វើបែបនេះ ដើម្បីធានាបាននូវតុល្យភាព និងប្រព័ន្ធត្រួតពិនិត្យចម្រុះក្នុងការអនុវត្តនយោបាយ ដើម្បីមានការអភិវឌ្ឍ។

វិមជ្ឈការប្រជាធិបតេយ្យ មានការពាក់ព័ន្ធទៅនឹងការផ្ទេររដ្ឋបាលសារពើពន្ធ អំណាចនយោបាយគឺដើម្បីឱ្យវិមជ្ឈការទទួលបានជោគជ័យ។ វិមជ្ឈការប្រជាធិបតេយ្យ គឺជាការពង្រឹងយ៉ាងសំខាន់ក្នុងការសម្របសម្រួលដំណើរការរៀបចំ និងការអនុវត្តផែនការ នៅមូលដ្ឋានហើយក៏ជាវិធីសាស្ត្រមួយដើម្បីទំនាក់ទំនងជាមួយអង្គការសង្គមស៊ីវិល និងធ្វើឯកជនសកលភាវូបនីយកម្មផងដែរ។ វិមជ្ឈការប្រជាធិបតេយ្យ អាចជាដំណើរការដែល

ឈានទៅរកការបង្កើតឱ្យមានប្រជាធិបតេយ្យនៅមូលដ្ឋាន ដើម្បីឱ្យប្រជាពលរដ្ឋមានការចូលរួមនៅមូលដ្ឋានក្នុងកិច្ចការងារអភិវឌ្ឍន៍មូលដ្ឋាន និងសង្គមជាតិ។

## ១.២. ការរៀបចំរដ្ឋបាលឃុំ សង្កាត់

### ១.២.១. ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានបោះឆ្នោតជ្រើសរើសឡើងដោយប្រជាពលរដ្ឋនៃឃុំ សង្កាត់របស់ខ្លួនតាមការបោះឆ្នោតជាទូទៅ ជាសកល ដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ដោយស្មើភាព ដោយចំពោះដោយសម្ងាត់។ ការបោះឆ្នោតនេះ ត្រូវបានធ្វើឡើងរៀងរាល់៥ឆ្នាំម្តង ដោយការបោះឆ្នោតនៅគ្រប់ឃុំ សង្កាត់ទាំងអស់ត្រូវធ្វើឡើងនៅថ្ងៃអាទិត្យតែមួយថ្ងៃគត់។[4] ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវអនុវត្តន៍តាមប្រព័ន្ធសមាមាត្រដោយមានការបែងចែកអាសនៈតាមមធ្យមភាគខ្ពស់បំផុត ក្រោមសមត្ថកិច្ចរៀបចំចាត់ចែង និងគ្រប់គ្រងរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប)។ ដំណើរការប្រព្រឹត្តិទៅនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងត្រូវបានរៀបតាមលំដាប់លំដោយដូចតទៅ៖

#### ១.២.១.១. ការចុះឈ្មោះបេក្ខជនបោះឆ្នោត

បេក្ខជនដែលមានបំណងឈរឈ្មោះបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបញ្ជូនឈ្មោះរបស់ខ្លួនទៅក្នុងបញ្ជីបេក្ខជននៃគណបក្សនយោបាយ ដែលបានចុះបញ្ជីត្រឹមត្រូវតាមលក្ខខណ្ឌកំណត់ក្នុងច្បាប់ស្តីពីគណបក្សនយោបាយ។[5] បន្ទាប់មកគណបក្សនយោបាយត្រូវដាក់ពាក្យសុំចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតដែលចុះហត្ថលេខាដោយប្រធានគណបក្សនយោបាយ ឬតំណាងដែលទទួលការផ្ទេរសិទ្ធិទៅជាគណៈកម្មការឃុំរាយនាមបេក្ខជនដែលមានចំនួនយ៉ាងហោចណាស់ស្មើនិងពីរដងនៃចំនួនសមាជិករបស់ក្រុមប្រឹក្សាឃុំ សង្កាត់។ ប្រជាពលរដ្ឋទាំងពីរភេទដែលមានបំណងឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបំពេញនូវលក្ខខណ្ឌដូចខាងក្រោម៖

- មានសញ្ជាតិខ្មែរពីកំណើត
- ចេះអាន និងចេះសរសេរអក្សរខ្មែរ
- ចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតក្នុងឃុំ សង្កាត់ដែលខ្លួនមានបំណងឈរឈ្មោះ
- មានអាយុយ៉ាងតិច ២៥ឆ្នាំ គិតមកដល់ថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ  សង្កាត់។

---

[4] មាត្រា៣ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់, លេខ នស/រកម/០៦០០/០២០, ចុះនៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៦។

[5] មាត្រា៤៩ ថ្មី (មាត្រា ៩៨ ចាស់) នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់, លេខ នស/រកម/០៦០០/០២០, ចុះនៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៦។

❖ ចំណែកជនត្រូវហាមមិនឱ្យឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់រួមមាន៖

- សមាជិករដ្ឋសភា ព្រឹទ្ធសភា សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ សមាជិករាជរដ្ឋាភិបាល និងចៅក្រម
- ប្រតិភូរាជរដ្ឋាភិបាល អភិបាលឬ អភិបាលរងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- សមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បុគ្គលិកបម្រើការងារក្នុងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់
- មន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ កងយោធពលខេមរភូមិន្ទ ឬនគរបាលជាតិក្នុងគ្រប់មុខតំណែង
- ព្រះសង្ឃ ឬបព្វជិតសាសនា
- ស្មៀនឃុំ សង្កាត់។

**១.២.១.២. ការរៀបចំបញ្ជីឈ្មោះអ្នកបោះឆ្នោត**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវរៀបចំបញ្ជីឈ្មោះអ្នកបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ឱ្យបានយ៉ាងតិច ៩០ថ្ងៃ មុនថ្ងៃបោះឆ្នោត។[6] បន្ទាប់ពីរៀបចំបញ្ជីឈ្មោះអ្នកបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់រួច គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវកំណត់រយៈពេលនៃការត្រួតពិនិត្យបញ្ជីឈ្មោះអ្នកបោះឆ្នោតសម្រាប់ឃុំ សង្កាត់នីមួយៗមិនត្រូវតិចជាង ១៥ថ្ងៃ(ដប់ប្រាំថ្ងៃ)ឡើយ។

ដើម្បីមានសិទ្ធិចុះឈ្មោះក្នុងបញ្ជីបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ប្រជាពលរដ្ឋទាំងពីរភេទត្រូវបំពេញនូវលក្ខខណ្ឌដូចខាងក្រោម៖

- មានសញ្ជាតិខ្មែរ
- មានអាយុ ១៨ឆ្នាំ(ដប់ប្រាំបីឆ្នាំ)ឡើងគិតមកដល់ថ្ងៃបោះឆ្នោត
- មានទីលំនៅក្នុងឃុំ សង្កាត់ដែលសាមីខ្លួនត្រូវបោះឆ្នោត[7]
- ស្ថិតក្នុងស្ថានភាពជាប់ពន្ធនាគារ ឬជាជនវិកលចរិត ឬជាជនស្ថិតនៅក្រោមអាណាព្យាបាល ដែលមានលិខិតបញ្ជាក់ពីស្ថាប័នមានសមត្ថកិច្ច[8]។

[6] មាត្រា៤៣ នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់, លេខ នស/រកម/០៦០០/០២០, ចុះនៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៦។

[7] មាត្រា១៩ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់, លេខ នស/រកម/០៦០០/០២០, ចុះនៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៦។

[8] មាត្រា២០ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់, លេខ នស/រកម/០៦០០/០២០, ចុះនៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៦។

### ១.២.២. រចនាសម្ព័ន្ធ និងតួនាទីក្រុមប្រឹក្សាឃុំ សង្កាត់

រដ្ឋបាលឃុំ សង្កាត់នីមួយៗមានរចនាសម្ព័ន្ធជាក់លាក់របស់ខ្លួន ដោយផ្អែកតាមបទប្បញ្ញត្តិដែលមានចែងក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។

#### ១.២.២.១. ក្រុមប្រឹក្សាឃុំ សង្កាត់

ក្រុមប្រឹក្សាឃុំ សង្កាត់មានសមាជិក៥, ៧, ៩ ឬ១១នាក់ ផ្អែកតាមភូមិសាស្ត្រ និងចំនួនប្រជាជនដែលកំពុងរស់នៅក្នុងឃុំ សង្កាត់នោះ។ ចំនួនជាក់ស្តែងនៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវកំណត់ដោយអនុក្រឹត្យ។ ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗមានប្រធានមួយរូប ដែលហៅថាប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ហើយប្រធានក្រុមប្រឹក្សឃុំ សង្កាត់គឺជា មេឃុំឬចៅសង្កាត់។

ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់មានតួនាទី ភារកិច្ចដូចខាងក្រោមៈ

- ធ្វើជាអធិបតីក្នុងសម័យប្រជុំនានារបស់ក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន
- ធានាឱ្យមានកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់យ៉ាងតិចឱ្យបានមួយដងក្នុងមួយខែ
- ធានាឱ្យសម័យប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួនដំណើរទៅបានត្រឹមត្រូវទៅតាមវិធាន និងបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាឃុំ សង្កាត់
- រក្សារបៀបរៀបរយ និងសណ្តាប់ធ្នាប់ក្នុងពេលប្រជុំ។[9]

❖ សមាជិក ក្រុមប្រឹក្សាឃុំ សង្កាត់ (កបឃ.ស) មានតួនាទី ភារកិច្ចដូចខាងក្រោមៈ

- ធានាក្រុមប្រឹក្សាឃុំ សង្កាត់ប្រើប្រាស់អំណាចតួនាទី និងមុខងារដូចមានចែងក្នុងច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធ
- ចូលរួមក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់
- ធ្វើសហប្រតិបត្តិការជាមួយនឹងប្រជាពលរដ្ឋ។

#### ១.២.២.២. មេឃុំ ឬចៅសង្កាត់

ឃុំ សង្កាត់នីមួយៗមានមេឃុំ ឬចៅសង្កាត់មួយនាក់។ ស្ត្រី និងបុរសអាចត្រូវបានជ្រើសរើសឱ្យធ្វើជាមេឃុំ ឬចៅសង្កាត់។ មេឃុំ ឬចៅសង្កាត់មានតួនាទី ភារកិច្ចដូចខាងក្រោមៈ

- ធានាថា សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានអនុវត្តន៍
- រាយការណ៍អំពីការបំពេញការងារប្រចាំខែ ជូនទៅក្រុមប្រឹក្សាឃុំ សង្កាត់
- ផ្តល់យោបល់ និងជួយដល់ក្រុមប្រឹក្សាឃុំ សង្កាត់លើការងារកសាងផែនការ ការរៀបចំហិរញ្ញវត្ថុ និងការអនុវត្តអំណាច តួនាទី និងមុខងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់

[9] មាត្រា១៣ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់, លេខ នស/រកម/០៣០១/០៥, ចុះនៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១។

- ផ្ទេរសិទ្ធិដល់ជំទប់ ឬចៅសង្កាត់រងតាមឋានានុក្រមនៅពេលខ្លួនអវត្តមាន។
- បំពេញភារកិច្ចផ្សេងៗទៀតដែលក្រុមប្រឹក្សាឃុំ សង្កាត់ប្រគល់ឱ្យ[10]។

### ១.២.៣. តួនាទី មុខងារ និងអំណាចរបស់រដ្ឋបាលឃុំ សង្កាត់

មាត្រា៤១ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ចែងថា រដ្ឋបាលឃុំ សង្កាត់មានតួនាទីជម្រុញនិងគាំពារអភិបាលកិច្ចល្អ ដោយចាត់ចែងប្រើប្រាស់ធនធាននានា ដែលប្រកបដោយចីរភាពសម្រាប់បំពេញសេចក្តីត្រូវការមូលដ្ឋានក្នុងឃុំ សង្កាត់របស់ខ្លួន បម្រើផលប្រយោជន៍រួមរបស់ប្រជាពលរដ្ឋនិងគោរពផលប្រយោជន៍ជាតិស្របតាមគោលនយោបាយទូទៅរបស់រដ្ឋ។[11]

ផ្អែកតាមបទប្បញ្ញត្តិក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានផ្ទេរឱ្យនូវតួនាទីមុខងារ និងអំណាចមួយចំនួនសម្រាប់បម្រើផលប្រយោជន៍រួមរបស់ប្រជាពលរដ្ឋនិងអភិវឌ្ឍន៍នៅមូលដ្ឋានរបស់ខ្លួន។

#### ១.២.៣.១. អំណាចរបស់រដ្ឋបាលឃុំ សង្កាត់

រដ្ឋបាលឃុំ សង្កាត់ត្រូវដឹកនាំគ្រប់គ្រងដោយក្រុមប្រឹក្សាឃុំ សង្កាត់។ រដ្ឋបាលឃុំ សង្កាត់មានអំណាចបញ្ញត្តិ និងអំណាចប្រតិបត្តិ។[12]

**អំណាចបញ្ញត្តិរបស់ឃុំ សង្កាត់៖** ត្រូវធ្វើឡើងតាមរយៈដីកាឃុំសង្កាត់តាមការសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ហើយត្រូវចុះហត្ថលេខាដោយមេឃុំ ចៅសង្កាត់ សម្រាប់គ្រប់គ្រងកិច្ចការនានាក្នុងក្របខណ្ឌតួនាទីមុខងារនិងអំណាចរបស់ខ្លួនដែលច្បាប់ប្រគល់ឱ្យ។ ដីកាឃុំ សង្កាត់មានប្រសិទ្ធភាពអនុវត្តតែនៅក្នុងរង្វង់ដែនដីរបស់ខ្លួនប៉ុណ្ណោះ។ ដីកាឃុំ សង្កាត់មិនត្រូវផ្ទុយនិងសន្ធិសញ្ញា អនុសញ្ញាអន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ស្មារតីរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានពាក់ព័ន្ធឡើយ។ បើសិនដីកាណាមួយដែលផ្ទុយនឹងលិខិតបទដ្ឋានគតិយុត្តខាងលើនេះ ដីកានោះនឹងត្រូវបានចាត់ទុកជាមោឃៈដាច់ខាត។

#### ១.២.៣.២. តួនាទី និងមុខងាររបស់រដ្ឋបាលឃុំ សង្កាត់

រដ្ឋបាលឃុំ សង្កាត់មានតួនាទីពីរប្រភេទគឺ៖

១. តួនាទីបម្រើកិច្ចការមូលដ្ឋានសម្រាប់បម្រើផលប្រយោជន៍ឃុំ សង្កាត់ និងប្រជាពលរដ្ឋក្នុងឃុំ សង្កាត់របស់ខ្លួន។

[10] ក្រសួងមហាផ្ទៃ សាលាជាតិរដ្ឋបាលមូលដ្ឋាន, *ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់*, ឆ្នាំ២០២២, ទំព័រ ១១។

[11] មាត្រា៤១ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់, លេខ នស/រកម/០៣០១/០៥, ចុះនៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១។

[12] មាត្រា៤៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់, លេខ នស/រកម/០៣០១/០៥, ចុះនៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១។

២. តួនាទីជាភ្នាក់ងារតំណាងរដ្ឋ ក្រោមការចាត់តាំង ឬការប្រគល់អំណាចរបស់អាជ្ញាធររដ្ឋ។

ក្នុងតួនាទីបម្រើកិច្ចការមូលដ្ឋាន រដ្ឋបាលឃុំ សង្កាត់មានភារកិច្ចៈ

- ធានារក្សាសន្តិសុខសណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ
- រៀបចំចាត់ចែងសេវាសាធារណៈចាំបាច់និងមើលការខុសត្រូវឱ្យកិច្ចការទាំងនោះដំណើរការបានល្អ
- លើកទឹកចិត្តឱ្យមានការបង្កើនផាសុកភាព និងសុខុមាលភាពរបស់ប្រជាពលរដ្ឋ
- ជម្រុញកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកិច្ច និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ
- ការពារថែរក្សាបរិស្ថាន ធនធានធម្មជាតិ វប្បធម៌ បេតិកភណ្ឌជាតិ
- សម្របសម្រួលទស្សនៈរបស់ប្រជាពលរដ្ឋ ដើម្បីឱ្យមានការយោគយល់អធ្យាស្រ័យគ្នាទៅវិញទៅមក
- បំពេញកិច្ចការជាទូទៅ ដើម្បីឆ្លើយតបសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ។

ក្នុងតួនាទីជាភ្នាក់ងារតំណាងរដ្ឋៈ រដ្ឋបាលឃុំ សង្កាត់មានភារកិច្ចអនុវត្តទៅតាមច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានពាក់ព័ន្ធ។ ក្នុងករណីនេះ អាជ្ញាធររដ្ឋបាលអាចធ្វើប្រតិភូកម្មអំណាចដល់ឃុំ សង្កាត់ដោយភ្ជាប់ជាមួយនូវការបង្កើនសមត្ថភាព និងផ្តត់ផ្គង់មធ្យោបាយសម្ភារៈ ថវិកាសម្រាប់អនុវត្ត។ ឧទាហរណ៍ៈ ដូចជាការចុះបញ្ជីអត្រានុកូលដ្ឋាន និងការចុះឈ្មោះអ្នកបោះឆ្នោតនៅក្នុងឃុំ សង្កាត់ជាដើម។

### ១.២.៣.៣. ព្រំដែននៃអំណាច

រដ្ឋបាលឃុំ សង្កាត់អាចធ្វើសកម្មភាពបានតែនៅក្នុងក្របខណ្ឌអំណាច តួនាទីនិង មុខងារដែលច្បាប់បានប្រគល់ឱ្យប៉ុណ្ណោះ។ នេះមានន័យថា រដ្ឋបាលឃុំ សង្កាត់មិនអាចធ្វើសកម្មភាពណាមួយដែលផ្ទុយនឹងគោលការណ៍ នឹងបទប្បញ្ញត្តិដែលបានកំណត់នៅក្នុងរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋាននានាឡើយ។

រដ្ឋបាលឃុំ សង្កាត់គ្មានអំណាចសម្រេចលើវិស័យៈ

- ព្រៃឈើ
- ប្រៃសណីយ៍ និងទូរគមនាគមន៍
- ការពារជាតិ
- សន្តិសុខជាតិ
- រូបិយវត្ថុ
- នយោបាយក្រៅប្រទេស
- គោលនយោបាយសារពើពន្ធ និង
- វិស័យផ្សេងទៀតដែលមានចែងក្នុងច្បាប់ លិខិតបទដ្ឋានពាក់ព័ន្ធ។

## ១.៣. កិច្ចការរដ្ឋបាលឃុំ សង្កាត់

### ១.៣.១. លិខិតបទដ្ឋានគតិយុត្តឃុំ សង្កាត់

លិខិតបទដ្ឋានគតិយុត្តឃុំ សង្កាត់ គឺជាលិខិតដែលកំណត់នូវវិធានបទប្បញ្ញត្តិបទបញ្ជាឬគោលការណ៍នានាសម្រាប់ការគ្រប់គ្រងការតែងតាំងការបង្កើតឡើងនូវយន្តការ និងការណែនាំនិងការអនុវត្តកិច្ចការនានា។ លិខិតបទដ្ឋានគតិយុត្តរបស់រដ្ឋបាលឃុំ សង្កាត់រួមមានដីកា និងសេចក្តីសម្រេច។

ដីកាឃុំ សង្កាត់គឺជាលិខិតបទដ្ឋានគតិយុត្តដែលកំណត់នូវបទប្បញ្ញត្តិទាំងឡាយដែលរដ្ឋបាលឃុំ សង្កាត់បង្កើតឡើងសំដៅបម្រើផលប្រយោជន៍ប្រជាពលរដ្ឋទូទៅក្នុងឃុំ សង្កាត់ដោយស្មើភាពមិនរើសអើង និងសម្រាប់គ្រប់គ្រងកិច្ចការនានាក្នុងក្របខណ្ឌតួនាទី មុខងារ និងអំណាចអនុវត្តក្នុងរង្វង់ដែនដីរបស់ខ្លួន។

ដីកាឃុំ សង្កាត់មិនត្រូវផ្ទុយនឹងច្បាប់ នឹងលិខិតបទដ្ឋាននានារបស់រដ្ឋឡើយ។ ដីកាឃុំ សង្កាត់ត្រូវចុះហត្ថលេខាដោយមេឃុំ ចៅសង្កាត់តាមការសម្រេចរបស់អង្គប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ដែលមានចំនួនលើសពាក់កណ្តាលនៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូល។

សេចក្តីសម្រេចឃុំ សង្កាត់ គឺជាលិខិតបទដ្ឋានគតិយុត្តដែលបង្កើតឡើងដើម្បីអនុវត្តដីការបស់ខ្លួន ឬលិខិតបទដ្ឋាននានារបស់រដ្ឋ ឬចែងអំពីការបង្កើតការតែងតាំងការរៀបចំ ឬការគ្រប់គ្រងកិច្ចការនានាក្នុងក្របខណ្ឌតួនាទី មុខងារ និង អំណាចអនុវត្តន៍ក្នុងរង្វង់ដែនដីរបស់ខ្លួន។

សេចក្តីសម្រេចមានលក្ខណៈប្រហាក់ប្រហែលនឹងដីកាឃុំ សង្កាត់ដែរ ប៉ុន្តែមានឋានានុក្រមទាបជាងដីកា និងខ្ពស់ជាងលិខិតរដ្ឋបាលធម្មតាផ្សេងៗទៀតក្នុងឃុំ សង្កាត់។

សេចក្តីសម្រេចឃុំ សង្កាត់មិនត្រូវផ្ទុយនឹងច្បាប់ នឹងលិខិតបទដ្ឋាននានារបស់រដ្ឋ និងដីការបស់ខ្លួនឡើយ។ សេចក្តីសម្រេចឃុំ សង្កាត់ត្រូវចុះហត្ថលេខាដោយមេឃុំ ចៅសង្កាត់តាមការសម្រេចរបស់អង្គប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ដែលមានចំនួនលើសពីពាក់កណ្តាលនៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូល។

ក្នុងករណីប្រធានសក្តិ និងបន្ទាន់បំផុតដែលមិនអាចកោះប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់បាន មេឃុំ ចៅ សង្កាត់អាចចេញសេចក្តីសម្រេចដើម្បីដោះស្រាយស្ថានភាពបន្ទាន់នោះ។ សេចក្តីសម្រេចនេះនឹងត្រូវដាក់ជូនកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់នៅកិច្ចប្រជុំបន្ទាន់ដើម្បីពិនិត្យឡើងវិញអំពីភាពត្រឹមត្រូវតាមច្បាប់។

### ១.៣.២. លិខិតរដ្ឋបាលឃុំ សង្កាត់

លិខិតរដ្ឋបាលឃុំគឺជាលិខិតដែលរៀបចំការតាក់តែងឡើងជាលាយលក្ខណ៍អក្សរ សម្រាប់ជាមធ្យោបាយទំនាក់ទំនងផ្លូវការរដ្ឋបាលឃុំ សង្កាត់ជាមួយស្ថាប័ន អង្គភាព និងបុគ្គលនានាក្នុងគោលបំណងជូនព័ត៌មានណែនាំ អញ្ជើញ រាយការណ៍ ផ្សព្វផ្សាយ ឆ្លើយតប ឬចាត់តាំង បុគ្គលណាមួយឱ្យទៅបំពេញបេសកកម្ម។

លិខិតរដ្ឋបាលឃុំ សង្កាត់ដែលប្រើប្រាស់ជាផ្លូវការរួមមាន៖ (១) លិខិតស្នើ (២) សេចក្តីជូនដំណឹង ឬលិខិតជូនដំណឹង (៣) លិខិតអញ្ជើញ (៤) លិខិតបញ្ជាបេសកកម្ម (៥)របាយការណ៍ (៦) កំណត់ហេតុ (៧) លិខិតផ្ទេរសិទ្ធិ និង (៨) ដីកាអម។

លិខិតស្នើ គឺជាលិខិតដែលឃុំ សង្កាត់រៀបចំដើម្បីបង្ហាញពីគោលបំណង និងមូលហេតុនៃតម្រូវការជាក់លាក់ណាមួយរបស់ខ្លួនថ្លែងទៅកាន់រូបវន្តបុគ្គល នីតិបុគ្គលសាធារណៈឯកជន ក្រសួង ស្ថាប័នអង្គការឬសង្គមស៊ីវិលដែលមានសិទ្ធិអំណាចសម្រេច ឬដោះស្រាយចំពោះការស្នើសុំនោះ។

សេចក្តីជូនដំណឹង គឺជាលិខិតដែលឃុំ សង្កាត់រៀបចំឡើងដើម្បីធ្វើការទំនាក់ទំនងជាមួយបុគ្គលក្រសួង ស្ថាប័ន អង្គការសង្គមស៊ីវិលមានខ្លឹមសារជាការឆ្លើយបំភ្លឺចំពោះបញ្ហា ឬជាការឆ្លើយតបចំពោះសំណើ ឬជាការជូនដំណឹងឱ្យសាធារណជនបានដឹងនូវព័ត៌មានទាំងឡាយដែលឃុំ សង្កាត់ត្រូវការផ្សព្វផ្សាយ។

លិខិតអញ្ជើញ គឺជាលិខិតដែលឃុំ សង្កាត់រៀបចំឡើងដើម្បីធ្វើការអញ្ជើញបុគ្គល ឬតំណាងក្រសួង ស្ថាប័ន អង្គការសង្គមស៊ីវិលឱ្យចូលរួមក្នុងសកម្មភាពរបស់ឃុំ សង្កាត់ចំពោះកិច្ចការដែលពាក់ព័ន្ធទៅនឹងបុគ្គល ឬ អង្គភាពទាំងនោះដោយមានបញ្ជាក់ឈ្មោះ និងឋានៈ (អ្នកដែលត្រូវអញ្ជើញ) ទីកន្លែងប្រជុំ ឬប្រារព្ធពិធីកាលបរិច្ឆេទកម្មវិធី ឬរបៀបវារៈប្រជុំ និងអាចមានឯកសារដែលពាក់ព័ន្ធនឹងការប្រជុំភ្ជាប់ជាមួយ។

លិខិតបញ្ជាបេសកកម្ម គឺជាលិខិតដែលឃុំ សង្កាត់រៀបចំឡើងដើម្បីចាត់តាំងមន្ត្រីបុគ្គលិកឃុំ សង្កាត់ឱ្យចូលរួមក្នុងសកម្មភាពនានានៅក្រៅឃុំ សង្កាត់។ លិខិតនេះមានភ្ជាប់ជាមួយនូវទិដ្ឋាការធ្វើដំណើរ។

ទិដ្ឋាការធ្វើដំណើរ គឺជាលិខិតរដ្ឋបាលមួយប្រភេទសម្រាប់ឱ្យអ្នកដែលមានភារកិច្ចទៅបំពេញបេសកកម្មយកទៅចុះទិដ្ឋាការនូវទីកន្លែងកាលបរិច្ឆេទ មធ្យោបាយធ្វើដំណើរ និងហត្ថលេខារបស់អង្គភាពមានសមត្ថកិច្ចដែលបានអនុញ្ញាត និងអង្គភាពដែលបានទទួលដឹងឮអំពីការចេញដំណើរ និងការមកដល់ពីដំណាក់កាលមួយទៅដំណាក់កាលមួយទៀត។

នៅពេលត្រឡប់មកវិញត្រូវធ្វើរបាយការណ៍ ឬរាយការណ៍ជូនមេឃុំ ចៅសង្កាត់ ឬក្រុមប្រឹក្សាឃុំ សង្កាត់ឱ្យបានជ្រាបពីលទ្ធផល ឬបញ្ហាសំខាន់ៗដែលខ្លួនបានទៅចូលរួម។

របាយការណ៍ គឺជាសេចក្តីរាយការណ៍អំពីសកម្មភាពដំណើរការនិងលទ្ធផលការងាររបស់ឃុំ សង្កាត់ ឬបុគ្គលិកណាម្នាក់ ឬមួយក្រុមដែលរដ្ឋបាលឃុំ សង្កាត់បានបំពេញ ឬឃុំ សង្កាត់បានចាត់តាំងឱ្យទៅបំពេញដើម្បីរាយការណ៍ជូនថ្នាក់ដឹកនាំ និងអង្គភាពពាក់ព័ន្ធ។

ទម្រង់របាយការណ៍ប្រចាំខែ និងប្រចាំឆ្នាំរបស់រដ្ឋបាលឃុំ សង្កាត់ត្រូវអនុវត្តតាមសេចក្តីណែនាំលេខ០៣៥ស.ណ.ន ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ របស់ក្រសួងមហាផ្ទៃស្តីពីការរៀបចំរបាយការណ៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

ក្រៅពីទម្រង់របាយការណ៍ប្រចាំខែ និងទម្រង់របាយការណ៍ប្រចាំឆ្នាំខាងលើនេះឃុំ សង្កាត់អាចបង្កើត និងប្រើប្រាស់ទម្រង់របាយការណ៍ផ្សេងទៀតសម្រាប់ប្រើប្រាស់នៅក្នុងឃុំ សង្កាត់របស់ខ្លួន។

កំណត់ហេតុ គឺជាការកត់ត្រាស្រង់យកមតិយោបល់សេចក្តីសម្រេច និងឯកភាពលើសកម្មភាពដែលត្រូវអនុវត្តពីគ្រប់សមាជិកអង្គប្រជុំ និងការសម្រេចរបស់អង្គប្រជុំ ឬការកត់ត្រារាល់ហេតុការណ៍ណាមួយដែលបានកើតឡើងជាក់ស្តែងដើម្បីរក្សាទុកជាសក្ខីភាពនៅពេលមានតម្រូវការ។

លិខិតផ្ទេរសិទ្ធិគឺជាលិខិតរបស់មេឃុំ ចៅ សង្កាត់ប្រកាសជាលាយលក្ខណ៍អក្សរប្រគល់សិទ្ធិឱ្យជំទប់ចៅសង្កាត់តាមឋានានុក្រមដើម្បីធ្វើជាមេឃុំ ចៅ សង្កាត់ស្តីទីក្នុងអំឡុងពេលដែលមេឃុំ ចៅសង្កាត់អវត្តមាន។

ដីកាអម គឺជាឯកសាររដ្ឋបាលដែលឃុំ សង្កាត់រៀបចំឡើងផ្ញើអមភ្ជាប់ជាមួយសំណុំលិខិតដែលត្រូវផ្ញើចេញទៅឱ្យអង្គភាព ក្រសួង ស្ថាប័នណាមួយដោយមានការកត់ត្រាឈ្មោះ និងចំនួនលិខិត (ឯកសារ) លើដីកាអមនោះ។

ឃុំ សង្កាត់ប្រើដីកាអមដើម្បីជៀសវាងការបាត់បង់ឯកសារដែលរដ្ឋបាលឃុំ សង្កាត់ផ្ញើចេញ។

### ១.៣.៣. ការគ្រប់គ្រងបុគ្គលិក ឯកសារ និងសម្ភារបរិក្ខាររបស់ឃុំ សង្កាត់

គ្រប់សម្ភារបរិក្ខាររបស់ឃុំ សង្កាត់ត្រូវចុះបញ្ជីឱ្យបានត្រឹមត្រូវ។ បញ្ជីគ្រប់គ្រងសម្ភារបរិក្ខារនេះត្រូវរក្សាទុកឱ្យបានល្អប្រកបដោយសុវត្ថិភាព និងធ្វើបច្ចុប្បន្នជាប្រចាំ។

គ្រប់សម្ភារបរិក្ខាររបស់ឃុំ សង្កាត់ដែលកាត់ចេញពីបញ្ជីត្រូវឡើងស្របតាមនីតិវិធី និងត្រូវសម្រេចដោយអង្គប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់។

### ១.៣.៤. ការរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់

យោងតាមអនុក្រឹត្យលេខ២២អនក្រ.បក ស្តីពីការធ្វើវិមជ្ឈការអំណាច តួនាទី និងភារកិច្ចទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ត្រង់មាត្រា៩ ចែងថា៖[13]

- ឃុំ សង្កាត់គឺជាម្ចាស់លើរាល់លិខិត និងឯកសារដែលរៀបចំឡើងដោយក្រុមប្រឹក្សាឃុំ សង្កាត់ ឬក្នុងនាមក្រុមប្រឹក្សាឃុំ សង្កាត់ និងជាម្ចាស់សិទ្ធិលើតែមប្រ៍ ត្រាឃុំ សង្កាត់ព្រមទាំងឧបករណ៍ផ្សេងៗទៀតទាំងអស់របស់ឃុំ សង្កាត់។
- ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធានាទុកដាក់ឯកសារ លិខិតស្នាមតែមប្រ៍ ត្រាឱ្យបានត្រឹមត្រូវ និងគង់វង្ស។
- ការគ្រប់គ្រងឯកសារគឺជាការរៀបចំទុកដាក់ និងថែរក្សាឯកសារទាំងឡាយតាមប្រព័ន្ធមួយមានសណ្តាប់ធ្នាប់ និងសុវត្ថិភាព។

[13] មាត្រា៩ នៃអនុក្រឹត្យលេខ ២២ អនក្រ.បក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០២ ស្តីពីការធ្វើវិមជ្ឈការអំណាច តួនាទីនិងភារកិច្ចឱ្យក្រុមប្រឹក្សាឃុំ សង្កាត់។

ការគ្រប់គ្រងឯកសារនឹងផ្តល់នូវផលប្រយោជន៍មួយចំនួនដូចជា៖

- បង្កលក្ខណៈងាយស្រួលក្នុងការស្វែងរកព័ត៌មាន និងទិន្នន័យសម្រាប់ដឹកនាំនៅក្នុងការពិភាក្សា និងការធ្វើសេចក្តីសម្រេច
- ជួយបន្តនិរន្តរភាពព័ត៌មាននៅពេលមានអ្នកមកកាន់ការងារថ្មី និងអ្នកផ្លាស់ចេញ
- ផ្តល់នូវភស្តុតាងជាក់លាក់ពីកិច្ចការ ឬព្រឹត្តិការណ៍ដែលកើតរួចមកហើយ
- បង្កើនប្រសិទ្ធភាព និងសន្សំពេលវេលាដល់ការងាររដ្ឋបាលឃុំ សង្កាត់។
- ជាទូទៅឯកសារឃុំ សង្កាត់ មានពីរប្រភេទ គឺឯកសារផ្ទៃក្នុង និងឯកសារសាធារណៈ។
- ឯកសារផ្ទៃក្នុង គឺជាឯកសារទាំងឡាយណាដែលត្រូវបានប្រើប្រាស់ និងផ្សព្វផ្សាយសម្រាប់តែផ្ទៃក្នុងរបស់រដ្ឋបាលឃុំ សង្កាត់ និងបុគ្គលពាក់ព័ន្ធផ្ទាល់ប៉ុណ្ណោះ។

  ឧទាហរណ៍៖

- របាយការណ៍ស៊ើបអង្កេត
- ឯកសារអគ្រានុកូលដ្ឋាន។ល។
- ឯកសារសាធារណៈគឺជាឯកសារទាំងឡាយណាដែលត្រូវបានប្រើប្រាស់ និងផ្សព្វផ្សាយសម្រាប់សាធារណជនទូទៅ។

  ឧទាហរណ៍៖

- ផែនការអភិវឌ្ឍន៍
- កម្មវិធីវិនិយោគបីឆ្នាំរំកិល
- របាយការណ៍ហិរញ្ញវត្ថុ...។ល។

# ជំពូកទី២

## ដំណើរការគ្រប់គ្រងរដ្ឋបាលរបស់ឃុំស្វាយទាប

# ជំពូកទី ២
# ដំណើរការគ្រប់គ្រងរដ្ឋបាលរបស់ឃុំស្វាយទាប

## ២.១. ស្ថានភាពទូទៅ

### ២.១.១. ស្ថានភាពភូមិសាស្ត្រ និងប្រជាសាស្ត្រ

ឃុំស្វាយទាប ជាឃុំមួយក្នុងចំណោមឃុំទាំង០៨នៃស្រុកចំការលើ មានទីតាំងសាលាឃុំស្ថិតនៅក្នុងភូមិស្វាយទាប ជាប់សាលាបឋមសិក្សាស្វាយទាប មានព្រំប្រទល់ខាងកើតទល់នឹងឃុំស្ពឺ និងឃុំជយោ ខាងត្បូងទល់នឹងឃុំតាអុង ខាងលិចទល់នឹងឃុំច្រនាង ស្រុកបារាយណ៍ ខេត្តកំពង់ធំ ខាងជើងទល់នឹងឃុំល្វាលើ និងឃុំចំការអណ្ដូង ស្រុកចំការលើ ខេត្តកំពង់ចាម។ ឃុំ ស្វាយទាប ចែកចេញជា១៤ភូមិមានផ្ទៃដីសរុប៧.២០០ គីឡូម៉ែត្រការ៉េ។ ប្រជាពលរដ្ឋរស់នៅមាន៖ គ្រួសារមាន ៥,១០៥ គ្រួសារ ប្រជាជន ២៣,៨៧១ នាក់ ស្រី ១២,០១៤នាក់ ប្រជាជនអាយុពី១៨ឆ្នាំឡើងមានចំនួន១២,១៤៤នាក់ ដង់ស៊ីតេប្រជាជន ៣.៣១ នាក់ក្នុងមួយគីឡូម៉ែត្រការ៉េ។ ប្រជាជនប្រមាណ៦០.៤% ជាកសិកររស់នៅពឹងផ្អែកលើវិស័យកសិកម្ម ដែលជាវិស័យជាចម្បងក្នុងការគាំទ្រ ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក្នុងឃុំ។

ឃុំស្វាយទាបមានលក្ខណៈភូមិសាស្ត្រចែកចេញដូចជា៖ ១)មានវាលទំនាបជាតំបន់ដីស្រែ សម្រាប់បង្កបង្កើនផលនារដូវវស្សា មានចំនួន២,២១០ហិកតា។ ២)តំបន់ខ្ពង់រាប សម្រាប់ដាំដំណាំផ្សេងៗដូចជាពោត សណ្ដែកសៀង សណ្ដែកបាយ សណ្ដែកដី ល្ង ដំឡូងមី ដំឡូងជ្វា កៅស៊ូ ម្រេច ស្វាយចន្ទី ស្វាយ សាវម៉ាវ ស្រកានាគ និងក្រូចពោធិសាត់ មានចំនួន ២,៩៦៥ ហិកតា ឃុំមានប្រព័ន្ធផ្លូវគមនាគមន៍ខ្វាត់ខ្វែងទូទាំងឃុំពីភូមិមួយ ទៅភូមិមួយទៀត ផ្លូវទាំងនេះភាគច្រើនជាផ្លូវដីនិងផ្លូវក្រាលគ្រួសក្រហម មានប្រវែង ៩,០០០ គីឡូម៉ែត្រ។[14]

### ២.១.២. ស្ថានភាពសេដ្ឋកិច្ច

ឃុំស្វាយទាប ជាឃុំមួយដែលប្រជាពលរដ្ឋភាគច្រើនប្រកបរបរកសិកម្ម ធ្វើស្រែចំការ ឃុំមានផ្ទៃដីផលិតកម្ម កសិកម្មសរុប ៥,១៧៥ ហិកតា សម្រាប់ដាំដំណាំ និងធ្វើស្រែចំការក្នុងនោះឃុំមានផ្ទៃដីស្រែវស្សាចំនួន២,២១០ ហិកតា ដោយឡែកស្រែវស្សានៅតាមភូមិខ្លះ កសិករធ្វើស្រែបាន២ដងក្នុងមួយរដូវ គឺស្រែប្រពលវប្បកម្មបង្កើនរដូវ។ ចំពោះសកម្មភាពសំខាន់ៗក្នុងវិស័យកសិកម្មឃុំ មានសក្ដានុពលសំខាន់ៗដូចខាងក្រោម៖

[14] គណៈកម្មាធិការកសាងផែនការ និងថវិកាឃុំ, *សៀវភៅផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ ២០១៧-២០២២ ឃុំស្វាយទាប ស្រុកចំការលើ ខេត្តកំពង់ចាម*, អនុម័តនៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៨, ទំព័រទី១។

មានផ្ទៃផលិតកម្មកសិកម្ម មានកម្លាំងពលកម្ម មានគ្រឿងយន្តកសិកម្ម មានប្រភពទឹក មានប្រព័ន្ធធារាសាស្រ្តសម្រាប់ស្រោចស្រព មានហេដ្ឋារចនាសម្ព័ន្ធ គមនាគមន៍តភ្ជាប់ពីភូមិមួយទៅភូមិមួយទៀត។ ឃុំមានសិប្បកម្មខ្នាតតូច និងធំដូចជា៖ ម៉ាស៊ីនកិនស្រូវខ្នាតមធ្យមចំនួន១៧ទីតាំងសិប្បកម្មផលិតគ្រឿងសង្ហារិមពីឈើ០៣ទីតាំង សិប្បកម្មផលិតពីដែកអាលុយមីញ៉ូម ០៦ទីតាំង សិប្បកម្មផលិតទឹកសុទ្ធ ០៤ទីតាំង សិប្បកម្មកែច្នៃឬវេចខ្ចប់ផលនេសាទ ០៣ទីតាំង អាជីវកម្មលក់ដូរគ្រឿងទេស២២៥ទីតាំងក្នុងនោះលក់គ្រឿងបរិភោគ និងទំនិញប្រើប្រាស់ ៥៥ទីតាំង លក់ខោអាវ ស្បែកជើង គ្រឿងក្រអូប ៣០ទីតាំង លក់គ្រឿងអលង្ការ ០៨ទីតាំង លក់គ្រឿងអេឡិចត្រូនិច ០៧ទីតាំង លក់គ្រឿងសង្ហារិម (តុ ទូ កៅអី) ១០ទីតាំង លក់សម្ភារៈសំណង់ ០៩ទីតាំង សេវាកម្មខ្នាតតូច កាត់សក់ ម៉ាស្សារ ១៩ទីតាំង លក់បាយគុយទាវ ២១ ទីតាំង ភោជនីយដ្ឋាន ០១កន្លែង ជួសជុលឬលក់កង់ម៉ូតូ ២៧ទីតាំង ជួសជុលឬលក់គ្រឿងយន្តនិងឧបករណ៍កសិកម្ម ០៩កន្លែង ជួសជុលគ្រឿងអេឡិចត្រូនិច ១១ទីតាំង ឱសថស្ថាន ឱសថស្ថានរង ០៤ទីតាំង គ្លីនីច ០៦កន្លែង និងផ្ទះសំណាក់ ០៨កន្លែង។[15]

## ២.២. ការរៀបចំ និងការប្រព្រឹត្តិទៅរបស់រដ្ឋបាលឃុំ ស្វាយទាប

### ២.២.១. សមាសភាពក្រុមប្រឹក្សាឃុំ

យោងតាមប្រកាសរបស់ក្រសួងមហាផ្ទៃលេខ ៧៦០៥ ប្រក ចុះនៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការទទួលស្គាល់សមាសភាពប្រធានក្រុមប្រឹក្សា មេឃុំ ជំទប់ និងសមាជិកក្រុមប្រឹក្សាឃុំ នៃឃុំស្វាយទាប ស្រុកចំការលើ ខេត្តកំពង់ចាម។ ក្រុមប្រឹក្សាឃុំស្វាយទាប នៅក្នុងអាណត្តិទី៤នេះ មានសមាសភាពចំនួន១១នាក់ ស្រ្តី៣នាក់ ដូចមានរាយនាមខាងក្រោម៖

១. លោក **គឹង យ៉ាត** ជាប្រធានក្រុមប្រឹក្សាឃុំ
២. លោក គឹម ប៊ុនឡុង ជាសមាជិកក្រុមប្រឹក្សាឃុំ
៣. លោកស្រី ទេព ដាទី ជាសមាជិកក្រុមប្រឹក្សាឃុំ
៤. លោក ស្មាន់ ប៊ុនប៉ា ជាសមាជិកក្រុមប្រឹក្សាឃុំ
៥. លោកស្រី សយ ណាវឿន ជាសមាជិកក្រុមប្រឹក្សាឃុំ
៦. លោក លី សុខលាង ជាសមាជិកក្រុមប្រឹក្សាឃុំ
៧. លោក ស៊ិន វ៉ានី ជាសមាជិកក្រុមប្រឹក្សាឃុំ
៨. លោក តឹក ឡេង ជាសមាជិកក្រុមប្រឹក្សាឃុំ
៩. លោក ឃិន យ៉ុន ជាសមាជិកក្រុមប្រឹក្សាឃុំ

[15] គណៈកម្មាធិការកសាងផែនការ និងថវិកាឃុំ, *សៀវភៅផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ ២០១៧-២០២២ ឃុំស្វាយទាប ស្រុកចំការលើ ខេត្តកំពង់ចាម*, អនុម័តនៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៨, ទំព័រទី៥។

១០. លោក ងិន ចាន់ ជាសមាជិកក្រុមប្រឹក្សាឃុំ

១១. លោកស្រី ជិន ហ៊ាប ជាសមាជិកក្រុមប្រឹក្សាឃុំ។

យោងតាមប្រកាសដែលទទួលស្គាល់សមាសភាពជាមេឃុំ ជំទប់ទី១ និងជំទប់ទី២ នៃឃុំ ស្វាយទាប ស្រុកចំការលើ ខេត្តកំពង់ចាម ដូចមានរាយនាមខាងក្រោម៖

១. លោក **គឹម យ៉ាត** ជាមេឃុំ

២. លោក គឹម ប៊ុនឡុង ជំទប់ទី១

៣. លោកស្រី ទេព ដាទី ជំទប់ទី២។

### ២.២.២. គណៈកម្មាធិការនានារបស់ឃុំស្វាយទាប

**១. គណៈកម្មាធិការកសាងផែនការ និងថវិកាឃុំ**

គណៈកម្មាធិការនេះ មានតួនាទី និង ភារកិច្ចដូចខាងក្រោម ៖

- ទទួលខុសត្រូវជួយមេឃុំ ក្នុងការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ និង រៀបចំថវិកាប្រចាំឆ្នាំ របស់ឃុំ ។
- អនុវត្តនីតិវិធីកសាងផែនការអភិវឌ្ឍន៍ និង កម្មវិធីវិនិយោគឃុំ និង រៀបចំថវិកាប្រចាំឆ្នាំ របស់ឃុំ ។
- កៀរគរប្រភពធនធាន ហិរញ្ញវត្ថុពីក្នុងនិងខាងក្រៅ ដោយប្រើប្រាស់ឱ្យអស់លទ្ធភាពនូវសក្តានុពលរបស់ខ្លួន ដើម្បីអភិវឌ្ឍន៍ភូមិ ឃុំ ។
- ធនធានថវិកាដែលមាន ត្រូវដោះស្រាយបញ្ហាជាអាទិភាពនៅមូលដ្ឋាន ក្នុងកិច្ចបម្រើផលប្រយោជន៍របស់ប្រជាពលរដ្ឋក្នុងឃុំ ។
- ប្រមូលទុនចូលរួមចំណែក របស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន ។
- ជួយផ្សព្វផ្សាយផែនការអភិវឌ្ឍន៍ឃុំ និងកម្មវិធីវិនិយោគឃុំ ។

**២. គណៈកម្មការលទ្ធកម្ម**

គណៈកម្មការលទ្ធកម្មមានតួនាទី ភារកិច្ចដូចខាងក្រោម[16] ៖

- អនុវត្តកិច្ចដំណើរការនៃការដេញថ្លៃ ទៅតាមនីតិវិធីដែលបានកំណត់
- ពិនិត្យ និងវាយតម្លៃសំណើដេញថ្លៃ និងឯកសារពាក់ព័ន្ធដែលបានដាក់ដោយអ្នកដេញថ្លៃ
- ផ្តល់អនុសាសន៍ដល់មេឃុំ ចៅសង្កាត់អំពីអ្នកឈ្នះក្នុងការដេញថ្លៃ។

គណៈកម្មការលទ្ធកម្មមានរបៀបរបបការងារដូចខាងក្រោម ៖

[16] សេចក្តីសម្រេចស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការលទ្ធកម្មឃុំស្វាយទាបក្នុងប្រការ២និងប្រការ៣។

- ប្រធានគណៈកម្មការលទ្ធកម្ម ជាអ្នកកោះប្រជុំ និងជាអធិបតីនៃអង្គប្រជុំរបស់គណៈកម្មការលទ្ធកម្ម។
- កិច្ចប្រជុំរបស់គណៈកម្មការលទ្ធកម្មអាចប្រព្រឹត្តទៅបានលុះត្រាតែមានវត្តមានសមាជិកគណៈកម្មការលទ្ធកម្មទាំង០៣រូប។ ក្នុងករណីសមាជិកណាម្នាក់អវត្តមាន កិច្ចប្រជុំរបស់គណៈកម្មការលទ្ធកម្មត្រូវពន្យារពេល ដើម្បីឱ្យសមាជិកគណៈកម្មការលទ្ធកម្មទាំង០៣រូបបានចូលរួម។ មូលហេតុនៃការពន្យារពេលនេះ ត្រូវកត់ត្រានៅក្នុងកំណត់ហេតុ។ នៅពេលកាលបរិច្ឆេទថ្មីនៃការពន្យារពេលឈានមកដល់ កិច្ចប្រជុំរបស់ គណៈកម្មការលទ្ធកម្មអាចប្រព្រឹត្តទៅបាន លុះត្រាតែមានវត្តមានសមាជិកគណៈកម្មការលទ្ធកម្មយ៉ាងតិច ចំនួន០២រូប ដែលក្នុងនោះ០១រូប គឺជាប្រធានគណៈកម្មការលទ្ធកម្ម។
- សេចក្តីសម្រេចរបស់អង្គប្រជុំគណៈកម្មការលទ្ធកម្មអាចយកជាការបាន លុះត្រាតែមានសំឡេងអនុម័តលើសពីពាក់កណ្តាលនៃចំនួនសមាជិកគណៈកម្មការលទ្ធកម្មទាំងមូល។ ប្រសិនបើសំឡេងអនុម័តមានចំនួនស្មើគ្នា សំឡេងរបស់ប្រធានគណៈកម្មការលទ្ធកម្មមានឧត្តមានុភាព។
- ប្រធានគណៈកម្មការលទ្ធកម្មត្រូវបានអញ្ជើញមន្ត្រីគាំទ្របច្ចេកទេសនៅឯរាជធានី ខេត្តដែលអភិបាលរាជធានី ខេត្តបានចាត់តាំងឱ្យជួយគណៈកម្មការលទ្ធកម្មឃុំ សង្កាត់ ចូលរួមក្នុងកិច្ចប្រជុំគណៈកម្មការលទ្ធកម្ម។ មន្ត្រីគាំទ្របច្ចេកទេសរាជធានី ខេត្តអាចផ្តល់យោបល់ដល់គណៈកម្មការលទ្ធកម្ម ប៉ុន្តែពុំមានសិទ្ធិបោះឆ្នោតអនុម័តឡើយ។
- គ្រប់កិច្ចប្រជុំរបស់គណៈកម្មការលទ្ធកម្ម តម្រូវឱ្យមានកំណត់ហេតុដែលរៀបចំដោយលេខាធិការរបស់គណៈកម្មការលទ្ធកម្ម និងត្រូវចុះហត្ថលេខាដោយអធិបតីនៃអង្គប្រជុំ។

### ៣. គណៈកម្មាធិការកិច្ចការនារី និងកុមារ

គណៈកម្មាធិការនេះ មានតួនាទី និង ភារកិច្ចដូចខាងក្រោម ៖

- រៀបចំផែនការសកម្មភាព និង ថវិកាប្រចាំឆ្នាំ របស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារក្នុងឃុំ ហើយឃុំត្រូវជូនព័ត៌មានទាំងនោះទៅក្រុមប្រឹក្សាឃុំដើម្បីអនុម័ត ។
- ផ្តល់យោបល់ជូនក្រុមប្រឹក្សាឃុំ និង មេឃុំ ចំពោះការងារពាក់ព័ន្ធទៅនឹងកិច្ចការនារី និង កុមារក្នុងឃុំ ។

- អប់រំផ្សព្វផ្សាយដល់ប្រជាពលរដ្ឋឱ្យយល់ដឹងអំពីច្បាប់ គោលនយោបាយនានារបស់រដ្ឋ ដែលពាក់ព័ន្ធសិទ្ធិនារី និងកុមារ និងបំផុសចលនាសហគមន៍លើវិស័យ អប់រំសុខភាព កិច្ចការពារ និងការអភិវឌ្ឍ ព្រមទាំងជំរុញការចុះបញ្ជីអត្រានុកូលដ្ឋានជូនកុមារ និងទារក ។
- ទាក់ទងការគាំទ្រ ដើម្បីឱ្យនារីបានចូលរួមធ្វើសេចក្តីសម្រេចចិត្តលើការអភិវឌ្ឍក្នុងមូលដ្ឋាន និង ពង្រឹងតួនាទីស្ត្រីក្នុងសង្គម ។
- បង្កើន និង ពង្រឹងនូវការប្រាស្រ័យទាក់ទងកិច្ចសហការ និង ការសម្របសម្រួលរវាងក្រុមប្រឹក្សាឃុំ និង អ្នកផ្តល់សេវាកម្ម និង អ្នកភូមិ ដែលធ្វើសកម្មភាពជួយនារី និង កុមារនៅក្នុងឃុំ ។
- ជួយក្រុមប្រឹក្សាឃុំ ក្នុងការប្រមូលព័ត៌មាន វិភាគទិន្នន័យពាក់ព័ន្ធ និង បញ្ហាតម្រូវការរបស់នារី និង កុមារ ដើម្បីដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ និង កម្មវិធីវិនិយោគឃុំ ។
- ចូលរួមអនុវត្ត ត្រួតពិនិត្យតាមដាន និង វាយតម្លៃផែនការសកម្មភាពឃុំ ពាក់ព័ន្ធនឹងស្ថានភាពកិច្ចការនារី និងកុមារ ។
- តាមដានស្ថានភាពស្ត្រី និង កុមារក្នុងឃុំ និង ធ្វើរបាយការណ៍ទៀងទាត់ឱ្យទៅក្រុមប្រឹក្សាឃុំ ព្រមទាំងដាក់បញ្ចូលព័ត៌មានទាំងនោះ ក្នុងរបាយការណ៍ឃុំ ។

### ៤. គណៈកម្មការគ្រប់គ្រងគម្រោង

គណៈកម្មការគ្រប់គ្រងគម្រោងមានតួនាទី ភារកិច្ចដូចខាងក្រោម ៖

- ក្នុងការរៀបចំគម្រោង ៖
  - ពិនិត្យ និងអនុម័តផែនការសិក្សាគម្រោង
  - គ្រប់គ្រងចាត់ចែងដំណើរការសិក្សា និងរៀបចំគម្រោង
  - រៀបចំសំណើគម្រោងដោយមានជំនួយពីអ្នកជំនាញបច្ចេកទេស
  - ពិនិត្យ និងអនុម័តសំណើគម្រោង។
- ក្នុងការអនុវត្តគម្រោង ៖
  - គ្រប់គ្រងចាត់ចែងដំណើរការអនុវត្តគម្រោង
  - រៀបចំប្រជុំចាប់ផ្តើម និងបញ្ចប់នៃការអនុវត្តការងារ ឬការផ្គត់ផ្គង់ទំនិញ និងរៀបចំប្រជុំពិនិត្យ និងអនុម័តការទូទាត់គម្រោង
  - តាមដានត្រួតពិនិត្យការអនុវត្តគម្រោង

គណៈកម្មការគ្រប់គ្រងគម្រោងមានរបៀបរបបការងារដូចខាងក្រោម ៖

- ប្រធានគណៈកម្មការគ្រប់គ្រងគម្រោង ជាអ្នកកោះប្រជុំ និងជាអធិបតីនៃអង្គប្រជុំរបស់គណៈកម្មការគ្រប់គ្រងគម្រោង។ ក្នុងករណីប្រធានអវត្តមាន ត្រូវផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរទៅឱ្យអនុប្រធាន ជាប្រធានស្តីទី ហើយប្រធានស្តីទីជាអ្នកកោះប្រជុំ និងជាអធិបតីនៃអង្គប្រជុំ
- កិច្ចប្រជុំរបស់គណៈកម្មការគ្រប់គ្រងគម្រោងអាចប្រព្រឹត្តទៅបាន លុះត្រាតែមានវត្តមានសមាជិកលើសពីពាក់កណ្តាលនៃសមាជិកគណៈកម្មការទាំងមូល
- សេចក្តីសម្រេចរបស់អង្គប្រជុំគណៈកម្មការគ្រប់គ្រងគម្រោងអាចយកជាការបាន លុះត្រាតែមានសំឡេងអនុម័តលើសពីពាក់កណ្តាលនៃចំនួនសមាជិកគណៈកម្មការទាំងមូល។ ប្រសិនបើជាសំឡេងអនុម័តមានចំនួនស្មើគ្នា សំឡេងរបស់អធិបតីនៃអង្គប្រជុំមានឧត្តមានុភាព
- ប្រធានគណៈកម្មការគ្រប់គ្រងគម្រោងអាចអញ្ជើញបុគ្គលិកមកពីទីភ្នាក់ងារនានា ឬតំណាងអង្គការសហគមន៍មូលដ្ឋានដែលពាក់ព័ន្ធនឹងគម្រោង ដើម្បីចូលរួមកិច្ចប្រជុំគណៈកម្មការក្នុងនាមជាអ្នកសង្កេតការ
- គ្រប់កិច្ចប្រជុំរបស់គណៈកម្មការគ្រប់គ្រងគម្រោង ត្រូវមានកំណត់ហេតុដែលរៀបចំដោយលេខាធិការរបស់គណៈកម្មការ និងត្រូវចុះហត្ថលេខាដោយអធិបតីនៃអង្គប្រជុំ។

## ២.៣. ការអភិវឌ្ឍឃុំស្វាយទាប

### ២.៣.១. ផែនការអភិវឌ្ឍន៍ឃុំ

ផែនការអភិវឌ្ឍន៍ឃុំ គឺមានអាណត្តិ៥ឆ្នាំ ដូចគ្នាទៅនឹងអាណត្តិរបស់ក្រុមប្រឹក្សាដែរ។ ផែនការអភិវឌ្ឍន៍ឃុំដែលត្រូវបានប្រើប្រាស់សម្រាប់កំណត់អំពីបញ្ហាតម្រូវការ និងយុទ្ធសាស្ត្រនានាដើម្បីដោះស្រាយរាល់បញ្ហាទាំងនោះសំដៅឆ្លើយតបទៅនឹងបញ្ហាជាអាទិភាពរបស់ប្រជាពលរដ្ឋឱ្យមានប្រសិទ្ធភាព។

#### ២.៣.១.១. ការរៀបចំផែនការអភិវឌ្ឍន៍ឃុំ

ក្រុមប្រឹក្សាឃុំ សង្កាត់ជារដ្ឋបាលដែលនៅដាច់ឆ្ងាយពីរដ្ឋបាលកណ្តាល ប៉ុន្តែជារដ្ឋបាលដែលនៅកៀកកិតជិតជាប់ជាមួយនឹងប្រជាពលរដ្ឋជាងរដ្ឋបាលដទៃទៀត ហើយក៏បានដឹងច្បាស់ពីតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋក៏ដូចជាស្ថានភាពនៃមូលដ្ឋានរបស់ឃុំ សង្កាត់ផ្ទាល់ផងដែរ។ ដូច្នេះ ការអភិវឌ្ឍក្នុងមូលដ្ឋានរបស់ឃុំ សង្កាត់នីមួយៗត្រូវតែពឹងផ្អែកលើវិធានការ និងការរៀបចំគម្រោងនានារបស់ឃុំ សង្កាត់នីមួយៗស្របតាមលទ្ធភាពផ្ទាល់ខ្លួនរបស់ឃុំ សង្កាត់នោះ។

ការរៀបចំអនុម័តនិង អនុវត្តឃុំ សង្កាត់ គឺជាភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ហើយគោលបំណងនៃការបង្កើតផែនការអភិវឌ្ឍន៍នេះគឺដើម្បីកំណត់នូវទស្សនៈវិស័យកម្មវិធី និងកិច្ចអភិវឌ្ឍន៍ឃុំ សង្កាត់របស់ខ្លួន។

ថ្មីបើឃុំ សង្កាត់ ត្រូវបានកំណត់ឱ្យរៀបចំនូវផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ដោយខ្លួនឯង និងទៅតាមលទ្ធភាពនៃឃុំ សង្កាត់រៀងៗខ្លួនក៏ដោយតែផែនការអភិវឌ្ឍន៍នេះត្រូវស្របទៅនឹងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ចរបស់ជាតិផងដែរ។ ផែនការអភិវឌ្ឍន៍គឺពិតជាមានសារៈសំខាន់ណាស់ដែលក្រុមប្រឹក្សាឃុំ សង្កាត់ចាំបាច់ត្រូវតែរៀបចំ និងអនុម័តហើយធ្វើការកែសម្រួលនូវទិន្នន័យថ្មីៗដែលមានការប្រែប្រួលជារៀងរាល់ឆ្នាំនៅពេលស្ថិតិក្នុងអាណត្តិ ឬក្នុងឆ្នាំទី១ នៃអាណត្តិក្រុមប្រឹក្សាដែលទើបនឹងជាប់ឆ្នោត។ ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ត្រូវរៀបចំជាលាយលក្ខណ៍អក្សរដោយមានផែនទី ស្ថិតិ និងសំណុំឯកសារពាក់ព័ន្ធផ្សេងៗទៀតភ្ជាប់មកជាមួយផង។ ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ត្រូវកំណត់ផងដែរនូវវិធីសាស្ត្រ និងមធ្យោបាយនានាដើម្បីបង្កលទ្ធភាពឱ្យមានការចូលរួមពីប្រជាពលរដ្ឋក្នុង ឃុំ សង្កាត់របស់ខ្លួនក្នុងកិច្ចដំណើរនោះ។ ករណីដែលផែនការអភិវឌ្ឍន៍ ឃុំ សង្កាត់ណាមួយធ្វើឡើងមិនស្របតាមច្បាប់នោះទេ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃនឹងធ្វើការណែនាំឱ្យក្រុមប្រឹក្សា ឃុំ សង្កាត់កែតម្រូវឱ្យបានសមស្របក្នុងកំឡុងពេលយ៉ាងយូរ ៤៥ថ្ងៃ បន្ទាប់ពីថ្ងៃទទួលបានច្បាប់ចម្លងនៃផែនការនោះ។ ក្រុមប្រឹក្សា ឃុំ សង្កាត់ ត្រូវធ្វើការកែសម្រួលផែនការអភិវឌ្ឍន៍ឃុំ សង្កាត់របស់ខ្លួនឱ្យបានសមស្របតាមការណែនាំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

### ២.៣.១.២. វដ្តនៃផែនការអភិវឌ្ឍន៍ឃុំ សង្កាត់

វដ្តនៃផែនការអភិវឌ្ឍន៍ឃុំ មាន៥ ជំហាន គឺ៖

- សេចក្តីព្រាងក្របខណ្ឌអភិវឌ្ឍន៍ និងថវិកា
- កិច្ចប្រជុំពិគ្រោះយោបល់ស្តីពីការអភិវឌ្ឍឃុំ សង្កាត់
- សេចក្តីព្រាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់
- ការអនុម័តផែនការអភិវឌ្ឍន៍ឃុំ សង្កាត់
- និង ការវាយតម្លៃអំពីផែនការអភិវឌ្ឍន៍ឃុំ សង្កាត់[17]។

[17]គណៈកម្មាធិការជាតិដឹកនាំការងារកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ, សេចក្តីណែនាំ ស្តីពីការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់, *រៀបចំដោយក្រុមការងារអន្តរក្រសួង ខែកក្កដា ឆ្នាំ២០០៧, ទំព័រ១០។*




**ជំហានទី១៖** សេចក្តីព្រាងក្របខណ្ឌអភិវឌ្ឍន៍ និងថវិកា

គោលបំណងសំខាន់នៃជំហាននេះ គឺរៀបចំសេចក្តីព្រាងក្របខណ្ឌអភិវឌ្ឍ និងថវិកាឃុំ សង្កាត់ដើម្បីដាក់ជូនកិច្ចប្រជុំពិគ្រោះយោបល់ស្តីពីការអភិវឌ្ឍឃុំ សង្កាត់ផ្តល់យោបល់ និងអនុសាសន៍។ សេចក្តីព្រាងក្រប-ខណ្ឌនេះ រួមមាន សេចក្តីត្រូវការ គោលដៅ យុទ្ធសាស្ត្រ សកម្មភាពជាអាទិភាព ព្រមទាំងការប៉ាន់ស្មានលទ្ធភាពធនធាន (តម្រូវការធនធានសម្រាប់ចំណាយមូលធន និងចំណាយចរន្ត) សម្រាប់រយៈពេល៥ឆ្នាំខាងមុខ។

**ជំហានទី២៖** កិច្ចប្រជុំពិគ្រោះយោបល់ស្តីពីការអភិវឌ្ឍឃុំ សង្កាត់

គោលបំណងសំខាន់នៃជំហាននេះគឺ បង្ហាញអំពីសេចក្តីព្រាងក្របខណ្ឌអភិវឌ្ឍន៍ និងថវិការបស់ឃុំ សង្កាត់ដល់ប្រជាពលរដ្ឋក្នុងឃុំ សង្កាត់ និងអ្នកពាក់ព័ន្ធនានា ដើម្បីស្តាប់មតិយោបល់របស់ប្រជាពលរដ្ឋក្នុងឃុំ សង្កាត់ និងអ្នកពាក់ព័ន្ធនានា និងស្រង់មតិយោបល់របស់ពួកគេដើម្បីរៀបចំសេចក្តីព្រាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់( ហៅកាត់ថា ផ.អ.ឃ/ស)។

**ជំហានទី៣៖** សេចក្តីព្រាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់

គោលបំណងសំខាន់នៃជំហាននេះ គឺចងក្រងសេចក្តីព្រាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ដោយផ្អែកលើការបូកសរុបយោបល់ដែលបានមកពីកិច្ចប្រជុំពិគ្រោះយោបល់ស្តីពីការអភិវឌ្ឍឃុំ សង្កាត់ និងសេចក្តីព្រាងក្របខណ្ឌ

អភិវឌ្ឍន៍ និងថវិកាឃុំ សង្កាត់ ដើម្បីដាក់ជូនក្រុមប្រឹក្សាឃុំ សង្កាត់ពិនិត្យ ឯកភាព និងដាក់ជូនអភិបាលខេត្ត ក្រុង ពិនិត្យ និងផ្តល់យោបល់។

**ជំហានទី៤៖** ការអនុម័តផែនការអភិវឌ្ឍន៍ឃុំ សង្កាត់

គោលបំណងសំខាន់នៃជំហាននេះ គឺការពិនិត្យ កែសម្រួល អនុម័ត និងផ្សព្វផ្សាយផែនការអភិវឌ្ឍន៍ឃុំ សង្កាត់។

**ជំហានទី៥៖** ការវាយតម្លៃអំពីការអនុវត្តផែនការអភិវឌ្ឍន៍ឃុំ សង្កាត់

គោលបំណងសំខាន់នៃជំហាននេះ គឺការពិនិត្យ និងវាយតម្លៃលើប្រសិទ្ធភាពនៃការអនុវត្តផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងដកស្រង់បទពិសោធន៍នានា សម្រាប់ជាមូលដ្ឋានក្នុងការគ្រប់គ្រងការអនុវត្ត និងការរៀបចំផែនការពេលក្រោយ។

### ២.៣.២. កម្មវិធីវិនិយោគរបស់ឃុំ

ក្របខណ្ឌវិនិយោគ គឺជាផ្នែកមួយដ៏សំខាន់របស់កម្មវិធីវិនិយោគឃុំស្វាយទាប ស្រុកចំការលើ ខេត្តកំពង់ចាម។ ក្រុមប្រឹក្សាឃុំស្វាយទាប ដែលមានគណៈកម្មាធិការកសាងផែនការនិង ថវិកាឃុំ ជាជំនួយបានយកចិត្តទុកដាក់គិតគូរនិងរៀបចំអំពីគោលបំណងសំខាន់ៗ ដើម្បីធ្វើការអភិវឌ្ឍមូលដ្ឋាននាពេលខាងមុខ ដោយផ្អែកទៅលើផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ (២០១៧-២០២២) ជាឯកសារគោល និងជាត្រីវិស័យសម្រាប់ឱ្យក្រុមប្រឹក្សាឃុំអនុវត្តតាមរយៈការរៀបចំនិងការអនុវត្តកម្មវិធីវិនិយោគប្រចាំឆ្នាំនីមួយៗរបស់ឃុំ។ នៅពេលពិនិត្យលើបញ្ហា និងតម្រូវការជាមួយប្រជាពលរដ្ឋឡើងវិញការរៀបចំគម្រោងវិនិយោគប្រចាំឆ្នាំរបស់ឃុំ ត្រូវឆ្លងកាត់ការពិភាក្សាគ្នាឱ្យបានល្អិតល្អន់ដើម្បីជ្រើសរើស និងចាត់អាទិភាពគម្រោងសម្រាប់យកទៅអនុវត្តន៍ឱ្យចំគោលដៅតាមការជាក់ស្តែងនៅក្នុងមូលដ្ឋានផ្ទាល់ថា តើអ្វីដែលជាបញ្ហាប្រឈមហើយចាំបាច់ត្រូវធ្វើការដោះស្រាយជាមុនឱ្យស្របទៅនឹងប្រភពធនធានដែលឃុំមាន និងទុនពីខាងក្រៅដែលបានមកពីការជួយឧបត្ថម្ភពីសំណាក់មន្ទីរជំនាញអង្គការមិនមែនរដ្ឋាភិបាល សប្បុរសជន និងដៃគូអភិវឌ្ឍន៍នានា ដើម្បីជួយគាំទ្រដល់គម្រោងកម្មវិធីវិនិយោគនេះនៅពេលសមាហរណកម្មផែនការឃុំ និងគម្រោងខ្លះទៀតដើម្បីជួយនិងគាំទ្រនៅក្រោយពេលដែលសមាហរណកម្មផែនការផងដែរ។ ជាមួយគ្នានេះដែរ ឃុំត្រូវកោះប្រជុំពេញអង្គក្រុមប្រឹក្សា ដើម្បីសម្រេចជ្រើសរើសគម្រោងដែលនៅសេសសល់គ្មានការសន្យាគាំទ្រសម្រាប់ប្រើប្រាស់មូលនិធិឃុំ ទុនចូលរួមពីប្រជាពលរដ្ឋនិងថវិកាផ្សេងៗទៀតរបស់ឃុំ ដែលទទួលបានពីមជ្ឈដ្ឋានខាងក្រៅ ត្រូវបញ្ចូលក្នុងតារាងថវិកាវិនិយោគតាមប្រភពតារាងគម្រោង វិនិយោគដែលមានការសន្យាគាំទ្រនិងតារាងគម្រោងវិនិយោគដែលមិនទាន់មានការសន្យាគាំទ្រ។

### ២.៣.២.១. វដ្តនៃកម្មវិធីវិនិយោគ

វដ្តនៃកម្មវិធីវិនិយោគឃុំ មាន៥ជំហាន គឺទី(១) ការពិនិត្យបញ្ហា ឬតម្រូវការជាមួយប្រជាពលរដ្ឋឡើងវិញ ទី(២) ការរៀបចំគម្រោងថវិកាវិនិយោគឃុំ សង្កាត់ ទី(៣) សិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ ស្រុក ខណ្ឌ ទី(៤) ការអនុម័តកម្មវិធីវិនិយោគឃុំ សង្កាត់ និងទី(៥) ការតាមដានត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តកម្មវិធីវិនិយោគ ឃុំ សង្កាត់[18]។




**ជំហានទី១៖** ការពិនិត្យបញ្ហា ឬតម្រូវការជាមួយប្រជាពលរដ្ឋឡើងវិញ

គណៈកម្មាធិការកសាងផែនការ និងថវិកា ជួបប្រជុំនៅថ្នាក់ឃុំ ដើម្បីពិភាក្សាពិនិត្យបញ្ហាឬតម្រូវការ មូលហេតុនៃបញ្ហា និងដំណោះស្រាយឡើងវិញ ដោយធ្វើការឆ្លុះបញ្ចាំងជាមួយទិន្នន័យភូមិទិន្នន័យឃុំឯកសារព័ត៌មានស្ថានភាពឃុំ និងទិន្នន័យ ឬព័ត៌មានផ្សេងៗហើយកំណត់អំពីបញ្ហាមូលហេតុនៃបញ្ហា និងដំណោះស្រាយនានាសម្រាប់ពិភាក្សាជាមួយប្រជាពលរដ្ឋ។ បន្ទាប់ពីនោះគណៈកម្មាធិការធ្វើការរៀបចំប្រជុំនៅតាមភូមិដើម្បីពិភាក្សា និងធ្វើសុពលភាពទៅលើបញ្ហាមូលហេតុ និងដំណោះស្រាយទាំងឡាយដែលបានកំណត់នៅថ្នាក់ឃុំ

[18] គណៈកម្មាធិការជាតិដឹកនាំការងារកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ, *សេចក្តីណែនាំ ស្តីពីការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់*, រៀបចំដោយក្រុមការងារអន្តរក្រសួង ខែកក្កដា ឆ្នាំ២០០៧, ទំព័រទី ៣១។

ដើម្បីពិភាក្សាកំណត់បញ្ហាឬតម្រូវការ និងដំណោះស្រាយនានាបន្ថែម។ ក្រោយមកគណៈកម្មាធិការជួបប្រជុំម្តងទៀតនៅថ្នាក់ឃុំដើម្បីបូកសរុបបញ្ហាមូលហេតុនិង ដំណោះស្រាយដែលបានមកពីបណ្តាភូមិនានា។

**ជំហានទី២៖** ការរៀបចំគម្រោងថវិកាវិនិយោគឃុំ

គណៈកម្មាធិការកសាងផែនការ និងថវិកាធ្វើការឆ្លុះបញ្ចាំងលទ្ធផលនៃជំហានទី១ ជាមួយនឹងគម្រោងតាមបណ្តាឆ្នាំនីមួយៗនៃផែនការអភិវឌ្ឍន៍ឃុំដើម្បីកំណត់គម្រោងវិនិយោគប្រចាំឆ្នាំដែលត្រូវយកទៅបង្ហាញ និងកៀរគរធនធាននៅសិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ស្រុក ខណ្ឌ។

**ជំហានទី៣៖** សិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ស្រុក ខណ្ឌ

សិក្ខាសាលាសមាហរណកម្មផែនការនេះត្រូវបានរៀបចំឡើងដើម្បីផ្តល់ឱកាស ឱ្យមានការផ្សារភ្ជាប់កម្មវិធីវិនិយោគឃុំជាមួយនឹងផែនការរបស់មន្ទីរជំនាញអង្គការមិនមែនរដ្ឋាភិបាល សង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍នានា ហើយធ្វើការកៀរគរ និងសម្របសម្រួលធនធានពីប្រភពផ្សេងៗសម្រាប់គាំទ្រដល់គម្រោងវិនិយោគឃុំជាពិសេសជួយតម្រង់ទិសសកម្មភាពរបស់មូលដ្ឋានឃុំឱ្យស្របតាមគោលនយោបាយអភិវឌ្ឍន៍ជាតិ និងខេត្ត។

**ជំហានទី៤៖** ការអនុម័តកម្មវិធីវិនិយោគឃុំ

គណៈកម្មាធិការកសាងផែនការ និងថវិការៀបចំតារាងថវិកាវិនិយោគតាមប្រភពតារាងគម្រោងវិនិយោគដែលមានការសន្យាគាំទ្រ និងតារាងគម្រោងវិនិយោគដែលមិនទាន់មានការសន្យាគាំទ្រព្រមទាំងជ្រើសរើសគម្រោងដែលមិនទាន់មានការសន្យាគាំទ្រ សម្រាប់ប្រើប្រាស់មូលនិធិឃុំ។ ក្រោយពីប្រមូលមតិយោបល់ឯកសារកម្មវិធីវិនិយោគដែលអនុម័តរួចត្រូវប្រកាសផ្សព្វផ្សាយដាក់ឱ្យប្រើប្រាស់ជាផ្លូវការនិងបង្កភាពងាយស្រួលដល់អ្នកពាក់ព័ន្ធធ្វើការសិក្សាស្វែងយល់។

**ជំហានទី៥៖** ការតាមដានត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តកម្មវិធីវិនិយោគឃុំ

ជំហានចុងក្រោយគណៈកម្មាធិការ ត្រូវតាមដានត្រួតពិនិត្យការរីកចម្រើន និងប្រសិទ្ធភាពនៃការអនុវត្តគម្រោង ឬសកម្មភាពនានាដែលមាននៅក្នុងកម្មវិធីវិនិយោគឃុំ ដើម្បីធានាការអនុវត្តគម្រោងឬសកម្មភាពទាំងនោះឱ្យបានត្រឹមត្រូវនិង ទាន់ពេលវេលា។ មិនត្រឹមតែប៉ុណ្ណោះ គណៈកម្មាធិការត្រូវពិនិត្យ និងវាយតម្លៃលើប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីវិនិយោគឃុំ និងដកស្រង់បទពិសោធន៍នានាសម្រាប់ជាមូលដ្ឋានការគ្រប់គ្រងការអនុវត្ត និងការរៀបចំកម្មវិធីវិនិយោគឆ្នាំក្រោយបន្តទៀត។[19]

[19]គណៈកម្មាធិការជាតិដឹកនាំការងារកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ, *សេចក្តីណែនាំ ស្តីពីការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់*, រៀបចំដោយក្រុមការងារអន្តរក្រសួង ខែកក្កដា ឆ្នាំ២០០៧, ទំព័រ៤៨។

## ២.៤. កម្មវិធីអភិវឌ្ឍន៍មូលដ្ឋានរយៈពេលប្រាំឆ្នាំ

### ២.៤.១. ក្របខណ្ឌវិនិយោគ

ដើម្បីអនុវត្តផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ(២០១៧-២០២២) ប្រកបដោយប្រសិទ្ធភាព ក្រុមប្រឹក្សាឃុំស្វាយទាប និងខិតខំប្រឹងប្រែងអស់ពីស្មារតីកម្លាំងកាយចិត្តទទួលខុសត្រូវដើម្បីអភិវឌ្ឍន៍មូលដ្ឋានតាមតម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋ ដែលរដ្ឋបាលឃុំ និងដាក់ចេញនូវក្របខណ្ឌវិនិយោគដូចមានសេចក្តីខាងក្រោម៖

- ផ្នែកសេដ្ឋកិច្ចមានដូចតទៅ[20]៖
  - ជួសជុលកែលម្អ ស្ពានប្រឡាយអមផ្លូវលំ
  - ជួសជុល និងកែលម្អប្រព័ន្ធធារាសាស្ត្រ
  - រៀបចំវគ្គបណ្តុះបណ្តាលនិងផ្តល់បច្ចេកទេស
  - បង្កើនការផ្សព្វផ្សាយនិង បណ្តុះបណ្តាល
  - រៀបចំប្រព័ន្ធទឹកស្អាត និងមានការពិនិត្យជាតិអាសេនិច។
- ផ្នែកសង្គមកិច្ចមានដូចជា៖
  - ផ្សព្វផ្សាយដល់ឪពុកម្តាយឱ្យបញ្ជូនកូនចូលរៀន និងរៀបចំកិច្ចប្រជុំគណៈកម្មការទ្រទ្រង់សាលា និងផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រ
  - បង្កើនការផ្សព្វផ្សាយពីសេវាសុខភាពដល់ប្រជាពលរដ្ឋទូទាំងឃុំ
  - គាំទ្រកុមារកំព្រាក្រីក្រ និងអ្នកជំងឺអេដស៍ និង
  - ផ្សព្វផ្សាយពីការប្រើប្រាស់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះ។
- ផ្នែកគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន និងបម្រែបម្រួលអាកាសធាតុ
  - ជម្រុញឱ្យមានការគ្រប់គ្រងកាកសំណល់និងដាក់ផ្ទាំងប៉ាណូ
  - ផ្សព្វផ្សាយ ការថែទាំនិងអភិរក្សជម្រកត្រី និង
  - ផ្សព្វផ្សាយច្បាប់ភូមិបាល។
- ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់មាន៖
  - បង្កើនការផ្សព្វផ្សាយគោលនយោបាយភូមិឃុំមានសុវត្ថិភាព៩ចំណុច ពង្រឹងប្រជាការពារនិងបង្កើនប៉ុស្តិ៍យាម
  - បណ្តុះបណ្តាលអភិវឌ្ឍន៍សមត្ថភាពភូមិឃុំ

---

[20]គណៈកម្មាធិការកសាងផែនការ និងថវិកាឃុំ, *សៀវភៅផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ ២០១៧-២០២២ ឃុំស្វាយទាប ស្រុកចំការលើ ខេត្តកំពង់ចាម*, អនុម័តនៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៨, ទំព័រទី១៨-២០។

- ពង្រឹងការយកព័ត៌មានរៀបចំប័ណ្ណក្រីក្រ និង
- បណ្តុះបណ្តាលប្រមូលទិន្នន័យភូមិ ឃុំមានភាពល្អប្រសើរ។

### ២.៤.២. ក្របខណ្ឌផ្តល់សេវារដ្ឋបាល

សម្រាប់ប្រាំឆ្នាំខាងមុខនេះក្រុមប្រឹក្សាឃុំ និងខិតខំយកចិត្តទុកដាក់ផ្តល់សេវាសាធារណៈនានាជូនប្រជាពលរដ្ឋឱ្យបានល្អប្រសើរ ក្នុងនាមជាអាជ្ញាធរបម្រើ និងមានតួនាទីភារកិច្ចស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងក្នុងនាមជាតំណាងឱ្យក្រសួងស្ថាប័ននានារបស់រាជរដ្ឋាភិបាល។ ក្រុមប្រឹក្សាឃុំ សូមដាក់នូវផែនការនៃការផ្តល់សេវាសាធារណៈដូចខាងក្រោម៖

❖ ប្រភេទសេវារដ្ឋបាលមានដូចតទៅ[21]៖

- សំបុត្រកំណើត (ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃកើត)
- សំបុត្របញ្ជាក់កំណើត
- សេចក្តីចម្លងសំបុត្រកំណើត
- សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត
- ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍
- សំបុត្រអាពាហ៍ពិពាហ៍ (ពលរដ្ឋខ្មែរ ជាមួយពលរដ្ឋខ្មែរ)
- សំបុត្រអាពាហ៍ពិពាហ៍ (ជនបរទេស ជាមួយពលរដ្ឋខ្មែរ)
- សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍
- សំបុត្រមរណភាព (ក្នុងរយៈពេល១៥ថ្ងៃ)
- សេចក្តីចម្លងសំបុត្រមរណភាព
- លិខិតបញ្ជាក់ភាពនៅលីវ មេម៉ាយ ឬពោះម៉ាយ
- លិខិតបញ្ជាក់ទីលំនៅ
- លិខិតបញ្ជាក់លើកិច្ចសន្យាខ្ចីប្រាក់
- លិខិតបញ្ជាក់ពីប្រវត្តិដីធ្លី
- លិខិតបញ្ជាក់កិរិយាមាយាទ
- លិខិតបញ្ជាក់ប្រវត្តិរូបសង្ខេប
- លិខិតបញ្ជាក់ទិញលក់សត្វពាហនៈ(គិតក្នុង០១ក្បាល)

[21] គណៈកម្មាធិការកសាងផែនការ និងថវិកាឃុំ, *សៀវភៅផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ ២០១៧-២០២២ ឃុំស្វាយទាប ស្រុកចំការលើ ខេត្តកំពង់ចាម*, អនុម័តនៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៨, ទំព័រទី២១។

- លិខិតបញ្ជាក់បណ្តាញអគ្គិសនី
- លិខិតបញ្ជាក់តបណ្តាញទឹកស្អាត
- លិខិតបញ្ជាក់ជួលដី ផ្ទះ តូប យានជំនិះ
- លិខិតបញ្ជាក់ផ្ទះជួលបន្ទប់ស្នាក់នៅ
- បញ្ជាក់លើលិខិតស្នាមផ្សេងៗទៀត (ដែលមិនមែនជាសមត្ថកិច្ចរបស់ស្ថាប័នណាមួយ)។

### ២.៤.៣. ការដាក់ចេញលិខិតបទដ្ឋានគតិយុត្តនានា

សម្រាប់ប្រាំឆ្នាំខាងមុខនេះ ក្រុមប្រឹក្សាឃុំ និងខិតខំយកចិត្តទុកដាក់បម្រើសំណូមពរចាំបាច់នានា និងដាក់ចេញនូវលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីឱ្យសេចក្តីត្រូវការរបស់រដ្ឋបាលឃុំ ដូចជា៖ ការរៀបចំបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាឃុំ ការរៀបចំនិងការអនុវត្តគម្រោងមូលនិធិឃុំ ការរៀបចំគម្រោងថវិកាឃុំ ការរៀបចំនិងការអនុវត្តការផ្តល់សេវាជូនប្រជាពលរដ្ឋ។ ក្នុងនាមជាអ្នកបម្រើ និងផ្តល់សេវាជូនប្រជាពលរដ្ឋ ក្រុមប្រឹក្សាឃុំ សូមដាក់ចេញនូវលិខិតទាំងនោះដូចខាងក្រោម៖

❖ ប្រភេទលិខិតមានដូចជា[22]៖

- ដីកា
- សេចក្តីសម្រេច និង
- សេចក្តីណែនាំ។

## ២.៥. ការគ្រប់គ្រងហិរញ្ញវត្ថុរបស់ឃុំ

### ២.៥.១. ការរៀបចំ និងអនុម័តថវិការបស់ឃុំ

គម្រោងថវិការបស់ឃុំ ស្វាយទាបត្រូវបានរៀបចំឡើងក្រោមការទទួលខុសត្រូវរបស់មេឃុំនិងដោយមានជំនួយពីគណៈកម្មាធិការកសាងផែនការ និងថវិកាឃុំ រួចទើបបញ្ជូលទៅក្រុមប្រឹក្សាឃុំ ដើម្បីធ្វើការពិនិត្យ និងអនុម័ត។

### ២.៥.២. ចំណូលនិង ចំណាយថវិការបស់ឃុំ

**ក. ចំណូលរបស់ឃុំស្វាយទាប[23]**

- ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិ និងសេវា
- ផលពីការគ្រប់គ្រងរដ្ឋបាល

[22] គណៈកម្មាធិការកសាងផែនការ និងថវិកាឃុំ, *សៀវភៅផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ ២០១៧-២០២២ ឃុំស្វាយទាប ស្រុកចំការលើ ខេត្តកំពង់ចាម*, អនុម័តនៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៨, ទំព័រទី២១-២៣។

[23] គម្រោងថវិកាឃុំជាក់ស្តែងក្នុងឆ្នាំ២០២៤ (*ការគ្រប់គ្រងថវិកាឆ្នាំ២០២៤ តារាងសរុបចំណូលថវិការបស់រដ្ឋបាលឃុំ ស្វាយទាប*)។

- ចំណូលពីការអនុញ្ញាតរដ្ឋបាល ទម្រង់ការរដ្ឋបាល និងការគ្រប់គ្រងរដ្ឋបាលផ្សេងៗ
- ការឧបត្ថម្ភ និងចំណាយ
- ឧបត្ថម្ភធនពីថ្នាក់ជាតិ
- ឧបត្ថម្ភធនពីក្រសួង-ស្ថាប័ន
- ការចូលរួមធនធានពីសមាសភាគអភិវឌ្ឍន៍មូលដ្ឋាន
- មូលនិធិបម្រុង
- អតិរេកនៃកាលបរិច្ឆេទ
- ឧបត្ថម្ភធនពីថ្នាក់ជាតិសម្រាប់ចំណាយវិនិយោគ
- ឧបត្ថម្ភធនរវាងរដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ចំណាយវិនិយោគ
- ឧបត្ថម្ភធនពីរាជធានី ខេត្ត សម្រាប់ចំណាយវិនិយោគ
- ចំណូលពីការចូលរួមចំណែករបស់ប្រជាពលរដ្ឋមូលដ្ឋាន

**ខ. ការចំណាយរបស់ឃុំស្វាយទាប**[24]

- ការទិញសម្ភារៈផ្គត់ផ្គង់ថែទាំ
- ការទិញសម្ភារៈផ្គត់ផ្គង់សម្រាប់ថែទាំអគារ ប្រាសាទ និងសំណង់ផ្សេងៗ
- ការទិញសម្ភារៈផ្គត់ផ្គង់សម្រាប់ថែទាំផ្លូវថ្នល់ ស្ពាន និងលូ
- ការប្រើប្រាស់ប្រេងឥន្ធនៈនិងប្រេងរំអិល
- សម្ភារៈផ្គត់ផ្គង់ផ្នែករដ្ឋបាល
- សម្ភារៈការិយាល័យ
- សៀវភៅមើល និងឯកសារ
- ការបោះពុម្ព
- សម្ភារៈផ្គត់ផ្គង់ផ្នែករដ្ឋបាលផ្សេងៗ
- ស្បៀងអាហារ និងផលិតផ្នែកកសិកម្ម
- ពូជសត្វ
- សំលៀកបំពាក់និងការតុបតែង
- ឯកសណ្ឋាន
- សម្ភារៈតូចតាច សង្ហារិម និងសម្ភារបរិក្ខារ
- សម្ភារៈ និងបរិក្ខារបច្ចេកទេសមិនមែនព័ត៌មានវិទ្យា
- សង្ហារិម

[24] គម្រោងថវិកាឃុំជាក់ស្តែងក្នុងឆ្នាំ២០២៤ (*ការគ្រប់គ្រងឆ្នាំ២០២៤ តារាងសរុបចំណាយថវិការបស់រដ្ឋបាលឃុំ ស្វាយទាប*)។

- ថាមពលនិង ទឹក
- អគ្គិសនី
- ទឹក
- សេវាកម្ម
- សោហ៊ុយបណ្តុះបណ្តាលបុគ្គលិកក្នុងនិងក្រៅប្រទេស
- ការថែទាំ និងជួសជុល
- ការថែទាំនិងជួសជុលផ្លូវ ផ្លូវលំ ស្ពាន និងលូ
- ការថែទាំ និងជួសជុលសម្ភារៈឧបករណ៍បច្ចេកទេស
- បុគ្គលិកខាងក្រៅ
- ភ្នាក់ងារជាតិជាប់កិច្ចសន្យា
- បុគ្គលិកសមូហភាពសាធារណៈផ្សេងៗ
- ទំនាក់ទំនងសាធារណៈនិងផ្សព្វផ្សាយ
- ប្រជុំ សិក្ខាសាលា និងសន្និសីទ
- សោហ៊ុយបេសកកម្មក្នុងប្រទេស
- សោហ៊ុយបេសកកម្ម
- សោហ៊ុយស្នាក់នៅ
- សោហ៊ុយប្រៃសណីយ៍និងទូរគមនាគមន៍
- សោហ៊ុយទូរគមនាគមន៍
- បន្ទុកបុគ្គលិក
- ប្រាក់បំណាច់ផ្សេងៗ
- រង្វាន់
- លាភការ និងប្រាក់បំណាច់នៃអំណាចរដ្ឋបាលថ្នាក់ក្រោមជាតិ
- ប្រាក់ឧបត្ថម្ភសមាជិកក្រុមប្រឹក្សា និងមេឃុំ ចៅសង្កាត់
- ប្រាក់ឧបត្ថម្ភមន្ត្រីភូមិ
- បន្ទុកបុគ្គលិកផ្សេងៗទៀត
- ជំនួយដល់ប្រជាពលរដ្ឋសម្រាកនៅពេទ្យនិងចំណាយដំណើរការរបស់មណ្ឌលថែទាំសុខភាព
- ជួយជនរងគ្រោះដោយគ្រោះធម្មជាតិ
- ជំនួយសង្គមផ្សេងៗទៀត
- ឧបត្ថម្ភសហគមន៍ និងរក្សាសណ្តាប់ធ្នាប់ សន្តិសុខសង្គម
- ឧបត្ថម្ភដល់អង្គការមូលដ្ឋាន និងគាំទ្រកម្មវិធីផ្សេងៗ និង

- ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ។

### ២.៥.៣. ប្រព័ន្ធទូទាត់ និងគណនេយ្យឃុំ សង្កាត់

ក្នុងដំណើរការនៃការគ្រប់គ្រងថវិកា រដ្ឋបាលឃុំ សង្កាត់មានប្រព័ន្ធទូទាត់ និងប្រព័ន្ធគណនេយ្យដូចខាងក្រោមៈ

❖ ប្រព័ន្ធទូទាត់

- ការទូទាត់ផ្ទាល់៖ ជាការទូទាត់តាមរយៈរតនាគាររាជធានី ខេត្ត។
- ការទូទាត់តាមរយៈរជ្ជទេយ្យបុរេប្រទាន៖ ចំនួនទឹកប្រាក់សម្រាប់មួយគោលការណ៍ចំណាយ ឬមួយប័ណ្ណចំណាយនៃរជ្ជទេយ្យបុរេប្រទានយ៉ាងច្រើនបំផុតត្រឹម៥០០,០០០រៀល (ប្រាំរយពាន់រៀល)។

❖ ប្រព័ន្ធគណនេយ្យ

- គណនេយ្យហិរញ្ញវត្ថុ៖ គណនេយ្យករនៅរតនាគាររាជធានី ខេត្តមានភារកិច្ចអនុវត្តគណនេយ្យហិរញ្ញវត្ថុ។ គណនេយ្យហិរញ្ញវត្ថុគឺជាកិច្ចបញ្ជីការរាល់ចំណូល ចំណាយទៅក្នុងប្រព័ន្ធគណនេយ្យ។
- គណនេយ្យថវិកា៖ មេឃុំ ចៅសង្កាត់មានភារកិច្ចទទួលខុសត្រូវក្នុងការអនុវត្តគណនេយ្យថវិកា។ គណនេយ្យថវិកា គឺជាការតាមដាន និងរាយការណ៍អំពីការអនុវត្តចំណូល ចំណាយ ថវិកាដែលបានអនុម័ត។

## ២.៦. ការតាមដាន និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍

### ២.៦.១. យន្តការតាមដាន និងវាយតម្លៃ

ដើម្បីអនុវត្តន៍ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ(២០១៧-២០២២)របស់ក្រុមប្រឹក្សាឃុំអាណត្តិទី៤ ប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល ក្រុមប្រឹក្សាឃុំមានយន្តការដូចជា៖ រៀបចំធ្វើការតាមដានជាប្រចាំដោយជនបង្គោលតាមដានត្រួតពិនិត្យគម្រោងឃុំ នៅក្នុងអំឡុងពេលនៃការអនុវត្តគម្រោង ឬសកម្មភាពទៅតាមផែនការគម្រោង និងការណែនាំផ្សេងៗដើម្បីដឹងថាគម្រោងឬសកម្មភាពមានភាពរីកចម្រើន និងមានឧបសគ្គអ្វីមករារាំងខ្លះ ហើយមានវិធានការសម្រាប់ដោះស្រាយបន្ទាន់ ដោយមានការចូលរួម អំពីគណៈកម្មការគ្រប់គ្រងគម្រោង និងមានការចូលរួមគ្រប់សមាសភាពនៃអ្នកពាក់ព័ន្ធ ដូចជាចាស់ ព្រឹទ្ធាចារ្យ ក្រុមអ្នកទទួលផលពីគម្រោងផ្ទាល់ មេភូមិ គណៈកម្មាធិការកសាងផែនការនិងថវិកាឃុំ តាមបណ្ដាឆ្នាំនីមួយៗដោយរៀបចំឱ្យមានគោលការណ៍មួយចំនួន សម្រាប់តាមដានត្រួតពិនិត្យ និងវាយតម្លៃដើម្បីឱ្យដឹងពីភាពរីកចម្រើននិងបញ្ហាប្រឈមនានា ដែលកើតមានឡើង នៅក្នុងអំឡុងពេលប្រតិបត្តិការ ទុកជាមេរៀនបទពិសោធន៍ និងកែលម្អសម្រាប់ឆ្នាំបន្ទាប់ នៃការអនុវត្តការងារ។

ក្រុមប្រឹក្សាឃុំ រៀបចំបង្កើតគណៈកម្មការតាមដានត្រួតពិនិត្យ និងវាយតម្លៃ នៃការអនុវត្តផែនការអភិវឌ្ឍន៍ ដោយដាក់ឱ្យប្រើប្រាស់ទិន្នន័យ សូចនាករសម្រាប់ឆ្នាំនីមួយៗដើម្បីកត់ត្រានូវវឌ្ឍនភាពនៃការអនុវត្តកម្មវិធី

អភិវឌ្ឍន៍មូលដ្ឋានរបស់រដ្ឋបាលឃុំ។ ផែនការតាមដាននិងវាយតម្លៃគឺបានរៀបចំបង្កើតសូចនាករសំខាន់ៗ សម្រាប់តាមដាន និងមានផែនការតាមបណ្តាឆ្នាំនីមួយៗសម្រាប់តាមដាន ការអនុវត្តផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំនៅក្នុងអំឡុងពេលអនុវត្តសកម្មភាព គឺពាក់កណ្តាលគម្រោង ពេលបញ្ចប់គម្រោង និងក្រោយពេលបញ្ចប់គម្រោង ដោយពិនិត្យ និងវាយតម្លៃលើ ប្រសិទ្ធភាពនៃការអនុវត្តគម្រោង លទ្ធផលសម្រេចបានផលប៉ះពាល់របស់គម្រោង មេរៀននិងបទពិសោធន៍ សម្រាប់កែលម្អការអនុវត្តគម្រោងនៅពេលក្រោយ និងជាព័ត៌មានមូលដ្ឋានក្នុងការវាយតម្លៃគម្រោង។

គណៈកម្មការគ្រប់គ្រងគម្រោងរាយការណ៍នៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាឃុំអំពីលទ្ធផលនៃការតាមដាននៅពាក់កណ្តាលឆ្នាំ និងនៅចុងឆ្នាំនីមួយៗ ដោយដាក់ជូនក្រុមប្រឹក្សានូវរបាយការណ៍ ស្តីពីការអនុវត្តផែនការអភិវឌ្ឍន៍ដើម្បីពិនិត្យអនុម័ត។ រដ្ឋបាលឃុំ និងវាយតម្លៃអំពីលទ្ធផលសម្រេចបានធៀបនឹងគោលដៅសូចនាករដែលបានកំណត់។

### ២.៦.២. វិធីសាស្ត្រ តាមដាន និងវាយតម្លៃ

ជាទូទៅរដ្ឋបាលឃុំប្រើប្រាស់វិធីសាស្ត្រតាមដាននិងវាយតម្លៃតាមទម្លាប់ដែលអនុវត្តកន្លងមកគឺតាមរយៈការចុះពិនិត្យផ្ទាល់របស់ជនបង្គោលតាមដានត្រួតពិនិត្យគម្រោងឃុំ តាមរយៈការចេញរបាយការណ៍រីកចម្រើនរបស់មន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធ តាមរយៈការប្រជុំជាមួយអ្នកពាក់ព័ន្ធ និងកិច្ចប្រជុំក្រុមប្រឹក្សាឃុំ ដើម្បីអនុម័តនិងចេញអាណត្តិបើកប្រាក់ឱ្យអ្នកទទួលការ។

សម្រាប់វិធីសាស្ត្រទាំងនេះមិនទាន់ឆ្លើយតបតាមតម្រូវការជាក់ស្តែងដែលបានណែនាំក្នុងសៀវភៅ ស្តីពីការតាមដានត្រួតពិនិត្យ និងវាយតម្លៃ គម្រោងអភិវឌ្ឍន៍ឃុំ នៅឡើយទេ ដោយសមត្ថភាពរបស់រដ្ឋបាលឃុំនៅមានកម្រិត។ ប្រសិនបើអនុវត្តតាមវិធីសាស្ត្រត្រឹមត្រូវ រដ្ឋបាលឃុំត្រូវ រៀបចំកំណត់វិធីសាស្ត្រឱ្យបានជាក់លាក់ដូចជា៖ វិធីសាស្ត្រប្រមូលព័ត៌មាន, កំណត់ពេលវេលា, ការសង្កេត, ការសម្ភាសន៍, ការបំពេញបញ្ជីសំណួរ, ការពិភាក្សាជាក្រុម វិធីសាស្ត្រទាំងនេះហើយដែលរដ្ឋបាលឃុំប្រើដោយផ្ទៀងផ្ទាត់។

### ២.៦.៣. សូចនាករតាមដាន និងវាយតម្លៃ

គោលបំណង និងគោលដៅ

- ផ្នែកសេដ្ឋកិច្ច

គោលបំណង៖ នៅក្នុងរយៈពេលប្រាំឆ្នាំ (២០១៧-២០២២) របស់ក្រុមប្រឹក្សាឃុំស្វាយទាប អាណត្តិទី៤ នេះ ឃុំធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធនានាដូចជា៖ ការកែលម្អផ្លូវលំជនបទនានាឱ្យមានភាពប្រសើរឡើងទូទាំងឃុំ ស្តារប្រព័ន្ធធារាសាស្ត្រ ទំនប់ ប្រឡាយ អាងស្តុកទឹកការបង្កើនការដាំដុះ ការផលិតនិងការរក

ទីផ្សារលក់ផលិតផល ការតភ្ជាប់បណ្តាញអគ្គិសនីតាមបណ្តាភូមិទាំងក្នុងឃុំ សម្រាប់ប្រជាពលរដ្ឋប្រើប្រាស់ និងប្រកបអាជីវកម្មនានាដើម្បីបង្កើនសេដ្ឋកិច្ចក្នុងគ្រួសារ។[25] ដែលក្នុងនោះមានគោលដៅ៖

- គោលដៅទី១៖ នៅឆ្នាំ២០២២ ប្រជាពលរដ្ឋ៩០%មានផ្លូវល្អសម្រាប់ប្រើប្រាស់
- គោលដៅទី២៖ នៅឆ្នាំ២០២២ ប្រជាពលរដ្ឋមានប្រព័ន្ធស្រោចស្រពផលដំណាំបាន ៨០%
- គោលដៅទី៣៖ នៅឆ្នាំ២០២២ ប្រជាពលរដ្ឋចំនួន៨០% នឹងចេះពីបច្ចេកទេសក្នុងការដាំដំណាំ
- គោលដៅទី៤៖ នៅឆ្នាំ២០២២ ប្រជាពលរដ្ឋចំនួន៨០% មានបច្ចេកទេសចិញ្ចឹម និងថែទាំសត្វ
- គោលដៅទី៥៖ នៅឆ្នាំ២០២២ ប្រជាពលរដ្ឋចំនួន៨០% មានបណ្តាញទឹកស្អាតប្រើប្រាស់

❖ ផ្នែកសង្គមកិច្ច

គោលបំណង៖ រយៈពេលប្រាំឆ្នាំ(២០១៧-២០២២) ក្នុងអាណត្តិទី៤ របស់ក្រុមប្រឹក្សាឃុំ ប្រជាពលរដ្ឋទទួលបាននូវសេវា សង្គមនានា ដូចជា៖ ចំណេះដឹងមូលដ្ឋានក្នុងការលើកកម្ពស់សុខភាពមាតា និងទារក ការកាត់បន្ថយ អត្រាអនក្ខរភាព ពង្រីកសាលារៀនឆ្លងកាត់ ប្រជាពលរដ្ឋយល់ដឹងពីសារៈសំខាន់នៃការសិក្សារបស់កូន ជម្រុញការលើកកម្ពស់សមភាពយេនឌ័រ ទប់ស្កាត់បានអំពើហិង្សាក្នុងគ្រួសារ ទទួលបានសុវត្ថិភាពក្នុងការធ្វើចំណាកស្រុក ការរំលោភបំពានលើកម្លាំងពលកម្មកុមារត្រូវបានកាត់បន្ថយ។ បង្កើនការយល់ដឹងពីសុខភាពអនាម័យនៅតាមសហគមន៍ជនបទ។[26]

- គោលដៅទី១៖ នៅឆ្នាំ២០២២ កុមារចំនួន៩០% បានចូលរៀន និងមានការអប់រំតាមផ្ទះ
- គោលដៅទី២៖ នៅឆ្នាំ២០២២ ប្រជាពលរដ្ឋ៨០% យល់ដឹងពីសារៈសំខាន់នៃការពិនិត្យសុខភាពនៅមណ្ឌលសុខភាព
- គោលដៅទី៣៖ នៅឆ្នាំ២០២២ កុមារកំព្រាក្រីក្រនិងអ្នកជំងឺអេដស៍មានការគាំទ្រពីអង្គការដៃគូ
- គោលដៅទី៤៖ នៅឆ្នាំ២០២២ ប្រជាពលរដ្ឋ៧៥%យល់ដឹងពីការធ្វើចំណាកស្រុកដោយស្របច្បាប់
- គោលដៅទី៥៖ នៅឆ្នាំ២០២២ គ្មានអំពើហិង្សាក្នុងគ្រួសារក្នុងឃុំ

❖ ផ្នែកគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន និងការបន្សាំបម្រែបម្រួលអាកាសធាតុ

គោលបំណង៖ នៅក្នុងអាណត្តិទី៤នេះ ក្រុមប្រឹក្សាឃុំបានរៀបចំផែនការប្រើប្រាស់ដីធ្លីឱ្យបានសមស្រប ដូចជាដីសម្រាប់សាងសង់លំនៅដ្ឋាន ដីបង្កបង្កើនផលដីរបស់រដ្ឋ។ ការធានានិរន្តរភាពបរិស្ថាន បានល្អ ទប់ស្កាត់

[25]គណៈកម្មាធិការកសាងផែនការ និងថវិកាឃុំ, *សៀវភៅផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ ២០១៧-២០២២ ឃុំស្វាយទាប ស្រុកចំការលើ ខេត្តកំពង់ចាម*, អនុម័តនៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៨, ទំព័រទី២៦។

[26]គណៈកម្មាធិការកសាងផែនការ និងថវិកាឃុំ, *សៀវភៅផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ ២០១៧-២០២២ ឃុំស្វាយទាប ស្រុកចំការលើ ខេត្តកំពង់ចាម*, អនុម័តនៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៨, ទំព័រទី២៧។

រាល់ការបំផ្លាញធនធានធម្មជាតិ ទ្រព្យសម្បត្តិសាធារណៈ រមណីយដ្ឋាននានា។ ត្រៀមបម្រុងស្បៀង សម្ភារៈបង្ការទុកជាមុនដើម្បីជួយសង្គ្រោះដល់ប្រជាពលរដ្ឋដែលជួបប្រទះនឹងគ្រោះមហន្តរាយផ្សេងៗ និងការប្រែប្រួលអាកាសធាតុ។ ដោយក្នុងចំណុចនេះមានគោលដៅ[27]៖

- គោលដៅទី១៖ នៅឆ្នាំ២០២២មានការគ្រប់គ្រងកាកសំណល់បានល្អ
- គោលដៅទី២៖ នៅឆ្នាំ២០២២ទិន្នផលត្រីមានការកើនឡើង៩០%
- គោលដៅទី៣៖ នៅឆ្នាំ២០២២ ប្រជាពលរដ្ឋ៩០% យល់ដឹងពីច្បាប់ភូមិបាល

❖ ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់

គោលបំណង៖ រយៈពេលប្រាំឆ្នាំ(២០១៧-២០២២) អាណត្តិទី៤ របស់ក្រុមប្រឹក្សាឃុំ បានពង្រឹងការងាររបស់ខ្លួន ក្នុងគោលដៅពង្រឹងបន្ថែមនូវស្ថិរភាព សន្តិសុខសណ្តាប់ធ្នាប់សង្គមជូនប្រជាពលរដ្ឋ ការផ្តល់សេវាសាធារណៈ ត្រូវបានកែលម្អ និងសម្របសម្រួលឱ្យមានភាពសាមញ្ញងាយស្រួលតាមរយៈការបែងចែកមុខងារតួនាទីភារកិច្ចដល់មន្ត្រីស្របតាមលក្ខខណ្ឌការងារដើម្បីឱ្យមានការអភិវឌ្ឍប្រកបដោយចីរភាព ប្រសិទ្ធភាពក្នុងការរួមចំណែកកាត់បន្ថយភាពក្រីក្រជូនប្រជាពលរដ្ឋផ្សព្វផ្សាយណែនាំចាត់តាំងអនុវត្តគោលនយោបាយ ភូមិឃុំមានសុវត្ថិភាព ដើម្បីធានាឱ្យប្រជាពលរដ្ឋគ្រប់រូបរស់នៅប្រកបដោយភាពសុខសាន្ត។[28]

- គោលដៅទី១៖ នៅឆ្នាំ២០២២ សន្តិសុខសណ្តាប់ធ្នាប់សាធារណៈមានភាពប្រសើរ
- គោលដៅទី២៖ នៅឆ្នាំ២០២២ ថ្នាក់ដឹកនាំភូមិ ឃុំ មានសមត្ថភាពគ្រប់គ្រាន់បំពេញការងារ
- គោលដៅទី៣៖ នៅឆ្នាំ២០២២ ការប្រមូលទិន្នន័យភូមិឃុំ មានភាពល្អប្រសើរជាងមុន។

[27] គណៈកម្មាធិការកសាងផែនការ និងថវិកាឃុំ, *សៀវភៅផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ ២០១៧-២០២២ ឃុំស្វាយទាប ស្រុកចំការលើ ខេត្តកំពង់ចាម*, អនុម័តនៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៨, ទំព័រទី២៨។

[28] គណៈកម្មាធិការកសាងផែនការ និងថវិកាឃុំ, *សៀវភៅផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ ២០១៧-២០២២ ឃុំស្វាយទាប ស្រុកចំការលើ ខេត្តកំពង់ចាម*, អនុម័តនៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៨, ទំព័រទី២៩។

# ជំពូកទី៣

## សមិទ្ធផលការងារ

## បញ្ហាប្រឈម និងដំណោះស្រាយ

# ជំពូកទី៣

# សមិទ្ធផលការងារ បញ្ហាប្រឈម និងដំណោះស្រាយ

## ៣.១. សមិទ្ធផលការងាររបស់ឃុំស្វាយទាប

របាយការណ៍ស្តីពីសមិទ្ធផលការងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់

អាណត្តិទី៤ គឺជាការបរិយាយសង្ខេបអំពីសមិទ្ធផលការងារដែលរដ្ឋបាលឃុំស្វាយទាប សម្រេចបាន ក្នុងរយៈពេលប្រាំឆ្នាំចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៧ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១។[29]

### ៣.១.១. ស្ថិតិប្រជាពលរដ្ឋ

ឃុំស្វាយទាប គឺជាឃុំមួយក្នុងចំណោមឃុំទាំង ៨ ស្ថិតនៅក្នុងស្រុកចំការលើ ខេត្តកំពង់ចាម នៅតាម បណ្តោយផ្លូវជាតិលេខ៧១ ស្ថិតនៅលើតំបន់ខ្ពង់រាប ស្ថិតនៅប៉ែកខាងជើងឈាងខាងលិច ទីរួមខេត្តកំពង់ចាម មានព្រំប្រទល់ខាងជើងទល់និងឃុំចំការអណ្តូង ស្រុកចំការលើ ខាងត្បូងទល់ និងឃុំតាអុង ខាងកើតទល់នឹង ឃុំជយោ ខាងលិចទល់ និងឃុំប្រនាង ស្រុកបារាយណ៍។ សមិទ្ធផលក្នុងអាណត្តិទី៤ នៃឃុំស្វាយទាបមាន ចំនួនសរុបគ្រួសារ ៥,៥០៨ គ្រួសារអចិន្ត្រៃយ៍ ៥,៤៩១ គ្រួសារបណ្តោះអាសន្ន១៧។ ប្រជាពលរដ្ឋសរុប ២៣,១៦៣នាក់ ប្រជាពលរដ្ឋជាស្ត្រី ១១,៨៦០នាក់ ប្រជាពលរដ្ឋដែលមានអាយុ១៨ឆ្នាំឡើង ១៥,០៨៩នាក់ និងប្រជាពលរដ្ឋចំណាកស្រុក ៥៣នាក់។

### ៣.១.២. ស្ថិតិក្រុមប្រឹក្សា និង បុគ្គលិក

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ សរុប ១១នាក់ ស្រី ៣នាក់ សមាជិកក្រុមប្រឹក្សាដែលបានផ្លាស់ប្តូរ ក្នុងរយៈពេល៥ឆ្នាំ មាន១នាក់ ស្រី ០នាក់ មេឃុំ ចៅសង្កាត់១នាក់ ជំទប់ទី១ ចៅសង្កាត់រងទី១ មួយនាក់ ស្រី០នាក់ ជំទប់ទី២ ចៅសង្កាត់រងទី២ មួយនាក់ ស្រី១នាក់ ស្មៀនឃុំ សង្កាត់ ១នាក់ ស្រី០នាក់ បុគ្គលិកកិច្ចសន្យា ២នាក់ ស្រី០នាក់ មេភូមិ ១៤នាក់ ស្រី១នាក់ អនុប្រធានភូមិ ១៤នាក់ ស្រី១នាក់ សមាជិកភូមិ ១៤នាក់ ស្រី១៤នាក់ អ្នកទទួលបន្ទុកកិច្ចការនារីនិង កុមារដែលមិនមែនជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់០នាក់ ស្រី០នាក់ និងជនបង្គោលតាមដានត្រួតពិនិត្យ និងវាយតម្លៃឃុំ សង្កាត់ ២នាក់ ស្រី១នាក់។

### ៣.១.៣. ដីកា សេចក្តីសម្រេច និងលិខិតរដ្ឋបាល

ការបរិយាយទៅលើសមិទ្ធផលដែលឃុំបានបំពេញដូចជា ដីកាដែលបានដាក់ចេញក្នុងឆ្នាំ២០១៧ដល់ ២០២១ សរុប២ដីកា នៃសេចក្តីសម្រេចដែលបានដាក់ចេញ ដូចគ្នាដែលឆ្នាំ២០១៧ ដល់២០២១ សរុប៨០ លិខិតរដ្ឋបាលដែលបានដាក់ចេញ ក្នុងឆ្នាំ២០១៧ ដល់២០២១ សរុប ៩,៥២៤ និងលិខិតដែលបានទទួលក្នុង ឆ្នាំ ២០១៧ ដល់២០២១ សរុប៥៦២។

[29] របាយការណ៍ស្តីពីសមិទ្ធផលការងាររបស់ក្រុមប្រឹក្សាឃុំស្វាយទាបអាណត្តិទី៤។

### ៣.១.៤. កិច្ចប្រជុំក្រុមប្រឹក្សា និងគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ

កិច្ចប្រជុំក្រុមប្រឹក្សា និងគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ ស្របតាមកិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាក្នុងឆ្នាំ២០១៧ ដល់ ២០២១ សរុប៦០កិច្ចប្រជុំវិសាមញ្ញរបស់ក្រុមប្រឹក្សាសរុប៦០ កិច្ចប្រជុំសម្ងាត់របស់ក្រុមប្រឹក្សា សរុប០ និងកិច្ចប្រជុំគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ សរុប៦០។

### ៣.១.៥. គម្រោងវិនិយោគដែលមានការសន្យាគាំទ្រដោយថវិកាឃុំ សង្កាត់

**ផ្នែកសេដ្ឋកិច្ច និងសមិទ្ធផលៈ**

- គម្រោងសាងសង់ផ្លូវដីប្រវែង ៤,៥៥០ម៉ែត្រ ២០១៧ ១គម្រោង ៨០,៩៨០,០០០ លានរៀល
- គម្រោងជួសជុលផ្លូវដីប្រវែង ៨,៥៥០ម៉ែត្រ ២០១៨ ១គម្រោង ១០៥,២៣៥,០០០ លានរៀល
- គម្រោងជួសជុលផ្លូវដីប្រវែង ១៦៥ម៉ែត្រ ២០១៨ ១គម្រោង ៣,៥៩៩,០៨៣ លានរៀល
- គម្រោងជួសជុលផ្លូវបេតុងអាមេ ២០១៩ ១គម្រោង ១៧០,១៧៤០,៤២៧ លានរៀល
- សាងសង់ផ្លូវបេតុងអាមេ ប្រវែង ៥៤៧ម៉ែត្រ ២០២០ ១គម្រោង ២៥៩,៨២៥,០០០ លានរៀល
- សាងសង់ផ្លូវបេតុងអាមេ ប្រវែង ៨៥៤ម៉ែត្រ ២០២១ ១គម្រោង ៣៧១, ៣៥០,០០០លានរៀល

**ផ្នែកសង្គមកិច្ចៈ**

- ថវិកាដល់ស្ត្រីទៅសម្រាលកូន នៅមណ្ឌលសុខភាព ២០១៧ ១គម្រោង ៣,២០០,០០០ រៀល
- ការផ្សព្វផ្សាយ លើកកម្ពស់ទឹកស្អាត និង អនាម័យ ២០១៧ ១គម្រោង ២,៥០០,០០០រៀល
- ការផ្សព្វផ្សាយ ពីការចុះអត្រានុកូលដ្ឋាន ២០១៧ ១គម្រោង ២,៥០០,០០០រៀល
- ផ្សព្វផ្សាយពីសុខភាពស្ត្រី និង កុមារ ២០១៧ ១គម្រោង ២,៥០០,០០០រៀល
- ផ្សព្វផ្សាយស្តីពីគ្រោះថ្នាក់ដោយគ្រោះធម្មជាតិ ២០១៧ ១គម្រោង ៣,០០០,០០០រៀល
- ថវិកាដល់ស្ត្រីទៅសម្រាលកូន នៅមណ្ឌលសុខភាព ២០១៨ ១គម្រោង ១,៣៨០,០០០រៀល
- ការផ្សព្វផ្សាយ ពីការចុះអត្រានុកូលដ្ឋាន ២០១៨ ១គម្រោង ៣,៥០០,០០០រៀល
- ផ្តល់ធុងចម្រោះទឹកស្អាតជូនគ្រួសារក្រីក្រ ២០១៨ ១គម្រោង ៥,០០០,០០០រៀល
- ឧបត្ថម្ភអង្ករដល់គ្រួសារក្រីក្រ ២០១៩ ១គម្រោង ២,០០០,០០០រៀល
- ការផ្សព្វផ្សាយ ពីបញ្ហាអនាម័យ ២០១៩ ១គម្រោង ៣,៦០០,០០០រៀល
- ផ្តល់ធុងចម្រោះទឹកស្អាតជូនគ្រួសារក្រីក្រ ២០១៩ ១គម្រោង ២,០០០,០០០រៀល
- ឧបត្ថម្ភអង្ករដល់គ្រួសារក្រីក្រ ២០២០ ១គម្រោង ៥,០០០,០០០រៀល
- ការផ្សព្វផ្សាយ ពីបញ្ហាអនាម័យ ២០២០ ១គម្រោង ៥,៦០០,០០០រៀល
- ផ្តល់ធុងចម្រោះទឹកស្អាតជូនគ្រួសារក្រីក្រ ២០២០ ១គម្រោង ៤,០០០,០០០រៀល

**ផ្នែកធនធានធម្មជាតិ និងបរិស្ថាន**

- ផ្តល់ស្បៀងជូនគ្រួសាររងគ្រោះដោយគ្រោះធម្មជាតិ ២០១៧ ១គម្រោង ៤,០០០,០០០រៀល

- ផ្តល់ស្បៀងជូនគ្រួសាររងគ្រោះដោយគ្រោះធម្មជាតិ ២០១៨ ១គម្រោង ៤,២០០,០០០រៀល
- ផ្តល់ស្បៀងជូនគ្រួសាររងគ្រោះដោយគ្រោះធម្មជាតិ ២០១៩ ១គម្រោង ៦,០០០,០០០រៀល
- ផ្តល់ស្បៀងជូនគ្រួសាររងគ្រោះដោយគ្រោះធម្មជាតិ ២០២០ ១គម្រោង ៦,០០០,០០០រៀល

## ៣.២. ស្ថានភាពនៅឃុំស្វាយទាប និងបញ្ហាប្រឈម

### ៣.២.១. ស្ថានភាពសេដ្ឋកិច្ច

ឃុំស្វាយទាប ជាឃុំមួយដែលប្រជាពលរដ្ឋភាគច្រើនប្រកបរបរកសិកម្ម ធ្វើស្រែចំការ ឃុំមានផ្ទៃដីផលិតកម្មកសិកម្មសរុប ៥,១៧៥ ហិកតា សម្រាប់ដាំដំណាំ និងធ្វើស្រែចំការ ក្នុងនោះឃុំមានផ្ទៃដីស្រែវស្សាចំនួន២,២១០ ហិកតាដោយឡែកស្រែវស្សានៅតាមភូមិខ្លះ កសិករធ្វើស្រែបាន២ដងក្នុងមួយរដូវ គឺស្រែប្រពលវប្បកម្មបង្កើនរដូវ។ ចំពោះសកម្មភាពសំខាន់ៗក្នុងវិស័យកសិកម្មឃុំ មានសក្តានុពលសំខាន់ៗដូចខាងក្រោមៈ

មានផ្ទៃផលិតកម្មកសិកម្ម មានកម្លាំងពលកម្ម មានគ្រឿងយន្តកសិកម្ម មានប្រភពទឹក មានប្រព័ន្ធធារាសាស្ត្រសម្រាប់ស្រោចស្រព មានហេដ្ឋារចនាសម្ព័ន្ធ គមនាគមន៍តភ្ជាប់ពីភូមិមួយទៅភូមិមួយទៀត។ ឃុំមានសិប្បកម្មខ្នាតតូច និងធំ ដូចជាៈ ម៉ាស៊ីនកិនស្រូវខ្នាតមធ្យមចំនួន១៧ ទីតាំង សិប្បកម្មផលិតទឹកសុទ្ធ០៤ ទីតាំង សិប្បកម្មកែច្នៃឬវេចខ្ចប់ផលនេសាទ០៣ ទីតាំង អាជីវកម្មលក់ដូរគ្រឿងទេស២២៥ ទីតាំង ក្នុងនោះលក់គ្រឿងបរិភោគ និងទំនិញប្រើប្រាស់៥៥ ទីតាំង លក់ខោអាវ ស្បែកជើង គ្រឿងក្រអូប ៣០ ទីតាំង លក់គ្រឿងអលង្ការ ០៨ ទីតាំង លក់គ្រឿងអេឡិចត្រូនិច ០៧ ទីតាំង លក់គ្រឿងសង្ហារិម (តុ កៅអី) ១០ ទីតាំង លក់សម្ភារៈសំណង់០៩ ទីតាំង សេវាកម្មខ្នាតតូច កាត់សក់ ម៉ាស្សា១៩ ទីតាំង លក់បាយគុយទាវ២១ ទីតាំង ភោជនីយដ្ឋាន ០១ កន្លែង ជួសជុលឬលក់កង់ម៉ូតូ ២៧ ទីតាំង ជួសជុលឬលក់គ្រឿងយន្ត និងឧបករណ៍កសិកម្ម ០៩ កន្លែង ជួសជុលគ្រឿង អេឡិចត្រូនិច១១ ទីតាំង ឱសថស្ថាន ឱសថស្ថានរង០៤ ទីតាំង គ្លីនីច ០៦ កន្លែង និង ផ្ទះសំណាក់ ០៨ កន្លែង។[30]

ទោះបីជាឃុំមានសក្តានុពលទាំងនេះក៏ដោយ ក៏ឃុំនៅមានបញ្ហាប្រឈមខ្លះ ដូចខាងក្រោមៈ

- ដីផលិតខ្សោះជីជាតិ
- ខ្វះពូជដែលមានទិន្នផលខ្ពស់
- ខ្វះជំនាញបច្ចេកទេសដាំដុះ

[30] គណៈកម្មាធិការកសាងផែនការ និងថវិកាឃុំ, *សៀវភៅផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ ២០១៧-២០២២ ឃុំស្វាយទាប ស្រុកចំការលើ ខេត្តកំពង់ចាម*, អនុម័តនៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៨, ទំព័រទី៣។

- មានការធ្វើចំណាកស្រុកទៅធ្វើជាកម្មករសំណង់ ហើយមួយចំនួនទៀតបានធ្វើចំណាកស្រុកទៅរកការងារធ្វើដែលទទួលបានប្រាក់កម្រៃខ្ពស់ (ក្នុងប្រទេស និងក្រៅប្រទេស)។
- ហេដ្ឋារចនាសម្ព័ន្ធមួយចំនួនមានសភាពទ្រុឌទ្រោម ប្រព័ន្ធស្រោចស្រពពុំទាន់មានគ្រប់គ្រាន់តាមតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋ
- ការភ្ជាប់បណ្តាញអគ្គិសនី ចូលទៅតាមភូមិទើបតែបានតិចតួច ពុំទាន់បានតាមតម្រូវការប្រើប្រាស់របស់ប្រជាពលរដ្ឋនៅឡើយ។

### ៣.២.២. ស្ថានភាពសង្គមកិច្ច

នៅក្នុងឃុំស្វាយទាប ស្ថានភាពសង្គមកិច្ច ជាផ្នែកមួយដែលត្រូវធ្វើការសិក្សាពីលក្ខណៈប្រជាសាស្ត្រ សេវាសាធារណៈផ្នែកសង្គម និងសុវត្ថិភាព សុខុមាលភាព របស់ប្រជាពលរដ្ឋក្នុងស្រុក ដោយផ្តោតសំខាន់លើចំណុចមួយចំនួនដូចខាងក្រោម៖

#### ក. វិស័យអប់រំ

នៅក្នុងឃុំស្វាយទាប វិស័យអប់រំមានសារៈសំខាន់ណាស់សម្រាប់ការអភិវឌ្ឍធនធានមនុស្សឱ្យមានសមត្ថភាពទាំងចំណេះដឹង ចំណេះធ្វើ និងបទពិសោធន៍ ដែលជាមូលដ្ឋានគ្រឹះក្នុងការអភិវឌ្ឍសង្គម និងមូលដ្ឋានឱ្យបានរីកចម្រើន និងជួយជម្រុញឱ្យសម្រេចនូវគោលនយោបាយអប់រំ ផែនការយុទ្ធសាស្ត្រអប់រំ ជួយឱ្យសង្គមជាតិកាន់តែរឹងមាំ ប្រកបដោយគុណភាពប្រសិទ្ធភាព និងសមធម៌។ ស្ថានភាពអប់រំឃុំស្វាយទាបមានបុគ្គលិកសរុប ១៥១នាក់ ចែកចេញជា ០៣ភូមិសិក្សាគឺ៖

- មត្តេយ្យសិក្សា
- បឋមសិក្សា
- មធ្យមសិក្សា
    - ក្នុងនោះគ្រូមត្តេយ្យសហគមន៍ ១ថ្នាក់ គ្រូ១នាក់ សិស្ស ២៤នាក់
    - បឋមសិក្សាមាន៨សាលា ស្មើ៦៦បន្ទប់ ស្មើនឹង៨៨ថ្នាក់ មានគ្រូ ៧៣នាក់ និងសិស្សសរុប ៣,៣៥១ នាក់
    - មធ្យមសិក្សាមាន ១សាលា ស្មើ៤៨បន្ទប់ ស្មើនឹង៣៤ថ្នាក់ មានគ្រូ ៧១នាក់ និងសិស្សសរុប ១,៧៣៧នាក់។

ការប្រមូលកុមារឱ្យចូលរៀន នៅមិនទាន់អស់ពីមូលដ្ឋានដាច់ស្រយាល។ គុណភាពអប់រំមិនទាន់ឆ្លើយតបតាមស្តង់ដាកម្រិតថ្នាក់។ សិស្សបោះបង់ការសិក្សាច្រើននៅមធ្យមសិក្សា ហើយកុមារអាយុ៦ឆ្នាំ មិនបានចូលរៀនមត្តេយ្យ និងបឋមមានចំនួន ១៥.២%។

**ខ. វិស័យសុខាភិបាល**

ឃុំមានមណ្ឌលសុខភាព ០២ កន្លែង ដែលកំពុងធ្វើប្រតិបត្តិការ យ៉ាងសកម្មលើជំនាញវិជ្ជាជីវៈរបស់ខ្លួន មានមន្ត្រីសុខាភិបាល ១៦នាក់ ស្រី៧នាក់ ការគាំទ្រវិស័យនេះ អង្គភាព មានដៃគូអភិវឌ្ឍន៍ដូចជា៖ កិច្ចសហប្រតិបត្តិការបច្ចេកទេស អង្គការស្ពានកម្ពុជា-ហូឡង់ (មណ្ឌលព័ត៌មានជម្ងឺ) ជម្ងឺលើសឈាមនិងទឹកនោមផ្អែម។

ទោះបីជាផ្នែកសុខាភិបាលមានធនធានមនុស្ស សម្ភារៈ និងទទួលបានការគាំទ្រពីដៃគូអភិវឌ្ឍន៍ក៏ដោយ ក៏នៅជួបប្រទះបញ្ហាប្រឈមដូចជា៖ ប្រជាពលរដ្ឋមួយចំនួន មិនទាន់យល់ពីសារៈសំខាន់ នៃការមកទទួលសេវានៅមណ្ឌលសុខភាព ជាពិសេសស្ត្រីមានផ្ទៃពោះ មកទទួលសេវាពិនិត្យសុខភាពតាមការកំណត់របស់ឆ្មប ជំងឺឆ្លង និងមិនឆ្លងនៅតែកើតមាន គុណភាពសេវានៅមិនទាន់បានល្អប្រសើរ ស្របតាមតម្រូវការរបស់ប្រជាពលរដ្ឋ សេវាឯកជនខ្លះនៅមិនទាន់អនុវត្តតាមច្បាប់កំណត់ខ្វះបុគ្គលិកឯកទេស។

**គ. ស្ថានភាពយេនឌ័រ**

ការរៀបចំផែនការអភិវឌ្ឍន៍ឃុំគឺជាកម្មវិធីមួយដ៏មានសារៈសំខាន់ក្នុងការជួយលើកកម្ពស់សមត្ថភាពសមធម៌ យេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រី ជាពិសេសផ្តល់សិទ្ធិ តួនាទីក្នុងការធ្វើសេចក្តីសម្រេច នៅគ្រប់ផ្នែក នៃអភិបាលកិច្ច និងធ្វើឱ្យស្ត្រីទទួលបាននូវសេវាសាធារណៈផ្សេងៗ កាន់តែប្រសើរឡើង សេវាសាធារណៈទាំងនោះ គឺជាតម្រូវការរបស់ស្ត្រីដែលត្រូវបានឆ្លើយតប។ សកម្មភាពដែលលើកឡើង នៅក្នុងសមាសធាតុកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ គឺបង្កើនលទ្ធភាពដល់ស្ត្រី និងកុមារទទួលបាននូវការគ្រប់គ្រងធនធានអភិវឌ្ឍន៍ សម្រាប់លើកកម្ពស់ជីវភាពរស់នៅប្រចាំថ្ងៃ។ នៅក្នុងរដ្ឋបាលឃុំគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារត្រូវបានបង្កើតឡើង ដើម្បីជួយលើកកម្ពស់ស្ត្រី និងកុមារ និងដើរតួជាអ្នកតំណាងឱ្យក្រុមជនងាយរងគ្រោះផងដែរ។

ស្ថិតក្នុងការតាមដាននេះយើងក៏ឃើញមានការគម្លាតយេនឌ័រ ក្នុងការធ្វើសេចក្តីសម្រេច នៅមានកម្រិតកង្វះដៃគូអភិវឌ្ឍន៍ និងសង្គមស៊ីវិលដើម្បីគាំទ្រនូវសកម្មភាពយេនឌ័រការធ្វើអន្តោប្រវេសន៍ស្វែងរកការងារកាន់តែច្រើនពីជនបទទៅទីក្រុង និងទៅក្រៅប្រទេស ស្ត្រីជួបហានិភ័យច្រើនជាងបុរស ដូចជាអំពើហិង្សាខាងផ្លូវកាយ ផ្លូវចិត្ត ផ្លូវភេទ ផ្លូវសេដ្ឋកិច្ច និងការជួញដូរមនុស្ស។ល។

### ៣.២.៣. ស្ថានភាពនៃការគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន និងការប្រែប្រួលអាកាសធាតុ

- ការប្រើប្រាស់ដីធ្លី

ទន្ទឹមនឹងការសម្រេចបាននូវសមិទ្ធផលខាងលើនេះនៅមានបញ្ហាប្រឈមនៅក្នុងឃុំដូចជា៖ ការសាងសង់សំណង់ដោយគ្មានលិខិតអនុញ្ញាត នៅតែកើតមាន ហើយសំណង់មួយចំនួននៅតែលួចសាងសង់នៅលើដីសាធារណៈ។

❖ ធនធានធម្មជាតិ

ទោះជាយ៉ាងណាក៏ដោយឃុំស្វាយទាបមានសក្តានុពលធនធានធម្មជាតិខាងលើក្តី ក៏នៅជួបបញ្ហាប្រឈមដូចតទៅ៖ បញ្ហាប្រឈមលើ អូរ អាង កន្លែងខ្លះមានសភាពគោករាក់ជាងមុន កំណើនប្រជាជនកើនឡើង ដីចំណីអាងមួយចំនួន ត្រូវបានទន្រ្ទានយកធ្វើស្រែចំការ។

### ៣.២.៤. ស្ថានភាពនៃការគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ

អភិបាលកិច្ចល្អ គឺជាស្នូលនៃយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជាកំពុងអនុវត្តគោលនយោបាយ វិមជ្ឈការ និងវិសហមជ្ឈការ តាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ ដែលកើតចេញពីការបោះឆ្នោតជាសកល និងអសកល ដើម្បីបម្រើផលប្រយោជន៍ និងផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋក្នុងមូលដ្ឋាន ដែលអាចជាម្ចាស់ការលើការគ្រប់គ្រង ចាត់ចែងមុខងារ ធនធានរបស់ខ្លួន អាចសម្របសម្រួលសកម្មភាពនៃការផ្តល់សេវា និងការអភិវឌ្ឍផ្សេងៗទៀតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ក្នុងនោះដែរ ឃុំ មានស្ថាប័នពាក់ព័ន្ធ ជំនាញគ្រប់វិស័យនានា រួមមានប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ ជាស្ថាប័នជួយផ្តល់នូវកិច្ចសហការយ៉ាងល្អប្រសើរ។

ការងារគ្រប់គ្រងរដ្ឋបាលដែនដី៖ រដ្ឋបាលឃុំ មានហេដ្ឋារចនាសម្ព័ន្ធ និងរចនាសម្ព័ន្ធ ក្រុមប្រឹក្សាឃុំ មានសមាជិក ១១ រូប ស្រី ០៣ រូប និងស្មៀនឃុំ ០១ រូប មេភូមិ ១៤ រូប អនុភូមិ ១៤ រូប សមាជិកភូមិ ១៤ រូប អគាររដ្ឋបាលសាលាឃុំ មួយខ្នង។ ដំណើរការផ្តល់សេវា រដ្ឋបាលសាធារណៈរួមមាន៖ ការទទួល និងផ្សព្វផ្សាយរាល់ឯកសារលិខិតបទដ្ឋាននានា រដ្ឋបាលឃុំដែលបានចេញសេចក្តីសម្រេច ដីកា ការគ្រប់គ្រងស្ថិតិនិង ចុះបញ្ជីអត្រានុកូលដ្ឋាន ការឆ្លើយតប នឹងតម្រូវការរបស់ប្រជាពលរដ្ឋ ទទួលពាក្យបណ្តឹង និងដោះស្រាយសម្រុះសម្រួលទំនាស់ផ្សេងៗ រៀបចំសណ្តាប់ធ្នាប់របៀបរៀបរយសាធារណៈ រៀបចំគណៈកម្មការកែលម្អសោភ័ណ្ឌភាពរបស់ឃុំ និងរដ្ឋបាលផ្សេងៗគ្នា ដើម្បីជួយអភិវឌ្ឍន៍ឃុំ។

យ៉ាងណាមិញទោះបីឃុំមានហេដ្ឋារចនាសម្ព័ន្ធ និងរចនាសម្ព័ន្ធរដ្ឋបាលក៏ពិតមែន តែឃុំនៅមានចំណុចខ្វះខាតមួយចំនួន៖ សមត្ថភាពរបស់ក្រុមប្រឹក្សាឃុំនៅមានកម្រិត ការឆ្លើយតបនឹងតម្រូវការរបស់ប្រជាពលរដ្ឋពុំទាន់បានសមស្រប និងតម្រូវការជាក់ស្តែង ខ្វះព័ត៌មានត្រឡប់ និងការចូលរួមរបស់សហគមន៍នៅក្នុងកម្មវិធីផ្សេងៗការកំណត់ព្រំប្រទល់ ឃុំ ភូមិ មិនទាន់បានសិក្សាវាស់វែងរួចនៅឡើយ។

មួយវិញទៀតរដ្ឋបាលឃុំក៏បានខិតខំពុះពារការងារយ៉ាងណា ក៏នៅមានបញ្ហាប្រឈមដូចជា៖ អគារប៉ុស្តិ៍នគរបាលរដ្ឋបាលមានលក្ខណៈបណ្តោះអាសន្ន កម្លាំងសមត្ថកិច្ចមិនតុល្យភាពជាមួយចំនួនប្រជាពលរដ្ឋ បទល្មើសតិចតួចនៅតែកើតមាន កម្រិតយល់ដឹងរបស់ប្រជាពលរដ្ឋអំពីច្បាប់ក្រមព្រហ្មទណ្ឌ រដ្ឋប្បវេណី និងច្បាប់ចរាចរណ៍ផ្លូវគោក នៅមានកម្រិត មធ្យោបាយសម្រាប់អន្តរាគមន៍មិនគ្រប់គ្រាន់។

## ៣.៣. ដំណោះស្រាយ

### ៣.៣.១. ការពង្រឹងលើវិស័យសេដ្ឋកិច្ច

សម្រាប់រយៈពេល៥ឆ្នាំនៃអាណត្តិទី៤នេះ ក្រុមប្រឹក្សាឃុំ និងខិតខំធ្វើកិច្ចការសហប្រតិបត្តិការដោយជម្រុញលើកទឹកចិត្តអាជីវករ វិនិយោគគិន ក្នុងការបង្កើតមុខរបរថ្មីៗ ថែមទៀតជូនប្រជាពលរដ្ឋ ដើម្បីបង្កើនប្រាក់ចំណូល និងធ្វើឱ្យជីវភាពកាន់តែប្រសើរឡើង។ និងបង្កើនការបណ្តុះបណ្តាលមុខជំនាញវិជ្ជាជីវៈ បច្ចេកទេសកសិកម្ម ជូនប្រជាពលរដ្ឋ កែលម្អរចនាសម្ព័ន្ធជនបទឱ្យបានល្អប្រសើរ និងកែលម្អប្រព័ន្ធធារាសាស្ត្រគ្រប់ប្រភេទឱ្យល្អប្រសើរ ព្រមទាំងរៀបចំឱ្យមានបណ្តាញអគ្គិសនី ឱ្យបានគ្រប់ភូមិ ប្រព័ន្ធទឹកស្អាតបានគ្រប់ភូមិ តាមតម្រូវការរបស់ប្រជាពលរដ្ឋ។

### ៣.៣.២. ការពង្រឹងលើវិស័យសង្គមកិច្ច

ដើម្បីធ្វើការពង្រឹងលើវិស័យសង្គមកិច្ចដោយផ្តោតសំខាន់លើចំណុចមួយចំនួនដូចខាងក្រោម៖

**ក. វិស័យអប់រំ**

ដើម្បីឆ្លើយតបបញ្ហាប្រឈមខាងលើ វិស័យអប់រំមានយុទ្ធសាស្ត្រដូចជា៖

- ផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រ
- សាងសង់ និងជួសជុលអគារសិក្សា ឱ្យស្របតាមកំណើនរបស់សិស្ស
- បង្កើតគណៈកម្មការប្រមូលកុមារគ្រប់វ័យសិក្សាឱ្យចូលរៀនបាន១០០%
- និង ជម្រុញឱ្យសាលារៀន កែលម្អគុណភាពអប់រំ ស្របតាមគោលដៅអភិវឌ្ឍន៍នៃសហស្សវត្សរ៍។

**ខ. វិស័យសុខាភិបាល**

ដើម្បីចូលរួម លើកកម្ពស់សេវាសុខភាពឱ្យបានប្រសើរ អង្គភាព មានយុទ្ធសាស្ត្រ ដូចជា៖ ការបង្កើនការផ្សព្វផ្សាយអប់រំសុខភាពដល់ប្រជាពលរដ្ឋនៅតាមសហគមន៍ និងតំបន់ដាច់ស្រយាល អំពីសារៈសំខាន់នៃការមកទទួលយកសេវាសុខភាពនៅមន្ទីរពេទ្យ និងមណ្ឌលសុខភាព ជាពិសេសស្ត្រីមានផ្ទៃពោះ ស្ត្រីដែលទើបឆ្លងទន្លេរួច ឱ្យយល់ពីសារៈសំខាន់នៃការពិនិត្យសុខភាពមុន និងក្រោយពេលសម្រាលកុមារ និងជនងាយរងគ្រោះបានមកទទួលសេវាទៀងទាត់ ការចុះចាក់ថ្នាំបង្ការរៀងរាល់ខែនៅតាមភូមិ និងបង្កើនទិវាចុះ

ព្យាបាលជូនប្រជាពលរដ្ឋតាមភូមិដាច់ស្រយាល និងលើកកម្ពស់ការអប់រំសុខភាព ជម្ងឺឆ្លង និងមិនឆ្លង សម្រាប់នៅមូលដ្ឋាន ឱ្យបានច្រើនដង ក្នុង១ខែ និងជម្រុញការផ្តល់សេវាឱ្យបានល្អប្រសើរជូនប្រជាពលរដ្ឋ។

**គ. ស្ថានភាពយេនឌ័រ**

ដើម្បីជម្រុញការអភិវឌ្ឍផ្នែកយេនឌ័រឱ្យមានភាពប្រសើរឡើង ត្រូវបង្កើនការបណ្តុះបណ្តាលពង្រឹងសមត្ថភាពជនបង្គោលស្ត្រី កុមារ បានផ្សព្វផ្សាយច្បាប់អំពើហិង្សាក្នុងគ្រួសារ ការបញ្រ្ជាបយេនឌ័រ ពង្រឹងសមត្ថភាពស្ត្រី ក្នុងភាពជាអ្នកដឹកនាំ។

### ៣.៣.៣. ការពង្រឹងលើការគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន និងការប្រែប្រួលអាកាសធាតុ

ចំណុចផ្សេងៗដែលជាដំណោះស្រាយក្នុងឃុំស្វាយទាបមានដូចតទៅ៖

**ក. ការប្រើប្រាស់ដីធ្លី**

ដើម្បីពង្រឹងប្រព័ន្ធគ្រប់គ្រងប្រើប្រាស់ដីធ្លី និងការសាងសង់សំណង់នានា ការិយាល័យរៀបចំដែនដីនគរូបនីយកម្មសំណង់ និងភូមិបាល ឃុំបានសហការជាមួយសមត្ថកិច្ចពាក់ព័ន្ធទប់ស្កាត់ការចូលកាន់កាប់ដីរដ្ឋដោយខុសច្បាប់ និងបានអនុវត្តតាមលិខិតបទដ្ឋាននានាដែលក្រសួងប្រគល់ឱ្យ។

ស្ថានភាពនៃការប្រើប្រាស់ដីធ្លី គឺការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ និងមានប័ណ្ណកម្មសិទ្ធិ កត្តានេះហើយដែលប្រជាពលរដ្ឋ ពោលពុំសូវមានជម្លោះដីធ្លី ហើយប្រកបរបរកសិកម្មបានជួយកាត់បន្ថយភាពខ្វះខាតក្នុងគ្រួសារមានជីវភាពធូរធារ។

ដើម្បីដោះស្រាយបញ្ហាខាងលើ ឃុំពង្រឹងការផ្សព្វផ្សាយច្បាប់ភូមិបាល ឱ្យបានទូលំទូលាយ និងត្រួតពិនិត្យ ណែនាំឱ្យប្រជាពលរដ្ឋយល់ដឹងពីនីតិវិធី លិខិតបទដ្ឋាននានា ដែលទាក់ទងនិងកិច្ចការសាងសង់ បង្កើនការផ្តល់ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ និងវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុ។

**ខ. ធនធានធម្មជាតិ**

ឃុំស្វាយទាប ជាឃុំមួយស្ថិតនៅតំបន់ខ្ពង់រាប មានសក្តានុពលសំខាន់គឺ៖ ធនធានធម្មជាតិ តំបន់ក្បាលទឹក អូរ ព្រៃឈើ ដែលបម្រើឱ្យវិស័យកសិកម្ម ទេសចរណ៍ បរិស្ថាន ធ្វើឱ្យប្រជាពលរដ្ឋ រស់នៅប្រកបមុខរបរចិញ្ចឹមជីវិត និងមានផាសុកភាព។

យ៉ាងណាមិញឃុំ ស្វាយទាបពង្រឹងប្រព័ន្ធគ្រប់គ្រងប្រើប្រាស់ដីធ្លី ទប់ស្កាត់ការទន្ទ្រានយកដីខុសច្បាប់ផ្សព្វផ្សាយច្បាប់ភូមិបាល និងលិខិតបទដ្ឋានពាក់ព័ន្ធទៅនឹងការអភិរក្សធនធានធម្មជាតិ។ ចំណែកឯបរិស្ថានឆ្លើយតបទៅនឹងស្ថានភាពឃុំ ដែលប្រជាពលរដ្ឋក្នុងឃុំ មានការកើនឡើងផ្នែកជីវភាព ការបង្កើត និងការពង្រីកអាជីវកម្ម កាន់តែរីកចម្រើន ស្របតាមភាពជឿនលឿនទាំងការអភិវឌ្ឍ និងបច្ចេកវិទ្យាទំនើប។

ការដោះស្រាយដោយមើលឃើញពីបញ្ហា ដែលកើតឡើងនៅក្នុងឃុំ និងបញ្ហាមួយចំនួនទៀត ដែលនឹងកើតឡើងនៅពេលខាងមុខ មន្ត្រីបរិស្ថាន និងអាជ្ញាធរឃុំ បានសហការគ្នាដោយយកចិត្តទុកដាក់ចុះអប់រំផ្សព្វផ្សាយ ណែនាំជាប្រចាំដល់ប្រជាពលរដ្ឋឱ្យបានយល់ដឹងអំពីផលប៉ះពាល់នៃបរិស្ថានដោយរៀបចំបង្កើតឱ្យមានឡដុតសំរាម និងកន្លែងសម្រាប់ចាក់សម្រាម។

### ៣.៣.៤. ការពង្រឹងការគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ

ដើម្បីដោះស្រាយបញ្ហាប្រឈមខាងលើ និងចូលរួមចំណែកអភិវឌ្ឍន៍ តាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ ឃុំត្រូវតែរៀបចំធ្វើកំណែទម្រង់ផ្នែករដ្ឋបាលឱ្យបានសមស្របដូចជា៖

- ពង្រឹងអភិបាលកិច្ចល្អ
- ពង្រឹងប្រសិទ្ធភាពការងារ
- អភិវឌ្ឍន៍សមត្ថភាពក្រុមប្រឹក្សាឃុំ និង
- មន្ត្រីតាមរយៈការបើកវគ្គបណ្តុះបណ្តាលជំនាញនានា ដល់ក្រុមប្រឹក្សា មន្ត្រី និងបុគ្គលិកកែលម្អគុណភាព ក្នុងការផ្តល់សេវាសាធារណៈកែប្រែអាកប្បកិរិយា និងឥរិយាបថរបស់មន្ត្រី ស្នើសុំការជួយគាំទ្រ និងផ្តល់ ឧបករណ៍សម្ភារៈ សង្ហារិម សម្រាប់បម្រើការងារប្រចាំថ្ងៃបន្តវាស់វែងកំណត់ព្រំប្រទល់រដ្ឋបាលឃុំ ភូមិឱ្យបានច្បាស់លាស់ងាយស្រួលក្នុងការគ្រប់គ្រង។

ការងារសន្តិសុខ៖ ផ្នែកសន្តិសុខ គឺជាកត្តាសំខាន់មួយដែលរដ្ឋបាលឃុំ បានខិតខំប្រឹងប្រែង ធ្វើឱ្យប្រសើរនូវផ្នែកនេះដើម្បីជាទំនុកចិត្តដល់ប្រជាពលរដ្ឋទូទៅ វិនិយោគគិន និងភ្ញៀវទេសចរណ៍ ក្នុងនោះយើងមាន ប៉ុស្តិ៍រដ្ឋបាល ០១ កន្លែង មានកម្លាំង ០៦នាក់ ស្រី០នាក់។

មានការចូលរួមសហការយ៉ាងសកម្មពីអាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ប្រជាពលរដ្ឋ ព្រះសង្ឃ ក្នុងសកម្មភាពសង្គម ការថែរក្សាស្ថិរភាពនយោបាយ សន្តិសុខសណ្តាប់ធ្នាប់សាធារណៈ គឺជម្រុញការអនុវត្តផែនការលេខ ០៣១ សណន ចុះថ្ងៃទី ១៨ ខែតុលា ឆ្នាំ២០១២ របស់ក្រសួងមហាផ្ទៃ ស្តីពីការចាត់តាំងគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព ដោយបង្កើតឱ្យមានក្រុមប្រជាការពារ ចំនួន៤២ ក្រុម និងមានសមាជិកចំនួន ១៦៨នាក់ លក្ខណៈសម្បត្តិ០៩យ៉ាង របស់គោលនយោបាយភូមិ ឃុំមានសុវត្ថិភាព គឺ៖

1) គ្មានសកម្មភាពលួចឆក់ប្លន់គ្រប់ប្រភេទ
2) គ្មានការផលិត ការចែកចាយ និងប្រើប្រាស់គ្រឿងញៀនខុសច្បាប់
3) គ្មានអំពើអានាចារ ការជួញដូរស្ត្រី កុមារ និងអំពើហិង្សាក្នុងគ្រួសារ
4) គ្មានក្មេងទំនើង
5) គ្មានអាវុធខុសច្បាប់ និងបទល្មើសគ្រប់ប្រភេទ គ្មានល្បែងស៊ីសង

6) គ្មានគ្រោះថ្នាក់ចរាចរណ៍

7) គ្មានគ្រាប់មីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ

8) វិធានការទប់ស្កាត់គ្រប់គ្រង ឆ្លើយតប គ្រោះមហន្តរាយប្រកបដោយប្រសិទ្ធភាព និង

9) គ្មានកុងត្រូលជជុះ (គ្មានការត្រួតពិនិត្យខុសច្បាប់)។

ដើម្បីដោះស្រាយបញ្ហាប្រឈមនេះឃុំស្វាយទាប មានវិធានការចំពោះមុខគឺ សាងសង់អគារប៉ុស្តិ៍នគរបាលរដ្ឋបាលឱ្យត្រូវស្តង់ដា បន្ថែមកម្លាំងសមត្ថកិច្ច បណ្តុះបណ្តាលសមត្ថភាពដល់មន្ត្រីសមត្ថកិច្ច ស្នើសុំបន្ថែមមធ្យោបាយសម្រាប់ អន្តរាគមន៍ ផ្សព្វផ្សាយអំពីច្បាប់ក្រមព្រហ្មទណ្ឌ រដ្ឋប្បវេណី និងច្បាប់ចរាចរណ៍ផ្លូវគោកឱ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋ។

## ៣.៤. ចក្ខុវិស័យរបស់ឃុំ

នៅក្នុងអាណត្តិទី៤ របស់ក្រុមប្រឹក្សាឃុំស្វាយទាប ប្រជាពលរដ្ឋក្នុងឃុំត្រូវមានសុខុមាលភាពសង្គមល្អប្រសើរ ទាំងផ្នែកហេដ្ឋារចនាសម្ព័ន្ធ ហើយប្រជាពលរដ្ឋគ្រប់រូបមានជីវភាពធូរធារ រស់នៅក្នុងបរិស្ថានល្អ ទទួលបានចំណេះដឹង និងជំនាញ មានសេវាកម្មល្អប្រកបដោយសុខសន្តិភាព និងសុវត្ថិភាព មានការយល់អំពីកិច្ចអភិវឌ្ឍន៍មូលដ្ឋាន ជាពិសេសកាត់បន្ថយ អត្រាស្លាប់របស់មាតា និងទារក ការប្រឆាំងជម្ងឺឆ្លង និងជម្ងឺមិនឆ្លងផ្សេងៗ។ ហើយនារីគ្រប់រូបមានសិទ្ធិ និងតួនាទីក្នុងសង្គមប្រកបដោយសមភាព និងសមធម៌លើសពីនេះ ក្រុមជនងាយរងគ្រោះទទួលបាននូវការយកចិត្តទុកដាក់ និងការគាំទ្រនូវគ្រប់កម្មវិធី។[31]

### ៣.៤.១. គោលបំណងអភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ច

គោលបំណងអភិវឌ្ឍន៍ ផ្នែកសេដ្ឋកិច្ចនៅក្នុងរយៈពេលប្រាំឆ្នាំ (២០១៧-២០២២) របស់ ក្រុមប្រឹក្សាឃុំស្វាយទាប អាណត្តិទី៤នេះឃុំធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធនានាដូចជា៖ ការកែលម្អផ្លូវលំជនបទនានា ឱ្យមានភាពប្រសើរឡើងទូទាំងឃុំ ស្ពារប្រព័ន្ធធារាសាស្ត្រ ទំនប់ ប្រឡាយ អាងស្តុកទឹក ការបង្កើនការដាំដុះ ការផលិត និងការរកទីផ្សារលក់ផលិតផល ការតភ្ជាប់បណ្តាញអគ្គិសនីតាមបណ្តាភូមិ ក្នុងឃុំ សម្រាប់ប្រជាពលរដ្ឋប្រើប្រាស់ និងប្រកបអាជីវកម្មនានាដើម្បីបង្កើនសេដ្ឋកិច្ចក្នុងគ្រួសារ។

### ៣.៤.២. គោលបំណងអភិវឌ្ឍន៍ផ្នែកសង្គមកិច្ច

គោលបំណងអភិវឌ្ឍន៍ផ្នែកសង្គមកិច្ចរយៈពេលប្រាំឆ្នាំ (២០១៧-២០២២) ក្នុងអាណត្តិទី៤របស់ក្រុមប្រឹក្សាឃុំ ប្រជាពលរដ្ឋទទួលបាននូវសេវា សង្គមនានាដូចជា៖ ចំណេះដឹងមូលដ្ឋានក្នុងការលើកកម្ពស់សុខភាព

[31] គណៈកម្មាធិការកសាងផែនការ និងថវិកាឃុំ, *សៀវភៅផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ ២០១៧-២០២២ ឃុំស្វាយទាប ស្រុកចំការលើ ខេត្តកំពង់ចាម*, អនុម័តនៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៨។

មាតា និងទារក ការកាត់បន្ថយអត្រាអនក្ខរភាព ពង្រឹងសាលារៀនឆ្លងកាត់ ប្រជាពលរដ្ឋយល់ដឹងពីសារៈសំខាន់នៃការសិក្សារបស់កូន ជម្រុញការលើកកម្ពស់សមភាពយេនឌ័រ ទប់ស្កាត់បានអំពើហិង្សាក្នុងគ្រួសារ ទទួលបានសុវត្ថិភាពក្នុងការធ្វើចំណាកស្រុក ការរំលោភបំពានលើកម្លាំងពលកម្មកុមារត្រូវបានកាត់បន្ថយ។ បង្កើនការយល់ដឹងពីសុខភាពអនាម័យ នៅតាមសហគមន៍ជនបទ។

### ៣.៤.៣. គោលបំណងអភិវឌ្ឍន៍ផ្នែកគ្រប់គ្រងដីធ្លីធនធានធម្មជាតិ បរិស្ថានបម្រែបម្រួលអាកាសធាតុ និងគ្រោះមហន្តរាយ

នៅក្នុងអាណត្តិទី៤ ក្រុមប្រឹក្សាឃុំស្វាយទាប បានរៀបចំផែនការប្រើប្រាស់ដីធ្លីឱ្យបានសមស្របដូចជាដីសម្រាប់សាងសង់លំនៅដ្ឋានដីបង្កបង្កើនផលដីរបស់រដ្ឋ។ ការធានានិរន្តរភាព បរិស្ថានបានល្អទប់ស្កាត់រាល់ការបំផ្លាញធនធានធម្មជាតិបេតិកភណ្ឌជាតិទ្រព្យសម្បត្តិសាធារណៈរមណីយដ្ឋាននានា។ ត្រៀមជម្រុញ ស្បៀងសម្ភារៈបង្ការទុកជាមុនដើម្បីជួយសង្គ្រោះដល់ ប្រជាពលរដ្ឋដែលជួបប្រទះនឹងគ្រោះថ្នាក់ ឬ គ្រោះមហន្តរាយផ្សេងៗ និងការប្រែប្រួលអាកាសធាតុ។

### ៣.៤.៤. គោលបំណងអភិវឌ្ឍន៍ផ្នែករដ្ឋបាលសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ

រយៈពេលប្រាំឆ្នាំ (២០១៧-២០២២) អាណត្តិទី៤របស់ក្រុមប្រឹក្សាឃុំ បានពង្រឹងការងាររបស់ខ្លួន ក្នុងគោលដៅពង្រឹងបន្ថែមនូវស្ថិរភាព សន្តិសុខសណ្តាប់ធ្នាប់សង្គមជូនប្រជាពលរដ្ឋ ការផ្តល់សេវាសាធារណៈ ត្រូវបានកែលម្អ និងសម្របសម្រួលឱ្យមានភាពសាមញ្ញងាយស្រួល តាមរយៈការបែងចែកមុខងារតួនាទីភារកិច្ចដល់មន្ត្រីស្របតាមលក្ខខណ្ឌការងារដើម្បីឱ្យមានការអភិវឌ្ឍប្រកបដោយចីរភាពប្រសិទ្ធភាព ក្នុងការរួមចំណែកកាត់បន្ថយភាពក្រីក្រជូនប្រជាពលរដ្ឋ ព្រមទាំងផ្សព្វផ្សាយណែនាំចាត់តាំងអនុវត្តន៍គោលនយោបាយ ភូមិឃុំមានសុវត្ថិភាព ដើម្បីធានាឱ្យប្រជាពលរដ្ឋគ្រប់រូបរស់នៅប្រកបដោយភាពសុខសាន្ត។

# សេចក្តីសន្និដ្ឋាន

# សេចក្ដីសន្និដ្ឋាន

ក្រោយពីបានសិក្សាស្វែងយល់ និងធ្វើការស្រាវជ្រាវទៅលើប្រធានបទស្ដីពី «ការគ្រប់គ្រងរដ្ឋបាល ឃុំស្វាយទាប ស្រុកចំការលើ ខេត្តកំពង់ចាម» រួចមកនេះ ទើបខ្ញុំបាទអាចធ្វើការសន្និដ្ឋានទៅលើសកម្មភាពគ្រប់គ្រងរដ្ឋបាលរបស់ឃុំ ស្វាយទាប ពិតជាមានភាពល្អប្រសើរដោយបានអនុវត្តន៍ទៅតាមគោលនយោបាយនានារបស់រាជរដ្ឋាភិបាលដែលបានដាក់ចេញ។ យ៉ាងណាមិញសកម្មភាពនៃការគ្រប់គ្រងរដ្ឋបាលឃុំស្វាយទាបពិតជាបម្រើដល់ប្រជាពលរដ្ឋបានកក់ក្ដៅ គួរជាទីទុកចិត្តសម្រាប់ពលរដ្ឋនៅដែនសមត្ថកិច្ចរបស់ខ្លួន។ ជាពិសេសនោះរដ្ឋបាលឃុំបានអនុវត្តន៍គោលនយោបាយ វិមជ្ឈការក្នុងការគ្រប់គ្រងឃុំ សង្កាត់នៅតាមមូលដ្ឋានដែលជារដ្ឋបាលថ្នាក់ក្រោមជាតិមួយដ៏សំខាន់ដើម្បីជម្រុញ និងលើកទឹកចិត្តឱ្យប្រជាពលរដ្ឋបានចូលរួមក្នុងសកម្មភាពក្នុងការធ្វើសេចក្ដីសម្រេចចិត្តណាមួយដែលពាក់ព័ន្ធទៅនឹងការអភិវឌ្ឍឃុំ សង្កាត់របស់ខ្លួនដែលនេះជាដំណើរការជម្រុញឱ្យមានលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស និងគ្មានការប្រកាន់និន្នាការណាមួយនៅក្នុងមូលដ្ឋានភូមិ ឃុំ។

ផ្អែកទៅតាមការសិក្សាស្រាវជ្រាវទៅលើទ្រឹស្ដី និងការចុះទៅដល់ទីតាំងផ្ទាល់ក្នុងឃុំ ស្វាយទាប ស្រុកចំការលើ ខេត្តកំពង់ចាម ខ្ញុំបាទសង្កេតឃើញថានៅក្នុងមូលដ្ឋាននេះមានការរីកចម្រើនមានវឌ្ឍនភាព ហើយការអភិវឌ្ឍមានភាពជឿនលឿនពីមួយអាណត្តិទៅមួយអាណត្តិដែលជាសញ្ញាសបញ្ជាក់ឱ្យឃើញថា ការគ្រប់គ្រងរដ្ឋបាលឃុំតាមបែបវិមជ្ឈការពិតជាទទួលបានអត្ថប្រយោជន៍ សម្រាប់ប្រជាជនគួរជាទីពេញចិត្ត ហើយជាងនេះទៅទៀតការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់នេះក៏ជាមូលដ្ឋានគ្រឹះ ដើម្បីរួមចំណែកក្នុងការអភិវឌ្ឍប្រទេសជាតិឱ្យមានភាពរីកចម្រើន និងមានស្ថិរភាពផងដែរ។

ជាក់ស្ដែងនៅឃុំស្វាយទាបតាំងពីអាណត្តិទី១ មកដល់អាណត្តិទី៤នេះបានអភិវឌ្ឍន៍ខ្លួនយ៉ាងឆាប់រហ័សពីឃុំដែលមានការអភិវឌ្ឍតិចតួចប្រែក្លាយទៅជាឃុំមួយដែលមានការអភិវឌ្ឍ លើគ្រប់វិស័យមានដូចជាផ្លូវគមនាគមន៍ ប្រព័ន្ធធារាសាស្ត្រ បណ្ដាញអគ្គិសនី មន្ទីរពេទ្យ ទីផ្សារ សាលារៀន ដែលសុទ្ធសឹងតែជាសរសៃឈាមនៃការអភិវឌ្ឍមូលដ្ឋាននៃឃុំ។ មិនត្រឹមតែប៉ុណ្ណោះ ក្រោមការដឹកនាំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងអាណត្តិទី៤ យើងសង្កេតឃើញថា ក្រុមប្រឹក្សាឃុំ បានខិតខំប្រឹងប្រែងបំពេញការងាររបស់ខ្លួនយ៉ាងយកចិត្តទុកដាក់ក្នុងការបម្រើប្រជាពលរដ្ឋ តាមរយៈការផ្ដល់សេវាកម្មសាធារណៈផ្សេងៗព្រមទាំងធ្វើការដោះស្រាយរាល់បញ្ហាប្រឈមនឹងការលំបាកជូនដល់ប្រជាពលរដ្ឋបានយ៉ាងទាន់ពេលវេលា និងមានប្រសិទ្ធភាពដើម្បីឆ្លើយតបទៅនឹងសេចក្ដីត្រូវការរបស់ពលរដ្ឋដែលនេះបង្ហាញយ៉ាងច្បាស់ថាការទទួលខុសត្រូវរបស់អាជ្ញាធរឃុំ ក្នុងកិច្ចដំណើរការគ្រប់គ្រងឃុំឱ្យប្រព្រឹត្តទៅបានយ៉ាងរលូន។

សរុបសេចក្តីមក ដូចយើងបានដឹងរួចមកហើយថា ឃុំដែលស្ថិតនៅក្រោមការដឹកនាំតាមបែបវិមជ្ឈការ ដែលជារដ្ឋបាលថ្នាក់ក្រោមជាតិ ដែលនៅប្រកៀកកិតជិតជាប់ជាមួយប្រជាពលរដ្ឋដោយផ្ទាល់បំផុតហើយបាន អនុវត្តន៍នៃការគ្រប់គ្រងឃុំ សង្កាត់ ជាគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍនៅតាមមូលដ្ឋាន ឃុំ សង្កាត់នៃការរស់នៅរបស់ប្រជាពលរដ្ឋ។

ជាសខីភាពការគ្រប់គ្រងរដ្ឋបាលឃុំស្វាយទាប ស្រុកចំការលើ ខេត្តកំពង់ចាម ដែលដឹកនាំដោយក្រុម ប្រឹក្សាឃុំ ក្នុងអាណត្តិទី៤ ពិតជាមានលក្ខណៈល្អប្រសើរដែលសម្រេចនូវសមិទ្ធផលជាច្រើនសម្រាប់ការអភិវឌ្ឍ នៅក្នុងឃុំទាំងមូល និងបានដោះស្រាយបញ្ហាការលំបាកគ្រប់យ៉ាងបានឡើងល្អ។ ធ្វើឱ្យមានការពេញចិត្តពី សំណាក់ប្រជាពលរដ្ឋនៅក្នុងឃុំ និងពលរដ្ឋរស់នៅក្នុងភាពកក់ក្តៅដែលមន្ត្រីថ្នាក់ក្រោមជាតិបានអនុវត្តន៍ តាមអនុសាសន៍ និងគោលនយោបាយរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** អតីត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។

# អនុសាសន៍

# អនុសាសន៍

បន្ទាប់ពីឆ្លងកាត់តាមរយៈការសិក្សាស្រាវជ្រាវ និងការធ្វើសេចក្ដីសន្និដ្ឋានពាក់ព័ន្ធនឹងលទ្ធផលស្រាវជ្រាវទៅប្រធានបទ «ការគ្រប់គ្រងរដ្ឋបាលឃុំស្វាយទាប» រួចមក ខ្ញុំបាទយល់ឃើញថាមិនទាន់មានលក្ខណៈល្អប្រសើរគ្រប់ជ្រុងជ្រោយនៅឡើយទេ ដោយសារនៅមានភាពចន្លោះប្រហោងខុសឆ្គងចំណុចណាមួយមិនខាន ដែលរាជរដ្ឋាភិបាលគួរយកចិត្តទុកដាក់បន្ថែមទៀត ដើម្បីបំពេញនូវចំណុចខ្វះខាតទាំងនោះឱ្យបានគ្រប់ជ្រុងជ្រោយហើយខ្ញុំបាទ សូមធ្វើការចូលរួមចំណែកជាគំនិតយោបល់ខ្លះៗក្នុងការផ្ដល់ជាអនុសាសន៍មួយចំនួនពាក់ព័ន្ធនឹងការគ្រប់គ្រងរដ្ឋបាលឃុំស្វាយទាប ដូចខាងក្រោម៖

- រាជរដ្ឋាភិបាល គួរតែបង្កើតខ្ទង់ថវិកាអភិវឌ្ឍន៍ឃុំ សង្កាត់ឱ្យបានសមស្របទៅតាមតម្រូវការ ជាពិសេសគឺនៅមូលដ្ឋានឃុំ សង្កាត់ណាដែលក្រីក្រ និងដាច់ស្រយាលដើម្បីជម្រុញការអភិវឌ្ឍឱ្យបានឆាប់រហ័ស
- រាជរដ្ឋាភិបាលគួរតែបើកវគ្គបណ្ដុះបណ្ដាលដល់ក្រុមប្រឹក្សា និងបុគ្គលិកឃុំឱ្យបានច្រើនដងដើម្បីបង្កើនសមត្ថភាពការងារជាពិសេសផ្នែកបច្ចេកទេស
- រាជរដ្ឋាភិបាល គួរតែបង្កើនសមាសភាពមន្ត្រីរាជការឱ្យបានសមស្របទៅតាមទំហំឃុំ និងចំនួនប្រជាជនដើម្បីងាយស្រួលធ្វើការបានលឿនទាន់ពេលវេលា និងតម្រូវការរបស់ប្រជាពលរដ្ឋ
- ក្រុមប្រឹក្សាឃុំ សង្កាត់ គួរតែត្រួតពិនិត្យ និងវាយតម្លៃទៅលើការបំពេញការងាររបស់បុគ្គលិកឃុំ អំពីការសាកសួរព័ត៌មានផ្សេងៗ
- ក្រុមប្រឹក្សាឃុំ សង្កាត់ គួរតែចុះទៅជួបប្រជាពលរដ្ឋក្នុងមូលដ្ឋានឱ្យបានញឹកញាប់ដើម្បីដឹងសុខទុក្ខ និងតម្រូវការរបស់ប្រជាពលរដ្ឋ
- បន្ថែមលើនេះទៀតនោះប្រជាពលរដ្ឋនៅតាមមូលដ្ឋានគួរមានការយល់ដឹងខ្លះៗអំពីច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗព្រមទាំងត្រូវចេះតាមដានការធ្វើការងាររបស់មន្ត្រីថ្នាក់ឃុំ សង្កាត់ របស់ខ្លួនផងដែរ
- ក្រុមប្រឹក្សាឃុំ គួរតែមានរចនាសម្ព័ន្ធរៀបចំទុកដាក់ឯកសារនិងឯកសារពាក់ព័ន្ធការអភិវឌ្ឍឃុំចាប់ពីឆ្នាំចាស់ៗជាពិសេសឯកសាររបស់ឃុំដើម្បីធ្វើការវាស់វែងលើវឌ្ឍនភាពឃុំមួយអាណត្តិទៅមួយអាណត្តិផងដែរ។

# ឯកសារយោង

# ឯកសារយោង


## ១. លិខិតបទដ្ឋានគតិយុត្ត

- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់, លេខ នស/រកម/០៣០១/០៥, ចុះនៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១។
- ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់, លេខ នស/រកម/០៦០០/០២០, ចុះនៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៦។
- ប្រកាសស្តីពីការទទួលស្គាល់សមាសភាពប្រធានក្រុមប្រឹក្សាឃុំ មេឃុំ ជំទប់ និងសមាជិកក្រុមប្រឹក្សាឃុំ នៃឃុំស្វាយទាប ស្រុកចំការលើ ខេត្តកំពង់ចាម, លេខ ៧៦០៥ ប្រក, ចុះនៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ ២០១៧។

## ២. សៀវភៅ

- គណៈកម្មាធិការកសាងផែនការ និងថវិកាឃុំ. ២០១៨. "*សៀវភៅផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ ២០១៧-២០២២ ឃុំស្វាយទាប ស្រុកចំការលើ ខេត្តកំពង់ចាម*"។
- សាកលវិទ្យាល័យវេស្ទើន. "*ប្រព័ន្ធគ្រប់គ្រងរដ្ឋបាល*". ឆ្នាំសិក្សា ២០១០-២០១១។
- ក្រសួងមហាផ្ទៃ សាលាជាតិរដ្ឋបាលមូលដ្ឋាន. ២០២២. "*ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់*" ។
- គណៈកម្មាធិការជាតិដឹកនាំការងារកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ, *សេចក្តីណែនាំ ស្តីពីការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់,* រៀបចំដោយក្រុមការងារអន្តរក្រសួង ខែកក្កដា ឆ្នាំ២០០៧។

## ៣. របាយការណ៍

- របាយការណ៍ស្តីពីសមិទ្ធផលការងាររបស់ក្រុមប្រឹក្សាឃុំស្វាយទាបអាណត្តិទី៤ ខែមករា ឆ្នាំ ២០២២។

# ឧបសម្ព័ន្ធ

# **បញ្ជីឧបសម្ព័ន្ធ**

I. **ឧបសម្ព័ន្ធទី ១៖ លិខិតបទដ្ឋានគតិយុត្ត**

- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់, លេខ នស/រកម/០៣០១/០៥, ចុះនៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១។
- ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់, លេខ នស/រកម/០៦០០/០២០, ចុះនៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៦។
- ប្រកាសស្តីពីការទទួលស្គាល់សមាសភាពប្រធានក្រុមប្រឹក្សាឃុំ មេឃុំ ជំទប់ និងសមាជិកក្រុមប្រឹក្សាឃុំ នៃឃុំស្វាយទាប ស្រុកចំការលើ ខេត្តកំពង់ចាម, លេខ ៧៦០៥ ប្រក, ចុះនៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៧។

II. **ឧបសម្ព័ន្ធទី ២៖ សៀវភៅ**

- គណៈកម្មាធិការកសាងផែនការ និងថវិកាឃុំ. ២០១៨. "*សៀវភៅផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ ២០១៧-២០២២ ឃុំស្វាយទាប ស្រុកចំការលើ ខេត្តកំពង់ចាម*"។

III. **ឧបសម្ព័ន្ធទី ៣៖ របាយការណ៍**

- របាយការណ៍ស្តីពីសមិទ្ធផលការងាររបស់ក្រុមប្រឹក្សាឃុំស្វាយទាបអាណត្តិទី៤ ខែមករា ឆ្នាំ២០២២។

IV. **ឧបសម្ព័ន្ធទី៤៖ រូបភាព**

# ឧបសម្ព័ន្ធទី ១

## លិខិតបទដ្ឋានគតិយុត្ត

- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់, លេខ នស/រកម/០៣០១/០៥, ចុះនៅថ្ងៃទី១៩ ខែមីនា ឆ្នាំ ២០០១។

# ច្បាប់

## ស្តីពី

## ការគ្រប់គ្រងរដ្ឋបាល
## ឃុំ សង្កាត់

នស / រកម / ០៣០១ / ០៥

# ព្រះរាជក្រម

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាតិ វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី០៨ ខែ មីនា ឆ្នាំ ១៩៩៩ដែលប្រកាសឱ្យប្រើជាផ្លូវការនូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤នៃរដ្ឋធម្មនុញ្ញនៃ ព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែង តាំងរាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម /០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំ ពីសម្តេចនាយករដ្ឋមន្ត្រី និង ពីសហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ។

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គលើកទី ៥ នីតិកាលទី ២ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាមលើទំរង់ និង គតិនៃច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី០១ខែ កុម្ភៈ ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គលើក ទី៤ នីតិកាលទី ១ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញ ប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ តាមសេចក្តីសម្រេចលេខ ០៤១/ ០០៣ / ២០០១ កបធ.ច ចុះថ្ងៃទី ២៨ ខែ កុម្ភះ ឆ្នាំ ២០០១ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ : ៕

# ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលដៅកំណត់ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជាតាមនយោបាយវិមជ្ឈការ ។

**មាត្រា ២.-**

ឃុំ សង្កាត់ជានីតិបុគ្គល ។

**មាត្រា ៣.-**

ប្រព័ន្ធនៃអភិបាលកិច្ចមូលដ្ឋានត្រូវអនុវត្តនៅថ្នាក់ឃុំ សង្កាត់ ។

**មាត្រា ៤.-**

អំណាចដឹកនាំនិងគ្រប់គ្រងឃុំ សង្កាត់បានមកដោយការបោះឆ្នោតជាទូទៅ ជាសកល ដោយសេរី ត្រឹមត្រូវនិងយុត្តិធម៌ ដោយស្មើភាព ដោយចំពោះ ដោយសម្ងាត់ ក្នុងក្របខ័ណ្ឌនៃឃុំ សង្កាត់នីមួយៗ ។

**មាត្រា ៥.-**

ឃុំ សង្កាត់គ្រប់គ្រងកិច្ចការមូលដ្ឋានក្នុងដែនដីរបស់ខ្លួនដោយផ្អែកទៅតាមរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាសនិងលិខិតបទដ្ឋានពាក់ព័ន្ធ ។

អំណាចបញ្ញត្តិ អំណាចប្រតិបត្តិក្នុងការគ្រប់គ្រងមូលដ្ឋានត្រូវផ្តល់ឱ្យឃុំ សង្កាត់ ហើយអំណាចនេះត្រូវអនុវត្តស្របទៅតាមរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានពាក់ព័ន្ធ ។

**មាត្រា ៦.-**

ការបង្កើត ការលុបចោល ការកែប្រែព្រំប្រទល់និងការប្តូរឈ្មោះរបស់ឃុំ សង្កាត់ ក្នុងករណីមិនប៉ះពាល់ដល់ព្រំប្រទល់របស់ខេត្ត ក្រុងពាក់ព័ន្ធ ត្រូវសំរេចដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

ក្នុងករណីដែលមានការប៉ះពាល់ដល់ព្រំប្រទល់របស់ខេត្ត ក្រុងពាក់ព័ន្ធ ការបង្កើត ការលុបចោល ការកែប្រែព្រំប្រទល់និងការប្តូរឈ្មោះរបស់ឃុំ សង្កាត់ ត្រូវ៖/..

សំរេចដោយព្រះរាជក្រឹត្យតាមសំណើរបស់នាយករដ្ឋមន្ត្រី ផ្អែកលើសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ៧.-**

កាលបើមានផលវិបាកណាមួយកើតឡើង ក្រោយពេលដែលឃុំ សង្កាត់ ត្រូវបានបង្កើត លុបចោលឬកែសម្រួល រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញប្រកាសដើម្បីដោះស្រាយផលវិបាកនោះស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន ។

**មាត្រា ៨.-**

ឃុំ សង្កាត់ណាដែលមិនអាចដំណើរការរៀបចំបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់បានដោយករណីប្រធានសក្តិ រាជរដ្ឋាភិបាលត្រូវធ្វើសេចក្តីរាយការណ៍ជូនរដ្ឋសភា។

បន្ទាប់ពីបានរាយការណ៍ជូនរដ្ឋសភារួចហើយ រាជរដ្ឋាភិបាលត្រូវចាត់ឱ្យក្រសួងមហាផ្ទៃរៀបចំគ្រប់គ្រងឃុំ សង្កាត់ទាំងនោះជាបណ្តោះអាសន្ន ហើយការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ទាំងនោះនឹងត្រូវដំណើរការ នៅពេលស្ថានការណ៍ឃុំ សង្កាត់ទាំងនេះមានប្រក្រតីភាពឡើងវិញ ។

## ជំពូកទី ២
## ក្រុមប្រឹក្សាឃុំ សង្កាត់

**មាត្រា ៩.-**

ឃុំ សង្កាត់នីមួយៗត្រូវមានក្រុមប្រឹក្សាមួយហៅថាក្រុមប្រឹក្សាឃុំ សង្កាត់ ។

ក្រុមប្រឹក្សាឃុំ សង្កាត់ជាអង្គការតំណាងប្រជាពលរដ្ឋក្នុងឃុំ សង្កាត់របស់ខ្លួន និងមានបេសកកម្មបំរើផលប្រយោជន៍ទូទៅក្នុងឃុំ សង្កាត់របស់ខ្លួន ។

**មាត្រា ១០.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវជ្រើសរើសឡើងតាមការបោះឆ្នោត ដោយប្រជាពលរដ្ឋនៃឃុំ សង្កាត់របស់ខ្លួនស្របទៅតាមនីតិវិធីដែលកំណត់ដោយច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។ល។

មាត្រា ១១.-

ក្រុមប្រឹក្សាឃុំ សង្កាត់មានអាណត្តិ ៥ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលដែលមានក្រុមប្រឹក្សាឃុំ សង្កាត់ថ្មីចូលកាន់តំណែង ។

ក្នុងតំណាក់កាលអន្តរកាលនេះ ក្រុមប្រឹក្សាឃុំ សង្កាត់ដែលផុតអាណត្តិមានភារកិច្ចសំរួលកិច្ចការប្រចាំថ្ងៃតែប៉ុណ្ណោះ ។

មាត្រា ១២.-

ក្រុមប្រឹក្សាឃុំ សង្កាត់មានសមាជិកចំនួនពី ៥ ទៅ ១១រូប ផ្អែកតាមប្រជាសាស្ត្រនិងភូមិសាស្ត្ររបស់ខ្លួន ។

ចំនួនជាក់ស្តែងនៃសមាជិកក្រុមប្រឹក្សាតាមឃុំ សង្កាត់នីមួយៗត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

ចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានកំណត់រួចហើយ អាចធ្វើការផ្លាស់ប្តូរបានដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អាស្រ័យដោយការផ្លាស់ប្តូរនៃប្រជាសាស្ត្រនិងភូមិសាស្ត្រ ។

សមាជិកបន្ថែមនៃក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវជ្រើសរើសតាមនីតិវិធីដូចសមាជិកដទៃទៀតដែរ ។

មាត្រា ១៣.-

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវមានប្រធានម្នាក់ហៅថាប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ។

ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់មានភារកិច្ច :

- ធ្វើជាអធិបតីក្នុងសម័យប្រជុំនានារបស់ក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន
- ធានាឱ្យមានកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ យ៉ាងតិចឱ្យបានមួយដងក្នុងមួយខែ
- ធានាឱ្យសម័យប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួនដំណើរការបានត្រឹមត្រូវទៅតាមវិធាននិងបទបញ្ញាដូចបានចែងក្នុងបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាឃុំ សង្កាត់ និងបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា២៣ នៃច្បាប់នេះ
- រក្សារបៀបរៀបរយនិងសណ្តាប់ធ្នាប់ក្នុងពេលប្រជុំ ។ល។

មាត្រា ១៤.-

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានសិទ្ធិនិងមានបំណងឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបំពេញល័ក្ខខ័ណ្ឌសំខាន់ៗដូចខាងក្រោម :

- មានសញ្ជាតិខ្មែរពីកំណើត
- ចេះអាននិងសរសេរអក្សរខ្មែរ
- បានចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតក្នុងឃុំ សង្កាត់ដែលខ្លួនមានបំណងឈរឈ្មោះ
- មានអាយុយ៉ាងតិច ២៥ឆ្នាំ គិតមកទល់ថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- មានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមល័ក្ខខ័ណ្ឌដែលកំណត់ដោយច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។

មាត្រា ១៥.-

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានបោះឆ្នោតជ្រើសរើសឡើងទៅតាមប្រព័ន្ធសមាមាត្រ ។

មាត្រា ១៦.-

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបាត់បង់សមាជិកភាពរបស់ខ្លួនទៅតាមករណីណាមួយក្នុងចំណោមករណីដូចខាងក្រោម :

- សាមីខ្លួនទទួលមរណភាព
- សាមីខ្លួនបាត់បង់សម្បទាវិជ្ជាជីវៈដោយមានលិខិតបញ្ជាក់ពីក្រសួងស្ថាប័នមានសមត្ថកិច្ច
- សាមីខ្លួនសុំលាលែងជាលាយលក្ខណ៍អក្សរពីសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់
- សាមីខ្លួនត្រូវតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬមជ្ឈឹមណាមួយ
- សមាជិកត្រូវបានបណ្តេញចេញដោយប្រព្រឹត្តផ្ទុយនឹងបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាឃុំ សង្កាត់ តាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា ៨៤នៃច្បាប់នេះ ។

- ក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូលត្រូវរំសាយ

- សាមីខ្លួនបាត់បង់សមាជិកភាពពីគណបក្សនយោបាយរបស់ខ្លួន ។

កាលបើសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ណាមួយត្រូវបាត់បង់សមាជិកភាព ត្រូវជ្រើសរើសបេក្ខជនដែលមានឈ្មោះបន្ទាប់តាមលេខរៀងក្នុងបញ្ជីបេក្ខជនជាមួយមកជំនួសដោយមិនបាច់បោះឆ្នោតឡើងវិញឡើយ ។

**មាត្រា ១៧.-**

ត្រូវរៀបចំធ្វើការបោះឆ្នោតឡើងវិញក្នុងរយៈពេល ១២០ថ្ងៃយ៉ាងយូរ ដើម្បីធ្វើការជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងករណីណាមួយដូចខាងក្រោម :

- ឃុំ សង្កាត់ដែលបង្កើតថ្មីតាមល័ក្ខខ័ណ្ឌដែលបានចែងក្នុងមាត្រា ៦ នៃច្បាប់នេះ

- ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវរំសាយចោលតាមល័ក្ខខ័ណ្ឌដែលបានចែងក្នុងមាត្រា ៥៧ និងមាត្រា ៥៨ នៃច្បាប់នេះ ។

ការបោះឆ្នោតឡើងវិញដូចមានចែងខាងលើនេះត្រូវចាត់ចែងធ្វើឡើង អនុលោមទៅតាមបែបបទនិងនីតិវិធីដែលបានចែងក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។

ក្រុមប្រឹក្សាឃុំ សង្កាត់ដែលកើតឡើងដោយការបោះឆ្នោតឡើងវិញខាងលើនេះ មានអាណត្តិស្មើនឹងអាណត្តិដែលនៅសល់របស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

ការបោះឆ្នោតឡើងវិញមិនត្រូវអនុញ្ញាតឱ្យធ្វើឡើយ ប្រសិនបើអាណត្តិដែលនៅសល់របស់ក្រុមប្រឹក្សាឃុំ សង្កាត់ មានរយៈពេលមិនលើសពី ១៨០ថ្ងៃ ។

ក្នុងរយៈពេលនេះ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវតែងតាំងសមាសភាពនិងកំណត់អំពីសមត្ថកិច្ច របៀបរបបដឹកនាំគ្រប់គ្រងឃុំ សង្កាត់នោះ រហូតដល់មានការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នាអាណត្តិបន្ទាប់ ។

**មាត្រា ១៨.-**

ការកែប្រែព្រំប្រទល់របស់ឃុំ សង្កាត់ណាមួយអាចប្រព្រឹត្តបានតែក្នុងករណីដែលការកែប្រែនោះ ពុំបណ្តាលឱ្យផ្លាស់ប្តូរដល់ចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានជាប់ឆ្នោត ។

ការបង្កើតឃុំ សង្កាត់ថ្មីណាមួយអាចប្រព្រឹត្តបានតែក្នុងករណីដែលការបង្កើតនោះពុំបណ្តាលឱ្យមានផ្លាស់ប្តូរដល់ចំនួនសមាជិកក្រុមប្រឹក្សានៃឃុំ សង្កាត់ដែលពាក់ព័ន្ធ ។

ក្នុងករណីឃុំ សង្កាត់ដែលត្រូវបង្កើតថ្មី ដែលត្រូវលុបចោល ដែលត្រូវកែប្រែព្រំប្រទល់ ហើយបណ្តាលឱ្យមានការផ្លាស់ប្តូរដល់ចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានជាប់ឆ្នោត ការបង្កើត ការលុបចោល ការកែប្រែព្រំប្រទល់ ត្រូវចូលជាធរមានសំរាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ នាអាណត្តិបន្ទាប់ ។

**មាត្រា ១៩.-**

ក្នុងអំឡុងពេល ១៤ថ្ងៃ ក្រោយពីការប្រកាសលទ្ធផលជាផ្លូវការនៃការបោះឆ្នោត ត្រូវចាត់ឱ្យមានការប្រជុំជាលើកដំបូងនៃក្រុមប្រឹក្សាឃុំ សង្កាត់ ក្រោមអធិបតីភាពមន្ត្រីម្នាក់ដែលចាត់តាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីប្រកាសសុពលភាពសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់និងប្រកាសឈ្មោះប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ ជំទប់និងចៅសង្កាត់រង ។

**មាត្រា ២០.-**

មុនចាប់ផ្តើមការងារ ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗត្រូវរៀបចំនិងអនុម័តបទបញ្ជាផ្ទៃក្នុងដើម្បីកំណត់នូវវិធានទាំងឡាយសំរាប់អង្គប្រជុំនិងរបៀបរបបធ្វើការងាររបស់ខ្លួន ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញសេចក្តីណែនាំអំពីគោលការណ៍នានាសំរាប់ជាមូលដ្ឋានដល់ការរៀបចំបទបញ្ជាផ្ទៃក្នុងខាងលើនេះ ។

**មាត្រា ២១.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើការប្រជុំយ៉ាងតិចណាស់ចំនួនមួយដងក្នុងមួយខែ ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវប្រជុំក្នុងសាលាឃុំ ឬសាលាសង្កាត់របស់ខ្លួន ឬក្នុងករណីចាំបាច់អធិបតីនៃអង្គប្រជុំអាចជ្រើសយកទីកន្លែងណាមួយក្នុងឃុំ សង្កាត់របស់ខ្លួនដើម្បីប្រជុំ ។ល។

មាត្រា ២២.-

ការប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ នឹងយកជាការ បាន លុះត្រាតែមានចំនួនលើស ពីពាក់កណ្តាលនៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូលចូលរួម ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើការបោះឆ្នោតអនុម័តដោយសម្លេងភាគច្រើនដាច់ខាតនៃសមាជិកក្រុមប្រឹក្សាទាំងមូល ដើម្បីសំរេចបញ្ហាណាមួយដូចខាងក្រោម :

- អនុម័តលើគំរោងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់
- អនុម័តលើគំរោងថវិកាឃុំ សង្កាត់
- កំណត់តម្លៃសារពើពន្ធមូលដ្ឋាន មិនមែនសារពើពន្ធមូលដ្ឋាននិងកំរៃសេវាផ្សេងៗ
- អនុម័តបទបញ្ជាផ្ទៃក្នុងនិងដីកាឃុំ សង្កាត់
- កិច្ចការផ្សេងៗទៀតដែលកំណត់ដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

ក្នុងពេលអនុម័ត ប្រសិនបើមានសំឡេងឆ្នោតស្មើគ្នា សម្លេងរបស់អធិបតីនៃអង្គប្រជុំមានឧត្តមានុភាព ។

មាត្រា ២៣.-

ការប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវធ្វើជាសាធារណៈនិងមានលក្ខណៈប្រជាធិបតេយ្យ ។

ក្រុមប្រឹក្សាឃុំ សង្កាត់អាចប្រជុំជាសម្ងាត់បាន ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញសេចក្តីណែនាំអំពីរបៀបរបបប្រជុំខាងលើនេះ ។

មាត្រា ២៤.-

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ មានសេរីភាពក្នុងការបញ្ចេញមតិក្នុងអង្គប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ ។

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់រូបណាក៏ដោយ មិនអាចត្រូវបានចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួនដោយហេតុពីបានសំដែងយោបល់ ឬបញ្ចេញមតិក្នុងអង្គប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់បានឡើយ ។ ន.ក.

## ជំពូកទី ៣
## រចនាសម្ព័ន្ធរដ្ឋបាលឃុំ សង្កាត់

**មាត្រា ២៥.-**

រដ្ឋបាលឃុំ សង្កាត់ត្រូវដឹកនាំគ្រប់គ្រងដោយក្រុមប្រឹក្សាឃុំ សង្កាត់ ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវមានប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ។

ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ជាមេឃុំ ចៅសង្កាត់ ។

**មាត្រា ២៦.-**

មេឃុំ ចៅសង្កាត់មានអ្នកជំនួយការដូចខាងក្រោម :

ចំពោះមេឃុំ អ្នកជំនួយការមានពីររូប :

-ជំទប់ទី ១ មួយរូប

-ជំទប់ទី ២ មួយរូប ។

ចំពោះចៅសង្កាត់ អ្នកជំនួយការមានពីររូប :

-ចៅសង្កាត់រងទី ១ មួយរូប

-ចៅសង្កាត់រងទី ២ មួយរូប ។

**មាត្រា ២៧.-**

មេឃុំ ចៅសង្កាត់មានសិទ្ធិចាត់តាំងគណៈកម្មាធិការនានាដើម្បីផ្តល់យោបល់ និងជួយកិច្ចការនានាតាមការចាំបាច់ ។

គណៈកម្មាធិការខាងលើនេះអាចយកសមាជិកណាម្នាក់ក្នុងក្រុមប្រឹក្សាឃុំ សង្កាត់ឱ្យធ្វើជាប្រធានក៏បាន ឬអាចយកប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតណាម្នាក់ក្នុងឃុំ សង្កាត់របស់ខ្លួន ក្រៅពីសមាជិកក្រុមប្រឹក្សាឱ្យធ្វើជាប្រធានក៏បាន ។

**មាត្រា ២៨.-**

ឃុំ សង្កាត់ត្រូវមានបុគ្គលិកក្របខ័ណ្ឌរដ្ឋបាលនៃក្រសួងមហាផ្ទៃមួយរូបធ្វើជាស្មៀនឃុំ សង្កាត់ ។

ស្មៀនឃុំ សង្កាត់តែងតាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃដែលមានភារកិច្ចជួយកិច្ចការឃុំ សង្កាត់ និងធានានិរន្តរភាពកិច្ចការរដ្ឋបាលក្នុងឃុំ សង្កាត់ ។ល។

ស្មៀនឃុំ សង្កាត់ត្រូវផ្លាស់ប្ដូរក្នុងករណីមានសំណើរបស់មេឃុំ ចៅសង្កាត់ អនុលោមតាមការសំរេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

**មាត្រា ២៩.-**

ឃុំ សង្កាត់អាចជ្រើសរើសបុគ្គលិកក្រៅក្របខ័ណ្ឌរដ្ឋដើម្បីជួយកិច្ចការរបស់ខ្លួន តាមសេចក្ដីត្រូវការនិងការចាំបាច់នៃការងារនិងតាមសេចក្ដីសំរេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងអាណត្តិ ហើយអាចបន្តការងារតាមការសំរេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិបន្ទាប់ ។

**មាត្រា ៣០.-**

ក្នុងគោលដៅលើកកំពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗត្រូវរៀបចំជ្រើសរើសឱ្យមានមេភូមិម្នាក់ សំរាប់ភូមិនីមួយៗ ចំណុះឃុំ សង្កាត់របស់ខ្លួន ។

មេភូមិត្រូវរៀបចំតាត់តាំងឱ្យមានអនុប្រធានមួយរូបនិងសមាជិកមួយរូបជាជំនួយការ ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញសេចក្ដីណែនាំអំពីបែបបទនីតិវិធីនៃការជ្រើសរើសមេភូមិ ការចូលកាន់តំណែង ការផ្លាស់ប្ដូរមេភូមិនិងការតែងតាំងជំនួយការមេភូមិ ។

**មាត្រា ៣១.-**

មេភូមិមានភារកិច្ច :

- អនុវត្តនូវភារកិច្ចដែលក្រុមប្រឹក្សាឃុំ សង្កាត់ ឬមេឃុំ ចៅសង្កាត់ប្រគល់ឱ្យដើម្បីធានាសន្តិសុខ សណ្ដាប់ធ្នាប់សាធារណៈ និងអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមក្នុងភូមិ
- ផ្ដល់យោបល់ដល់ក្រុមប្រឹក្សាឃុំ សង្កាត់អំពីបញ្ហានានាដែលទាក់ទងដល់ផលប្រយោជន៍ក្នុងភូមិរបស់ខ្លួន
- ស្នើសុំយោបល់ទៅក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ដើម្បីចាត់ចែងនិងសម្របសម្រួលកិច្ចការនៅក្នុងភូមិរបស់ខ្លួន ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញសេចក្ដីណែនាំបន្ថែមអំពីរបៀបរបបធ្វើការងារនិងភារកិច្ចរបស់ភូមិ ឱ្យបានសមស្រប ។ល។

មាត្រា ៣២.-

ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់ត្រូវជ្រើសរើសចេញពីបេក្ខជនលេខរៀងលើគេបង្អស់នៃបញ្ជីបេក្ខជនដែលបានទទួលសម្លេងឆ្នោតច្រើនជាងគេបង្អស់ ។

ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់មានអាណត្តិស្មើនឹងអាណត្តិរបស់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ។

មាត្រា ៣៣.-

ជំទប់ទី ១ ចៅសង្កាត់រងទី ១ ត្រូវជ្រើសរើសចេញពីបេក្ខជនដែលមានឈ្មោះលេខរៀងលើគេនៃបញ្ជីបេក្ខជនដែលបានទទួលសម្លេងឆ្នោតលំដាប់ទី ២ ។

ជំទប់ទី ២ ចៅសង្កាត់រងទី ២ ត្រូវជ្រើសរើសចេញពីបេក្ខជនដែលមានឈ្មោះលេខរៀងលើគេនៃបញ្ជីបេក្ខជនដែលបានទទួលសម្លេងឆ្នោតលំដាប់ទី ៣ ។

មាត្រា ៣៤.-

ក្នុងករណីដែលលទ្ធផលជាផ្លូវការនៃការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ណាបានផ្តល់សម្លេងគាំទ្រដល់បញ្ជីបេក្ខជនតែមួយដែលមានលក្ខណៈសម្បត្តិទទួលបានអាសនៈទាំងអស់ក្នុងក្រុមប្រឹក្សា ត្រូវជ្រើសរើសសមាជិកក្រុមប្រឹក្សាពីក្នុងបញ្ជីតែមួយនោះឱ្យទទួលតំណែងជាមេឃុំ ឬចៅសង្កាត់ ជំទប់ទី ១ ឬចៅសង្កាត់រងទី ១ ជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ។

មាត្រា ៣៥.-

ក្នុងករណីដែលលទ្ធផលជាផ្លូវការនៃការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ណាបានផ្តល់សម្លេងគាំទ្រដល់បញ្ជីបេក្ខជនតែពីរដែលមានលក្ខណៈសម្បត្តិទទួលបានអាសនៈក្នុងក្រុមប្រឹក្សា ត្រូវជ្រើសរើសសមាជិកក្រុមប្រឹក្សាជាបេក្ខជន ដែលមានឈ្មោះលេខរៀងបន្ទាប់ពីបេក្ខជនដែលមានឈ្មោះលេខរៀងលំដាប់លើគេបង្អស់នៃបញ្ជីដែលបានទទួលសម្លេងឆ្នោតគាំទ្រលំដាប់ទីមួយ ឱ្យទទួលតំណែងជាជំទប់ទី ១ ឬចៅសង្កាត់រងទី ១ និងជ្រើសរើសយកសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ជាបេក្ខជនដែលមានឈ្មោះលេខរៀងលើគេបង្អស់ នៃបញ្ជីដែលបានទទួលសម្លេងគាំទ្រលំដាប់ទី ២ ឱ្យទទួលតំណែងជាជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ។ ស.ក.

**មាត្រា ៣៦.-**

តំណែងប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់ត្រូវបាត់បង់ក្នុងករណីសាមីខ្លួនបាត់បង់សមាជិកភាពក្រុមប្រឹក្សាឃុំ សង្កាត់តាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងវាក្យខ័ណ្ឌទី ១ មាត្រា ១៦នៃច្បាប់នេះ ។

**មាត្រា ៣៧.-**

មុខតំណែងប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ មុខតំណែងមេឃុំ ចៅសង្កាត់និងមុខតំណែងជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ កាលបើមុខតំណែងណាមួយត្រូវបាត់បង់ មុខតំណែងទាំងអស់ខាងលើរបស់ជននោះក៏ត្រូវបានបាត់បង់ព្រមពេលជាមួយគ្នាដែរ ។

ក្នុងករណីខាងលើនេះ ត្រូវជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលមានឈ្មោះតាមលេខរៀងបន្ទាប់នៅក្នុងបញ្ជីរួមជាមួយអតីតប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់ ដែលបានបាត់បង់ពីមុខតំណែងនោះ ឱ្យទទួលបន្តតំណែងប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់និងត្រូវជ្រើសរើសសមាជិកក្រុមប្រឹក្សាថ្មី ជំនួសកន្លែងដែលទំនេរតាមល័ក្ខខ័ណ្ឌដែលបានចែងក្នុងវាក្យខ័ណ្ឌទី ២ មាត្រា ១៦នៃច្បាប់នេះ ។

ក្នុងករណីដែលបញ្ជីបេក្ខជនត្រូវកាន់កាប់តំណែងប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់អស់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ចេញពីក្នុងបញ្ជីបេក្ខជនជាមួយ ផ្សេងៗតាមល័ក្ខខ័ណ្ឌដែលបានចែងក្នុងវាក្យខ័ណ្ឌទី ២ មាត្រា ១៦ នៃច្បាប់នេះនិងចាត់ឱ្យសមាជិកក្រុមប្រឹក្សារូបនេះទទួលបន្តតំណែងប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់ជំនួសប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់ដែលបានបាត់បង់ពីមុខតំណែង ។

ផ្អែកតាមល័ក្ខខ័ណ្ឌខាងលើនេះ ការបាត់បង់ពីមុខតំណែងនិងការទទួលតំណែងប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់ត្រូវធ្វើដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃក្នុងរយៈពេលយ៉ាងយូរ ១៤ថ្ងៃ ។

**មាត្រា ៣៨.-**

តំណែងជាជំទប់ទី ១ ឬចៅសង្កាត់រងទី ១ តំណែងជាជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ត្រូវបាត់បង់ពីមុខតំណែង ក្នុងករណីដែលសាមីខ្លួនបាត់បង់សមាជិកភាពក្រុមប្រឹក្សាឃុំ សង្កាត់តាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងវាក្យខ័ណ្ឌទី ១ មាត្រា ១៦នៃច្បាប់នេះ ។ល។

ក្នុងករណីតំណែងជាជំទប់ទី ១ ឬចៅសង្កាត់រងទី ១ តំណែងជាជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ត្រូវបានបាត់បង់ មុខតំណែងជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់របស់ជននោះក៏ត្រូវបានបាត់បង់ព្រមពេលជាមួយគ្នាដែរ ។

ក្នុងករណីខាងលើនេះ ត្រូវជ្រើសរើសយកសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ជាបេក្ខជនដែលមានឈ្មោះតាមលេខរៀងបន្ទាប់នៃបញ្ជីបេក្ខជនរួមជាមួយជំទប់ទី ១ ឬចៅសង្កាត់រងទី ១ ជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ឱ្យទទួលតំណែងជំនួសជំទប់ ឬចៅសង្កាត់រងដែលបានបាត់បង់ពីមុខតំណែងនិងត្រូវជ្រើសរើសសមាជិកក្រុមប្រឹក្សាថ្មីជំនួសកន្លែងដែលទំនេរ តាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងវាក្យខ័ណ្ឌទី ២ មាត្រា ១៦នៃច្បាប់នេះ ។

ក្នុងករណីបញ្ជីបេក្ខជនដែលត្រូវកាន់កាប់តំណែងជាជំទប់ទី ១ ឬចៅសង្កាត់រងទី ១ ជំទប់ទី ២ ឬចៅសង្កាត់រងទី ២ អស់សមាជិកក្នុងក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវជ្រើសរើសបេក្ខជនពីក្នុងបញ្ជីនោះបញ្ចូលជាសមាជិកក្នុងក្រុមប្រឹក្សាឃុំ សង្កាត់ ទៅតាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងវាក្យខ័ណ្ឌទី ២ មាត្រា ១៦នៃច្បាប់នេះ នឹងប្រគល់ឱ្យសមាជិកក្រុមប្រឹក្សារូបនោះទទួលតំណែងជាជំទប់ទី ១ ឬចៅសង្កាត់រងទី ១ ជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ជំនួសតំណែងជំទប់ទី ១ ឬចៅសង្កាត់រងទី ១ ជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ដែលបានបាត់បង់ពីមុខតំណែង ។

ផ្អែកតាមល័ក្ខខ័ណ្ឌខាងលើនេះនិងល័ក្ខខ័ណ្ឌដែលបានចែងក្នុងមាត្រា ៣៣ នៃច្បាប់នេះ ការបាត់បង់មុខតំណែងនិងការទទួលតំណែងជាជំទប់ទី ១ ឬចៅសង្កាត់រងទី ១ ជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ត្រូវធ្វើដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃក្នុងរយៈពេលយ៉ាងយូរ ១៤ថ្ងៃ ។

**មាត្រា ៣៩.-**

មេឃុំ ចៅសង្កាត់បំពេញតួនាទីភារកិច្ចដូចខាងក្រោម :

- អនុវត្តសេចក្តីសំរេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់
- អនុវត្តនូវបទប្បញ្ញត្តិនិងគោលការណ៍នានាដែលបានទទួលពីក្រុមប្រឹក្សាឃុំ សង្កាត់
- ធ្វើសេចក្តីរាយការណ៍អំពីសកម្មភាពការងារជូនក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួនយ៉ាងតិចឱ្យបានមួយដងក្នុងមួយខែ
- ផ្តល់យោបល់ផ្សេងៗនិងជួយដល់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការរៀបចំផែនការហិរញ្ញវត្ថុនិងក្នុងការចាត់ចែងអនុវត្តនូវតួនាទី មុខងារ សិទ្ធិអំណាចរបស់ក្រុម

ប្រឹក្សាឃុំ សង្កាត់ ព្រមទាំងកិច្ចការផ្សេងទៀតដែលក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួនប្រគល់ឱ្យ ។

មាត្រា ៤០.-

ជំទប់ ឬចៅសង្កាត់រងជាជំនួយការរបស់មេឃុំ ចៅសង្កាត់ក្នុងការអនុវត្តភារកិច្ច ដែលមេឃុំ ចៅសង្កាត់ប្រគល់ឱ្យនិងជំនួសមេឃុំ ចៅសង្កាត់ទៅតាមឋានានុក្រមនៃជំទប់ ចៅសង្កាត់រង នៅពេលដែលមេឃុំ ចៅសង្កាត់អវត្តមាន ។

ជំទប់ ឬចៅសង្កាត់រង ត្រូវធ្វើការបែងចែកភារកិច្ចដូចខាងក្រោម :

ជំទប់ទី ១ ឬចៅសង្កាត់រងទី ១ ទទួលជួយមេឃុំ ចៅសង្កាត់លើកិច្ចការសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

ជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ទទួលជួយមេឃុំ ចៅសង្កាត់លើកិច្ចការរដ្ឋបាល សង្គមកិច្ច សេវាសាធារណៈនិងសណ្តាប់ធ្នាប់សាធារណៈ ។

មេឃុំ ចៅសង្កាត់អាចប្រគល់ភារកិច្ចបន្ថែមពីលើភារកិច្ចដែលបានបែងចែកខាងលើនេះដល់ជំទប់ ឬចៅសង្កាត់រងរបស់ខ្លួន ។

## ជំពូកទី ៤
## តួនាទី មុខងារនិងអំណាចនៃរដ្ឋបាលឃុំ សង្កាត់

មាត្រា ៤១.-

រដ្ឋបាលឃុំ សង្កាត់មានតួនាទីជំរុញនិងគាំពារអភិបាលកិច្ចល្អ ដោយចាត់ចែងប្រើប្រាស់ធនធាននានាដែលមានប្រកបដោយចីរភាព សំរាប់បំពេញសេចក្តីត្រូវការជាមូលដ្ឋានក្នុងឃុំ សង្កាត់របស់ខ្លួន បំរើផលប្រយោជន៍រួមរបស់ប្រជាពលរដ្ឋនិងគោរពផលប្រយោជន៍របស់ជាតិស្របតាមនយោបាយទូទៅរបស់រដ្ឋ ។

មាត្រា ៤២.-

រដ្ឋបាលឃុំ សង្កាត់មានតួនាទីពីរប្រភេទគឺ :

- តួនាទីបំរើកិច្ចការមូលដ្ឋានសំរាប់បំរើផលប្រយោជន៍ឃុំ សង្កាត់និងប្រជាពលរដ្ឋក្នុងឃុំ សង្កាត់របស់ខ្លួន ។
- តួនាទីជាភ្នាក់ងារតំណាងរដ្ឋ ក្រោមការចាត់តាំង ឬការប្រគល់អំណាចរបស់អាជ្ញាធររដ្ឋ ។ល។

មាត្រា ៤៣.-

ក្នុងតួនាទីបំរើកិច្ចការមូលដ្ឋាន រដ្ឋបាលឃុំ សង្កាត់មានភារកិច្ច :

- ធានារក្សាសន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ

- រៀបចំចាត់ចែងសេវាសាធារណៈចាំបាច់និងមើលការខុសត្រូវឱ្យកិច្ចការទាំងនោះដំណើរការបានល្អ

- លើកទឹកចិត្តឱ្យមានការបង្កើនផាសុកភាពនិងសុខុមាលភាពរបស់ប្រជាពលរដ្ឋ

- ជំរុញកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ចនិងលើកកំពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ

- ការពារ ថែរក្សាបរិស្ថាន ធនធានធម្មជាតិ វប្បធម៌ បេតិកភណ្ឌជាតិ

- សំរបសំរួលទស្សនៈរបស់ប្រជាពលរដ្ឋដើម្បីឱ្យមានការយោគយល់អធ្យាស្រ័យទៅវិញទៅមក

- បំពេញកិច្ចការជាទូទៅដើម្បីឆ្លើយតបសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ ។

មាត្រា ៤៤.-

ក្នុងតួនាទីជាភ្នាក់ងារតំណាងរដ្ឋ រដ្ឋបាលឃុំ សង្កាត់មានភារកិច្ចអនុវត្តទៅតាមច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាសនិងលិខិតបទដ្ឋានពាក់ព័ន្ធ ។

ក្នុងករណីនេះ អាជ្ញាធររដ្ឋអាចធ្វើប្រតិភូកម្មអំណាចដល់ឃុំ សង្កាត់ដោយភ្ជាប់ជាមួយនូវការបង្កើនសមត្ថភាពនិងផ្គត់ផ្គង់មធ្យោបាយ សម្ភារៈ ថវិកា សំរាប់អនុវត្ត ។

ប្រតិភូកម្មខាងលើនេះ ត្រូវផ្តល់ចំពោះតែសមូហភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់តែប៉ុណ្ណោះ ។

មាត្រា ៤៥.-

រដ្ឋបាលឃុំ សង្កាត់គ្មានអំណាចសំរេចលើវិស័យទាំងឡាយដូចខាងក្រោម :

- ព្រៃឈើ

- ប្រៃសណីយ៍និងទូរគមនាគមន៍

- ការពារប្រទេស ។ល។

- សន្តិសុខជាតិ
- រូបិយវត្ថុ
- នយោបាយក្រៅប្រទេស
- គោលនយោបាយសារពើពន្ធ
- និងវិស័យផ្សេងទៀតដែលមានចែងក្នុងច្បាប់ លិខិតបទដ្ឋានពាក់ព័ន្ធ។

**មាត្រា ៤៦.-**

តួនាទី មុខងារនិងអំណាចរបស់ឃុំ សង្កាត់ ដូចមានចែងក្នុងមាត្រា ៤២, ៤៣ និងមាត្រា ៤៤នៃច្បាប់នេះ អនុវត្តបានតែក្នុងរង្វង់ដែនដីឃុំ សង្កាត់របស់ខ្លួនតែប៉ុណ្ណោះ ។

ក្នុងករណីមានបញ្ហាកើតឡើងទាក់ទងសមត្ថកិច្ចរវាងឃុំ សង្កាត់ពីរឬច្រើន រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចាត់ការឱ្យមានការសំរុះសំរួលគ្នារវាងរដ្ឋបាលដែលពាក់ព័ន្ធទាំងនោះ ។

**មាត្រា ៤៧.-**

តួនាទី មុខងារនិងអំណាចរបស់រដ្ឋបាលឃុំ សង្កាត់ដូចមានចែងក្នុងមាត្រា ៤២, ៤៣, ៤៤ និងមាត្រា ៤៥នៃច្បាប់នេះ អាចកំណត់លំអិតជាក់ស្តែងបន្ថែមទៀតដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ៤៨.-**

ឃុំ សង្កាត់មានអំណាចបញ្ញត្តិនិងអំណាចប្រតិបត្តិ ។

អំណាចបញ្ញត្តិរបស់ឃុំ សង្កាត់ត្រូវធ្វើឡើងតាមរយៈដីកាឃុំ សង្កាត់សំរាប់គ្រប់គ្រងកិច្ចការនានាក្នុងក្របខ័ណ្ឌ តួនាទី មុខងារនិងអំណាចរបស់ខ្លួន ។

ដីកាឃុំ សង្កាត់ត្រូវធ្វើឡើងតាមការសំរេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ហើយត្រូវចុះហត្ថលេខាដោយមេឃុំ ចៅសង្កាត់ ។

រដ្ឋបាលឃុំ សង្កាត់ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈនិងជាបន្ទាន់ក្នុងឃុំ សង្កាត់របស់ខ្លួននូវដីកាដែលបានសំរេចរួចហើយ ។

**មាត្រា ៤៩.-**

ដីកាឃុំ សង្កាត់មានប្រសិទ្ធភាពអនុវត្តតែក្នុងវង្វង់ដែនដីរបស់ខ្លួនប៉ុណ្ណោះ ។

ដីកាឃុំ សង្កាត់មិនត្រូវផ្ទុយនឹងសន្ធិសញ្ញា អនុសញ្ញាអន្តរជាតិ ដែលព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ ស្មារតីរដ្ឋធម្មនុញ្ញ ផ្ទុយនឹងច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានពាក់ព័ន្ធបានឡើយ ។

ដីកាដែលដាក់ចេញដោយរដ្ឋបាលឃុំ សង្កាត់ ហើយផ្ទុយនឹងសន្ធិសញ្ញា អនុសញ្ញាអន្តរជាតិ ដែលព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ ស្មារតីរដ្ឋធម្មនុញ្ញ ផ្ទុយនឹងច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាសនិងលិខិតបទដ្ឋានពាក់ព័ន្ធត្រូវចាត់ទុកជាមោឃៈដាច់ខាត ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវជូនដំណឹងអំពីមោឃភាពនេះជាលាយលក្ខណ៍អក្សរដល់ឃុំ សង្កាត់សាមីនិងត្រូវផ្សព្វផ្សាយជាសាធារណៈ ។

**មាត្រា ៥០.-**

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវណែនាំអំពីទំរង់និងបែបបទ ដើម្បីឱ្យឃុំ សង្កាត់រៀបចំដីកាស្របទៅតាមសភាពការណ៍ក្នុងឃុំ សង្កាត់របស់ខ្លួន ។

**មាត្រា ៥១.-**

ក្រុមប្រឹក្សាឃុំ សង្កាត់អាចធ្វើប្រតិភូកម្មអំណាចឱ្យដល់មេឃុំ ចៅសង្កាត់តាមសេចក្តីណែនាំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ លើកលែងតែបញ្ហាទាំងឡាយដូចខាងក្រោម :

- ការអនុម័តលើគំរោងថវិកាឃុំ សង្កាត់
- ការកំណត់តម្លៃសារពើពន្ធមូលដ្ឋាន មិនមែនសារពើពន្ធមូលដ្ឋាន និងកំរៃសេវាផ្សេងៗ
- ការបោះឆ្នោតអនុម័តបទបញ្ជាផ្ទៃក្នុងនិងដីកាឃុំ សង្កាត់
- ការអនុម័តលើគំរោងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់
- បញ្ហាដទៃទៀតដែលកំណត់ដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

មេឃុំ ចៅសង្កាត់ដែលត្រូវបានក្រុមប្រឹក្សាឃុំ សង្កាត់ធ្វើប្រតិភូកម្មអំណាចឱ្យពុំអាចផ្ទេរអំណាចនេះបន្តទៅឱ្យបុគ្គលដទៃទៀតបានឡើយ ។ ៚

មាត្រា ៥២.-

ក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានធ្វើប្រតិភូកម្មអំណាចឱ្យដល់មេឃុំ ចៅសង្កាត់ នៅតែទទួលខុសត្រូវលើកិច្ចការដែលបានធ្វើប្រតិភូកម្មនោះ ។

ការដកហូតនូវអំណាចដែលបានធ្វើប្រតិភូកម្ម មិនធ្វើឱ្យប៉ះពាល់ដល់សុពលភាពនៃកិច្ចការដែលបានធ្វើរួចហើយនោះទើយ ។

## ជំពូកទី ៥
## ការតាមដាន ការត្រួតពិនិត្យនិងការធ្វើអន្តរាគមន៍

មាត្រា ៥៣.-

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវកំណត់ពីនីតិវិធីផ្សេងៗសំរាប់ធ្វើការតាមដាននិងត្រួតពិនិត្យអំពីសកម្មភាពទូទៅរបស់ឃុំ សង្កាត់ដើម្បី :

- ពិនិត្យមើលអំពីនីត្យានុកូលភាពនៃការគ្រប់គ្រងការងារ ការប្រើប្រាស់អំណាចនិងការបំពេញតួនាទី ភារកិច្ច របស់ឃុំ សង្កាត់នីមួយៗ
- ពិនិត្យមើលការវិវត្តន៍អំពីសមត្ថភាពរបស់ឃុំ សង្កាត់នានា
- ប៉ាន់ប្រមាណអំពីការធ្វើអន្តរាគមន៍និងការជួយឧបត្ថម្ភគាំទ្រចំពោះឃុំ សង្កាត់ដើម្បីពង្រឹងសមត្ថភាពគ្រប់គ្រងការងារ ការប្រើប្រាស់អំណាចនិងការបំពេញតួនាទីភារកិច្ច ។

ក្នុងការតាមដាន ការត្រួតពិនិត្យនិងការធ្វើការអន្តរាគមន៍ចំពោះឃុំ សង្កាត់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អាចរំលែកអំណាចដល់មន្ត្រីជាតំណាងរាជរដ្ឋាភិបាលតាមថ្នាក់រដ្ឋបាលដែនដីខេត្ត ក្រុង ស្រុក ខ័ណ្ឌ ឱ្យជួយកិច្ចការនេះទៅតាមសំណូមពរការងារ ។

មាត្រា ៥៤.-

ឃុំ សង្កាត់ណាដែលមិនបានបំពេញភារកិច្ចដែលច្បាប់បានតម្រូវ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវធ្វើអន្តរាគមន៍ដើម្បីឱ្យមានការបំពេញភារកិច្ចដែលច្បាប់បានតម្រូវនោះជាបន្ទាន់ ។៚

ភារកិច្ចដែលច្បាប់បានតម្រូវ គឺជាភារកិច្ចមួយដែលក្រុមប្រឹក្សាឃុំ សង្កាត់ មានកាតព្វកិច្ចបំពេញតាមល័ក្ខខ័ណ្ឌទាំងឡាយនៃច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស លិខិតបទដ្ឋានពាក់ព័ន្ធ ឬបទបញ្ជាផ្ទៃក្នុងនិងដីកាឃុំ សង្កាត់ ។

**មាត្រា ៥៥.-**

ការតាមដាន ត្រួតពិនិត្យនិងធ្វើអន្តរាគមន៍រួមមានការងារ :

- ស៊ើបអង្កេតនិងវាយតំលៃ
- ធ្វើសេចក្តីណែនាំជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាឃុំ សង្កាត់ ឱ្យបំពេញភារកិច្ចដែលច្បាប់បានតម្រូវ
- ធ្វើជំនួសក្នុងការបន្តបំពេញភារកិច្ចដែលច្បាប់បានតម្រូវ ។

**មាត្រា ៥៦.-**

ការធ្វើអន្តរាគមន៍ដូចមានចែងក្នុងវាក្យខ័ណ្ឌទី ១ មាត្រា ៥៤ នៃច្បាប់នេះត្រូវមានលក្ខណៈសមហេតុផលនិងស្របទៅតាមទំហំនៃកិច្ចការដែលក្រុមប្រឹក្សាឃុំ សង្កាត់ មិនបានបំពេញភារកិច្ចដែលច្បាប់បានតម្រូវ ដោយភ្ជាប់ជាមួយនូវការណែនាំនិងការគាំទ្រសំខាន់ចាំបាច់ ដើម្បីឱ្យក្រុមប្រឹក្សាឃុំ សង្កាត់អាចបំពេញភារកិច្ចដែលច្បាប់បានតំរូវជាធម្មតា ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានសិទ្ធិចុះកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរជាមួយបុគ្គល ឬអង្គការណាមួយ ឬធ្វើការណែនាំជាលាយលក្ខណ៍អក្សរដល់មន្ត្រីជាតំណាងរាជរដ្ឋាភិបាលតាមថ្នាក់រដ្ឋបាលដែនដីខេត្ត ក្រុង ស្រុក ខ័ណ្ឌឱ្យបំពេញការងារចាំបាច់ដើម្បីធ្វើអន្តរាគមន៍ក្នុងនាមខ្លួនចំពោះកិច្ចការណាមួយ ។

**មាត្រា ៥៧.-**

កាលបើការធ្វើអន្តរាគមន៍មិនទទួលបានលទ្ធផលចំពោះភារកិច្ចដែលច្បាប់បានតម្រូវណាមួយ ឬមួយចំនួនក្នុងអំឡុងពេល ៦ខែ ហើយភារកិច្ចដែលច្បាប់បានតម្រូវជាទូទៅក្រុមប្រឹក្សាឃុំ សង្កាត់ក៏មិនអាចបំពេញបាន រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវសំរេចរំសាយក្រុមប្រឹក្សាឃុំ សង្កាត់ ហើយធ្វើការបោះឆ្នោតឡើងវិញទៅតាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងច្បាប់នេះនិងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។ល។

មាត្រា ៥៨.-

ក្នុងករណីក្រុមប្រឹក្សាឃុំ សង្កាត់ណាធ្វើសកម្មភាពផ្ទុយនឹងរដ្ឋធម្មនុញ្ញ ផ្ទុយនឹងនយោបាយរដ្ឋាភិបាល រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវសំរេចរំសាយក្រុមប្រឹក្សាឃុំ សង្កាត់ នោះជាបន្ទាន់ ហើយត្រូវធ្វើការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នោះឡើងវិញ ទៅតាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងច្បាប់នេះនិងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។

មាត្រា ៥៩.-

ត្រូវបង្កើតឱ្យមានអង្គភាពមួយចំណុះក្រសួងមហាផ្ទៃដើម្បីធ្វើជាសេនាធិការអំពីការងាររដ្ឋបាលមូលដ្ឋាន ។

ការរៀបចំនិងការប្រព្រឹត្តទៅនៃអង្គភាពនេះត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

## ជំពូកទី ៦
## ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់

មាត្រា ៦០.-

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវរៀបចំ អនុម័តនិងអនុវត្តនូវផែនការអភិវឌ្ឍន៍ឃុំសង្កាត់ក្នុងគោលបំណងកំណត់នូវទស្សនវិស័យ កម្មវិធីនិងកិច្ចអភិវឌ្ឍន៍ឃុំ សង្កាត់របស់ខ្លួន ។

មាត្រា ៦១.-

ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ត្រូវឱ្យស្របទៅនឹងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកិច្ចរបស់ជាតិ ។

មាត្រា ៦២.-

ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ត្រូវអនុម័តយល់ព្រមដោយក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងឆ្នាំទី ១ នៃអាណត្តិរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ហើយត្រូវពិនិត្យឡើងវិញដើម្បីផ្តល់ទិន្នន័យថ្មីៗជារៀងរាល់ឆ្នាំ ដោយក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន ។ស.ក.

**មាត្រា ៦៣.-**

ក្នុងការរៀបចំផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវចាត់វិធានការដូចតទៅ :

- វាយតំលៃអំពីកំរិតអត្ថិភាពនៃការអភិវឌ្ឍន៍និងសកម្មភាពអភិវឌ្ឍន៍នៅក្នុងឃុំ សង្កាត់របស់ខ្លួន
- ប្រមូលផ្តុំសេចក្តីត្រូវការក្នុងឃុំ សង្កាត់និងកំណត់អាទិភាពចំពោះសេចក្តីត្រូវការទាំងនោះ ដោយផ្អែកទៅលើធនធានទាំងឡាយដែលឃុំ សង្កាត់មាននិងធនធានដែលបានទទួល
- រៀបចំកម្មវិធីដែលអាចឆ្លើយតបនឹងសេចក្តីត្រូវការនានា តាមរយៈការផ្តល់សេវានិងការអភិវឌ្ឍន៍ ហើយកម្មវិធីទាំងនេះត្រូវបញ្ចូលក្នុងថវិកាប្រចាំឆ្នាំរបស់ឃុំ សង្កាត់
- ផ្តល់សេវានិងការអភិវឌ្ឍន៍ អនុលោមទៅតាមថវិការបស់ខ្លួន
- ពិនិត្យ តាមដាននិងវាយតំលៃចំពោះលទ្ធផលនៃការអនុវត្តផែនការអភិវឌ្ឍន៍
- ប្រើប្រាស់លទ្ធផលផ្សេងៗ ដើម្បីវាយតំលៃអំពីកំរិតនៃការអភិវឌ្ឍន៍ថ្មីៗក្នុងឃុំ សង្កាត់របស់ខ្លួន
- ធ្វើសេចក្តីរាយការណ៍អំពីលទ្ធផលនៃការអនុវត្តផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ជូនប្រជាពលរដ្ឋរបស់ខ្លួន ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវដឹកនាំការងារឱ្យស្របទៅនឹងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់របស់ខ្លួន ។

**មាត្រា ៦៤.-**

ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ត្រូវរៀបចំជាលាយលក្ខណ៍អក្សរដោយមានផែនទី ស្ថិតិនិងសំណុំឯកសារពាក់ព័ន្ធផ្សេងៗទៀតភ្ជាប់ជាមួយផង ។

ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ក៏ត្រូវកំណត់ផងដែរនូវវិធីសាស្ត្រនិងមធ្យោបាយនានាដើម្បីបង្កលទ្ធភាពឱ្យមានការចូលរួមពីប្រជាពលរដ្ឋក្នុងឃុំ សង្កាត់របស់ខ្លួនក្នុងកិច្ចដំណើរការទាំងមូល ។ ມ.ກ.

**មាត្រា ៦៥.-**

ក្នុងករណីដែលផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ណាមួយធ្វើឡើងមិនស្របតាមល័ក្ខខ័ណ្ឌដែលបានចែងក្នុងច្បាប់នេះ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវណែនាំឱ្យក្រុមប្រឹក្សាឃុំ សង្កាត់កែតម្រូវផែនការរបស់ខ្លួនឱ្យបានសមស្របក្នុងអំឡុងពេលយ៉ាងយូរ ៤៥ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលច្បាប់ចម្លងនៃផែនការនោះ ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើការកែសំរួលផែនការអភិវឌ្ឍន៍ឃុំ សង្កាត់របស់ខ្លួនឱ្យបានសមស្របតាមការណែនាំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ៦៦.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើការតាមដាន ត្រួតពិនិត្យនិងវាយតំលៃរាល់ការអនុវត្តផែនការ កម្មវិធី គំរោងនិងការផ្តល់សេវានានាប្រកបដោយតម្លាភាពនិងមានការទទួលខុសត្រូវខ្ពស់ ។

**មាត្រា ៦៧.-**

ក្រុមប្រឹក្សាឃុំ សង្កាត់នៅតែជាអ្នកទទួលខុសត្រូវក្នុងការតាមដាន ការត្រួតពិនិត្យនិងការវាយតំលៃចំពោះផែនការ កម្មវិធីនិងគំរោងនានា ទោះជាការងារនោះត្រូវបានអនុវត្តដោយសមាសភាពណាក៏ដោយដែលខ្លួនបានជ្រើសយក ។

**មាត្រា ៦៨.-**

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវណែនាំក្រុមប្រឹក្សាឃុំ សង្កាត់អំពីវិធីផ្សេងៗក្នុងការអនុវត្តផែនការនិងក្នុងការត្រួតពិនិត្យ វាយតំលៃចំពោះការប្រើប្រាស់មូលនិធិសំរាប់ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ។

**មាត្រា ៦៩.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើសេចក្តីរាយការណ៍ប្រចាំឆ្នាំអំពី :

- កិច្ចការជាអាទិភាព គោលដៅសំរាប់ផ្តល់សេវានិងគំរោងផែនការអភិវឌ្ឍន៍របស់ឃុំ សង្កាត់នាឆ្នាំសារពើពន្ធកន្លងមក
- លទ្ធផលនៃការអនុវត្តចំពោះកិច្ចការជាអាទិភាព គោលដៅសំរាប់ផ្តល់សេវានិងគំរោងផែនការអភិវឌ្ឍន៍ទាំងនោះរបស់ឃុំ សង្កាត់ ល.ៗ

- វិធានការធ្វើឱ្យបានល្អប្រសើរចំពោះវិស័យនានាដែលមានការខ្វះចន្លោះក្នុងការអនុវត្តកន្លងមក

- កិច្ចការជាអាទិភាព គោលដៅសំរាប់ផ្តល់សេវានិងគំរោងផែនការអភិវឌ្ឍន៍របស់ឃុំ សង្កាត់ក្នុងឆ្នាំសារពើពន្ធបច្ចុប្បន្ន ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវអនុម័តសេចក្តីរាយការណ៍នេះក្នុងអំឡុងពេលយ៉ាងយូរ ៤៥ថ្ងៃ បន្ទាប់ពីបំណាច់ឆ្នាំសារពើពន្ធនីមួយៗ ។

**មាត្រា ៧០.-**

សេចក្តីរាយការណ៍ប្រចាំឆ្នាំដូចមានចែងក្នុងមាត្រា ៦៩នៃច្បាប់នេះ ក្រោយពីបានអនុម័តយល់ព្រមដោយក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវ :

- បញ្ជូនជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- តម្កល់ទុកជាសាធារណៈ
- បញ្ជូនចែកជូនអង្គការ សមាគមនិងសាធារណជនសំខាន់ៗដោយគិតត្រឹមថ្ងៃដើម ។

**មាត្រា ៧១.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវពិនិត្យពិចារណាទៅលើមតិយោបល់ផ្សេងៗដែលបានផ្តល់ចំពោះសេចក្តីរាយការណ៍ដូចមានចែងក្នុងមាត្រា ៦៩ និងមាត្រា ៧០នៃច្បាប់នេះ ហើយត្រូវទទួលយកនូវមតិយោបល់ល្អៗ ដើម្បីដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ។

**មាត្រា ៧២.-**

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវពិគ្រោះពិភាក្សាជាមួយក្រសួងស្ថាប័នពាក់ព័ន្ធដើម្បីចេញសេចក្តីណែនាំអនុវត្តជាក់ស្តែងនូវបទប្បញ្ញត្តិនានា ដែលបានចែងក្នុងជំពូកទី ៦ នៃច្បាប់នេះ ។

## ជំពូកទី ៧
## ហិរញ្ញវត្ថុឃុំ សង្កាត់

**មាត្រា ៧៣.-**

ឃុំ សង្កាត់មានធនធានហិរញ្ញវត្ថុ ថវិកានិងទ្រព្យសម្បត្តិផ្ទាល់ ។ ៸អ៊ុ.

## មាត្រា ៧៤.-

ឃុំ សង្កាត់មានសិទ្ធិទទួលចំណូលផ្ទាល់ដែលបានមកពីចំណូលសារពើពន្ធ ចំណូលមិនមែនសារពើពន្ធនិងកំរៃសេវាផ្សេងៗ ។

ពន្ធខាងលើនេះរាប់បញ្ចូលនូវពន្ធលើដីធ្លី ពន្ធលើអចលនទ្រព្យនិងពន្ធនៃការជួល ។

ក្នុងករណីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុប្រមូលចំណូលផ្ទាល់របស់ឃុំ សង្កាត់ ការប្រមូលចំណូលនេះត្រូវធ្វើក្នុងនាមឃុំ សង្កាត់ ។

ប្រភេទ កំរិតនិងរបៀបរបបនៃការប្រមូលចំណូលសារពើពន្ធ ចំណូលមិនមែនសារពើពន្ធនិងកំរៃសេវាផ្សេងៗ ខាងលើនេះត្រូវកំណត់ដោយច្បាប់ ។

## មាត្រា ៧៥.-

ឃុំ សង្កាត់មានសិទ្ធិទទួលបាននូវធនធានវិភាជន៍ពីចំណូលរដ្ឋ សំរាប់ថវិការបស់ខ្លួន ។

ធនធានវិភាជន៍នេះរួមមានៈ

- ការផ្ទេរទាំងមូលឬមួយផ្នែកនូវប្រាក់ចំណូលសារពើពន្ធនិងចំណូលមិនមែនសារពើពន្ធដ៏ជាក់លាក់របស់រដ្ឋ
- ទាយជ្ជទាននិងធនធានវិភាជន៍ ឧបត្ថម្ភធន ឬអនុប្បទានដែលបានមកពីប្រាក់ចំណូលរដ្ឋ ។

ធនធានវិភាជន៍ខាងលើនេះត្រូវផ្តល់ទៅឱ្យឃុំ សង្កាត់តាមរតនាគារខេត្ត ក្រុង ។

ការរៀបចំនិងនីតិវិធីនៃការផ្ទេរប្រាក់វិភាជន៍ខាងលើនេះត្រូវកំណត់ដោយអនុក្រឹត្យ ។

## មាត្រា ៧៦.-

ឃុំ សង្កាត់នីមួយៗ មានសិទ្ធិទទួលបាននូវប្រាក់កំរៃ ចំពោះការអនុវត្តនូវតួនាទីជាភ្នាក់ងារតំណាងរដ្ឋដែលរាជរដ្ឋាភិបាល ឬក្រសួងស្ថាប័នណាមួយនៃរាជរដ្ឋាភិបាលបានប្រគល់ឱ្យអនុវត្ត ។

ប្រាក់កំរៃខាងលើនេះគឺជាប្រាក់បន្ថែមពីលើប្រាក់ចំណូលរបស់ឃុំ សង្កាត់ ឬប្រាក់វិភាជន៍ផ្សេងៗដែលឃុំ សង្កាត់ទទួលបានពីប្រាក់ចំណូលរដ្ឋ ។៚

រាជរដ្ឋាភិបាលឬក្រសួងស្ថាប័នណាមួយនៃរាជរដ្ឋាភិបាលត្រូវផ្ដល់កំរៃសមស្របដល់ឃុំ សង្កាត់ ដែលបានអនុវត្តតួនាទីជាភ្នាក់ងារតំណាងរដ្ឋដូចបានចែងខាងលើ ។

ក្នុងករណីដែលការប្រគល់អំណាច មុខងាររបស់រដ្ឋមានលក្ខណៈជាអចិន្ត្រៃយ៍ទៅឱ្យឃុំ សង្កាត់រាជរដ្ឋាភិបាលត្រូវរៀបចំឱ្យមានធនធានហិរញ្ញវត្ថុរយៈពេលយូរអង្វែងសំរាប់ផ្ដល់ឱ្យឃុំ សង្កាត់ ។

ការរៀបចំប្រាក់កំរៃខាងលើនេះត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៧៧.-**

រដ្ឋបង្កើតឱ្យមានមូលនិធិឃុំ សង្កាត់ ។

មូលនិធិឃុំ សង្កាត់បង្កើតឡើងក្នុងគោលដៅដើម្បីធ្វើការផ្ទេរនូវប្រាក់ចំណូលពីជាតិនិងប្រាក់ចំណូលផ្សេងៗទៀតទៅឱ្យថវិកាឃុំ សង្កាត់ ។

ការផ្ទេរប្រាក់ចំណូលពីជាតិទៅមូលនិធិខាងលើនេះត្រូវធ្វើឡើងទៅតាមរូបមន្តឬតាមអត្រាជាក់លាក់មួយសំរាប់ថេរៈវេលាយ៉ាងតិច ៣ឆ្នាំ និងមិនលើសពី ៥ឆ្នាំដែលកំណត់ដោយអនុក្រឹត្យ ។

នីតិវិធីអនុវត្តជាក់ស្តែងនៃមាត្រានេះត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៧៨.-**

មូលនិធិឃុំ សង្កាត់បានមកពី :

- ការធ្វើវិភាជន៍នូវចំណែកដ៏ជាក់លាក់នៃប្រាក់ចំណូលរដ្ឋ ពីថវិការដ្ឋប្រចាំឆ្នាំដែលកំណត់ដោយអនុក្រឹត្យ
- អនុប្បទាននិងការខ្ចីពីប្រភពក្នុងប្រទេសនិងក្រៅប្រទេស ។

ការធ្វើវិភាជន៍នូវធនធានប្រចាំឆ្នាំទៅឱ្យឃុំ សង្កាត់តាមមូលនិធិឃុំ សង្កាត់ត្រូវធ្វើឡើងទៅតាមរូបមន្តដែលកំណត់ដោយអនុក្រឹត្យ ។

របៀបរបបចាត់ចែង វិធាននៃការប្រើប្រាស់និងនីតិវិធីនៃការបើកប្រាក់ចំណាយពីមូលនិធិឃុំ សង្កាត់ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៧៩.-**

ឃុំ សង្កាត់ត្រូវរៀបចំនិងអនុម័តថវិការបស់ខ្លួនជារៀងរាល់ឆ្នាំ ។ល។

ថវិកាឃុំ សង្កាត់ត្រូវរៀបចំទៅតាមទំរង់មួយនិងអនុម័តនៅក្នុងកាលបរិច្ឆេទ ឬមុនកាលបរិច្ឆេទមួយអនុលោមទៅតាមប្រពន្ធ័ថវិកាជាតិ ។

ថវិកាឃុំ សង្កាត់ត្រូវមានតុល្យភាពរវាងចំណូលសរុបនិងចំណាយសរុប ។

ឃុំ សង្កាត់អាចបង្កើនចំណាយបាន តែត្រូវឱ្យស្របទៅតាមចំណូលរបស់ខ្លួន ។

ថវិកាឃុំ សង្កាត់ត្រូវឆ្លុះបញ្ចាំងអំពីអាទិភាពនិងសេចក្ដីត្រូវការនៃផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគរបស់ឃុំ សង្កាត់ ។

នីតិវិធីនៃការរៀបចំនិងការអនុម័តថវិកាខាងលើត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៨០.-**

ឃុំ សង្កាត់គ្មានសិទ្ធិខ្ចីប្រាក់បានឡើយ ។

ឃុំ សង្កាត់មិនអាចធានាភ្ជាប់រងចំពោះការខ្ចី ឬកាតព្វកិច្ចហិរញ្ញវត្ថុណាមួយបានឡើយ ។

**មាត្រា ៨១.-**

ឃុំ សង្កាត់មានសិទ្ធិទទួលបាននូវការផ្ទេរទ្រព្យសម្បត្តិមួយផ្នែករបស់រដ្ឋមកជាទ្រព្យសម្បត្តិរបស់ឃុំ សង្កាត់ ។

ឃុំ សង្កាត់ត្រូវគ្រប់គ្រងឱ្យបានល្អនូវទ្រព្យសម្បត្តិដែលរកបានដោយខ្លួនឯងនិងទ្រព្យសម្បត្តិដែលរដ្ឋបានប្រគល់ឱ្យ ។

ឃុំ សង្កាត់អាចប្រើប្រាស់និងទាញយកផលចំណូលពីទ្រព្យសម្បត្តិដែលរដ្ឋបានប្រគល់ឱ្យខ្លួនគ្រប់គ្រង ។

ឃុំ សង្កាត់ត្រូវថែរក្សាការពារទ្រព្យសម្បត្តិដែលរដ្ឋប្រគល់ឱ្យ ។ បានគង់វង្ស ហើយទ្រព្យសម្បត្តិទាំងនោះ ឃុំ សង្កាត់គ្មានសិទ្ធិលក់ដូរឬផ្ទេរកម្មសិទ្ធិ ឬផ្ទេរការប្រើប្រាស់ដោយគ្មានការយល់ព្រមជាមុនពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បន្ទាប់ពីមានយោបល់ឯកភាពរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃបានឡើយ ។

នីតិវិធីចាត់ចែងនិងប្រើប្រាស់ទ្រព្យសម្បត្តិខាងលើ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៨២.-**

ឃុំ សង្កាត់ត្រូ[illegible]កឱ្យមាននូវប្រព័ន្ធគ្រប់គ្រង តាមដាននិងត្រួតពិនិត្យហិរញ្ញវត្ថុរបស់ខ្លួនដែលរួមមាន : ន.ត.

- បទដ្ឋានហិរញ្ញវត្ថុនិងការអនុវត្តជាក់ស្តែងផ្នែកគណនេយ្យ
- ការចាត់ចែង គ្រប់គ្រងទ្រព្យសម្បត្តិ
- តំរូវការផ្សេងៗ ក្នុងការធ្វើសវនកម្ម
- ការគ្រប់គ្រងហិរញ្ញវត្ថុប្រកបដោយតម្លាភាព ប្រសិទ្ធិភាពនិងការទទួលខុសត្រូវ ។

ប្រព័ន្ធនៃការគ្រប់គ្រង ការតាមដាននិងការត្រួតពិនិត្យហិរញ្ញវត្ថុឃុំ សង្កាត់ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៨៣.-**

របបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់ឃុំ សង្កាត់ត្រូវស្ថិតក្រោមការត្រួតពិនិត្យរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បន្ទាប់ពីបានពិភាក្សាឯកភាពលើគោលការណ៍ជាមួយក្រសួងមហាផ្ទៃ ។

## ជំពូកទី ៨
## ទោសប្បញ្ញត្តិ

**មាត្រា ៨៤.-**

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលមិនគោរពតាមបទប្បញ្ញត្តិនៃច្បាប់នេះត្រូវទទួលវិន័យដោយពុំទាន់គិតដល់ទោសព្រហ្មទ័ណ្ឌផ្សេងទៀត ។

វិន័យរួមមាន :

- ស្តីបន្ទោសក្នុងអង្គប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ដោយមានកំណត់ហេតុច្បាស់លាស់
- ករណីនៅតែបន្តប្រព្រឹត្តកំហុស ត្រូវកាត់មួយផ្នែកឬទាំងអស់នូវប្រាក់ឧបត្ថម្ភ ។

វិន័យដែលតម្រូវឱ្យកាត់មួយផ្នែកឬទាំងអស់នូវប្រាក់ឧបត្ថម្ភដូចចែងខាងលើអាចអនុវត្តបាន លុះត្រាតែមានការយល់ព្រមជាមុនពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ តាមសេចក្តីស្នើសុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

ប្រាក់ឧបត្ថម្ភដែលកាត់នេះត្រូវបានមកជាប្រយោជន៍នៃថវិកាឃុំ សង្កាត់ ។

ក្នុងករណីបានអនុវត្តបភាពវិន័យទាំងពីរខាងលើរួចហើយ តែសាមីខ្លួននៅតែមិនរាងចាល ក្រុមប្រឹក្សាឃុំ សង្កាត់អាចបញ្ឈប់ជននោះពីមុខតំណែងជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដោយការបោះឆ្នោតអនុម័តតាមសម្លេងភាគច្រើនដាច់ខាតនៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូល ហើយត្រូវធ្វើការជ្រើសរើសសមាជិកថ្មីមកជំនួសតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងវាក្យខ័ណ្ឌទី ២ មាត្រា ១៦នៃច្បាប់នេះ ។

ក្នុងករណីប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ជាមេឃុំ ចៅសង្កាត់ទទួលវិន័យ ត្រូវជ្រើសយកសមាជិកណាម្នាក់ក្នុងក្រុមប្រឹក្សាឬមន្ត្រីម្នាក់ដែលចាត់តាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃឱ្យដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ដើម្បីអនុវត្តបភាពវិន័យខាងលើនេះ ។

មន្ត្រីដែលចាត់តាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃឱ្យដឹកនាំកិច្ចប្រជុំខាងលើនេះពុំមានសិទ្ធិអនុម័តឡើយ ។

## ជំពូកទី ៩
## អន្តរប្បញ្ញត្តិ

**មាត្រា ៨៥.-**

ដើម្បីមានមូលដ្ឋានសំរាប់រៀបចំបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់និងគ្រប់គ្រងឃុំ សង្កាត់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញប្រកាសអំពីចំនួន ឈ្មោះនិងព្រំប្រទល់របស់ឃុំ សង្កាត់ ក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជាឱ្យបាន ៩ខែមុនកាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នាអាណត្តិដំបូងនេះ ។

**មាត្រា ៨៦.-**

ក្រោយការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នាអាណត្តិទី ១ នេះ ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗ ត្រូវរៀបចំឡើងវិញនូវមេភូមិនាទាចំណុះឃុំ សង្កាត់របស់ខ្លួនទៅតាមបែបបទនីតិវិធីដូចមានចែងក្នុងមាត្រា ៣០នៃច្បាប់នេះ ។

**មាត្រា ៨៧.-**

ដើម្បីបង្កលក្ខណៈសម្បត្តិដល់ការគ្រប់គ្រងឃុំ សង្កាត់តាមប្រព័ន្ធវិមជ្ឈការត្រូវបង្កើតគណៈកម្មាធិការអន្តរក្រសួងមួយឈ្មោះថា "គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់" ដែលមានរដ្ឋមន្ត្រីក្រសួងមហាផ្ទៃជាប្រធាន ។ ល.ក.

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ត្រូវបង្កើតឡើងដោយព្រះរាជក្រឹត្យតាមសំណើរបស់នាយករដ្ឋមន្ត្រី ។

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ត្រូវបង្កើតបន្ទាប់ពីច្បាប់នេះបានចូលជាធរមាន ហើយត្រូវបញ្ចប់អាណត្តិរបស់ខ្លួនឱ្យបាន ៩ខែមុនកាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នាអាណត្តិបន្ទាប់ ។

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់អាចចែកចេញជាអនុគណៈកម្មការតាមការចាំបាច់ ។

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ត្រូវយកអង្គភាពដែលបានបង្កើតឡើងស្របតាមមាត្រា ៥៩នៃច្បាប់នេះធ្វើជាលេខាធិការដ្ឋាន ។

**មាត្រា ៨៨.-**

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់មានសមត្ថកិច្ចធ្វើសេចក្តីស្នើយោបល់ទៅក្រសួងមហាផ្ទៃនិងរាជរដ្ឋាភិបាលអំពីបញ្ហានានាដូចខាងក្រោម :

- សិក្សាស្រាវជ្រាវកំណត់ឡើងវិញនូវព្រំប្រទល់ឃុំ សង្កាត់ទាំងអស់ក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជា
- បែងចែកមុខងារ សិទ្ធិអំណាចនិងភារកិច្ចផ្សេងៗ រវាងរាជរដ្ឋាភិបាលនិងឃុំ សង្កាត់ព្រមទាំងរៀបចំឱ្យមានកិច្ចសហការសិរបសិរូលរវាងឃុំ សង្កាត់ ពីរឬច្រើន ។
- បណ្តុះបណ្តាល បង្កើនសមត្ថភាពដល់ក្រុមប្រឹក្សាឃុំ សង្កាត់
- រៀបចំប្រាក់ចំណូលនិងសារពើពន្ធសំរាប់ឃុំ សង្កាត់
- គាំទ្រផ្នែកបច្ចេកទេសដល់ឃុំ សង្កាត់
- វិះរកមធ្យោបាយសំរាប់ផ្តល់ព័ត៌មាននិងគំរង់ទិសរដ្ឋបាលសាធារណៈអំពីកិច្ចដំណើរការនៃប្រព័ន្ធគ្រប់គ្រងឃុំ សង្កាត់តាមបែបប្រជាធិបតេយ្យនិងវិមជ្ឈការ
- ផ្តល់យោបល់ដល់រាជរដ្ឋាភិបាលអំពីការអនុវត្តនយោបាយវិមជ្ឈការក្រោមអំណាចនៃច្បាប់នេះនិងផ្តល់យោបល់លើការកែទម្រង់រដ្ឋបាលសាធារណៈ
- រៀបចំព្រាងលិខិតបទដ្ឋានសំរាប់អនុវត្តច្បាប់នេះ
- រួមយោបល់ទៅលើអនុក្រឹត្យដែលមានការពាក់ព័ន្ធដល់ការងារនៅថ្នាក់ឃុំ សង្កាត់ ល។

- កំណត់របបគ្រប់គ្រងរដ្ឋបាលអន្តរកាលចំពោះឃុំ សង្កាត់ដែលពុំមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីអនុវត្តនយោបាយវិមជ្ឈការ ។

**មាត្រា ៨៩.-**

ក្រោយការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នាអាណត្តិដំបូងនេះ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដោយផ្អែកតាមសេចក្តីស្នើយោបល់របស់គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់អាចស្នើបង្កើតឃុំ សង្កាត់ លុបចោលឃុំ សង្កាត់ កែប្រែព្រំប្រទល់ឃុំ សង្កាត់ ផ្លាស់ប្តូរឈ្មោះឃុំ សង្កាត់ តាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា ៦ និងមាត្រា ១៨នៃច្បាប់នេះ សំរាប់ដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នាអាណត្តិទី ២ ។

## ជំពូកទី ១០
## អវសានប្បញ្ញត្តិ

**មាត្រា ៩០.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍ ។៚

រាជធានីភ្នំពេញថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០១

ក្នុងព្រះបរមនាមនិងតាមព្រះរាជបង្គាប់

ប្រមុខរដ្ឋស្តីទី

**ហត្ថលេខា**

**ជា ស៊ីម**

បានបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី

សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

**ហត្ថលេខា**

**ស ខេង យូ ហុកគ្រី**

លេខ : ៧០ ច.ល

ចំឡងចេញពីច្បាប់ដើម

រាជធានីភ្នំពេញថ្ងៃទី ២១ ខែ ៣ ឆ្នាំ ២០០១

អគ្គលេខាធិការរាជរដ្ឋាភិបាល

[illegible] តាន់

- ច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់, លេខ នស/រកម/០៦០០/០២០, ចុះនៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៦។



នស / រកម / ០៣០១ / ០៤

# ព្រះរាជក្រម

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
## រាជហរិវង្ស ឧភតោសុជាតិ វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍
## និករោត្តមធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
## ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៩៣ ដែលប្រកាសឱ្យប្រើជាផ្លូវការនូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំ ពីសម្តេចនាយករដ្ឋមន្ត្រី និងពីសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

## ប្រកាសអោយប្រើ

ច្បាប់ស្តីពី ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គលើកទី ៥ នីតិកាលទី ២ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាមលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គលើកទី ៤ នីតិកាលទី ១ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញ ប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ តាមសេចក្តីសម្រេចលេខ ០៤២/០០៤/២០០១ កបធ.ច ចុះថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០០១ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ :

# ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលបំណងកំណត់ការរៀបចំ ការគ្រប់គ្រង និងការប្រព្រឹត្តទៅនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។

ច្បាប់នេះត្រូវអនុវត្តចំពោះឃុំ សង្កាត់ទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២.-**

ឃុំ សង្កាត់នីមួយៗត្រូវមានក្រុមប្រឹក្សាមួយដែលត្រូវបានបោះឆ្នោតជ្រើសរើសឡើងដោយប្រជាពលរដ្ឋនៃឃុំ សង្កាត់របស់ខ្លួន តាមការបោះឆ្នោតជាទូទៅ ជាសកល ដោយសេរី ត្រឹមត្រូវនិងយុត្តិធម៌ ដោយស្មើភាព ដោយចំពោះ ដោយសម្ងាត់ ស្របទៅតាមនីតិវិធីដូចមានចែងក្នុងច្បាប់នេះ ។

***មាត្រា ៣.- ថ្មី***

ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ត្រូវធ្វើឡើងរៀងរាល់៥ឆ្នាំម្តង។

ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ត្រូវរៀបចំធ្វើឡើងនៅថ្ងៃជាមួយគ្នា ។

កាលបរិច្ឆេទនៃការបោះឆ្នោតត្រូវកំណត់ដោយនាយករដ្ឋមន្ត្រី តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

នាយករដ្ឋមន្ត្រីត្រូវប្រកាសកាលបរិច្ឆេទ នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងរយៈពេល៩(ប្រាំបួន)ខែយ៉ាងតិច មុនថ្ងៃបោះឆ្នោត ។

ការបោះឆ្នោតត្រូវធ្វើនៅថ្ងៃអាទិត្យ តែមួយថ្ងៃ ។

**មាត្រា ៤.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវកាន់កាប់មុខតំណែងរបស់ខ្លួនរហូតទាល់តែមានក្រុមប្រឹក្សាថ្មីដែលត្រូវបានបោះឆ្នោតជ្រើសរើសឡើងចូលកាន់តំណែងជំនួស ។

## មាត្រា ៤៩.- ថ្មី (មាត្រា ៩៨ ចាស់)

ជនគ្រប់រូបដែលមានបំណងឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបញ្ចូលឈ្មោះរបស់ខ្លួនទៅក្នុងបញ្ជីបេក្ខជននៃគណបក្សនយោបាយ ។

បញ្ជីបេក្ខជននីមួយៗត្រូវរៀបចំដោយគណបក្សនយោបាយដែលបានចុះបញ្ជីត្រឹមត្រូវតាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងច្បាប់ស្តីពីគណបក្សនយោបាយ ។

បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗត្រូវមានឈ្មោះបេក្ខជនតាមលំដាប់លេខរៀង ។

## មាត្រា ៥០.- ថ្មី (មាត្រា ៩៩ ចាស់)

បេក្ខជនម្នាក់ៗត្រូវមានឈ្មោះក្នុងបញ្ជីបេក្ខជននៃគណបក្សនយោបាយតែមួយប៉ុណ្ណោះ ។

## មាត្រា ៥១.- ថ្មី (មាត្រា ១០០ ចាស់)

ដើម្បីឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ គណបក្សនយោបាយត្រូវដាក់ពាក្យសុំចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត តាមការកំណត់របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ទៅគណៈកម្មការឃុំសង្កាត់រៀបចំការបោះឆ្នោតយ៉ាងតិច៩០(កៅសិប)ថ្ងៃ មុនថ្ងៃបោះឆ្នោត ។

ពាក្យសុំត្រូវចុះហត្ថលេខាដោយប្រធានគណបក្សនយោបាយ ឬតំណាងដែលបានទទួលការផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរពីប្រធានគណបក្សនយោបាយនោះ ។

## មាត្រា ៥២.- ថ្មី (មាត្រា ១០១ ចាស់កែប្រែ)

ពាក្យសុំចុះបញ្ជីបេក្ខជនត្រូវភ្ជាប់មកជាមួយនូវ ÷

- សេចក្តីចម្លងលិខិតបញ្ជាក់ការចុះបញ្ជីគណបក្សនយោបាយនៅក្រសួងមហាផ្ទៃមួយច្បាប់

- អាសយដ្ឋាននៃទីស្នាក់ការកណ្តាលគណបក្សនយោបាយ អាសយដ្ឋានទីស្នាក់ការគណបក្សនយោបាយក្នុងឃុំ សង្កាត់ និងឈ្មោះអ្នកតំណាងប្រចាំទីស្នាក់ការគណបក្សនយោបាយក្នុងឃុំ សង្កាត់ដែលបានដាក់ស្នើបញ្ជីបេក្ខជន

- បញ្ជីរាយនាមបេក្ខជន ដែលមានចំនួនបេក្ខជនយ៉ាងហោចណាស់ស្មើនឹងពីរដងនៃចំនួនសមាជិកក្រុមប្រឹក្សាក្នុងក្រុមប្រឹក្សាឃុំ សង្កាត់

- នាមត្រកូល និងនាមខ្លួន អាសយដ្ឋាន លិខិតបញ្ជាក់ថាពិតជាបានចុះឈ្មោះ និងមានឈ្មោះក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតក្នុងឃុំ សង្កាត់ដែលខ្លួនមានបំណងឈរឈ្មោះបោះឆ្នោត ។

# ឧបសម្ព័ន្ធទី ២

# សៀវភៅ

– គណៈកម្មាធិការកសាងផែនការ និងថវិកាឃុំ. ២០១៨. *"សៀវភៅផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ ២០១៧-២០២២ ឃុំស្វាយទាប ស្រុកចំការលើ ខេត្តកំពង់ចាម"*។


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ
# ២០១៧ - ២០២២

សាលាខេត្តកំពង់ចាម
ចូល លេខ...
បញ្ជូនទៅ...

## ឃុំ ស្វាយទាប

## ស្រុក ចំការលើ

## ខេត្ត កំពង់ចាម

រៀបចំ៖ ដោយគណៈកម្មាធិការកសាងផែនការ និងថវិកាឃុំ
បានទទួលការអនុម័តពីក្រុមប្រឹក្សាឃុំ ក្នុងកិច្ចប្រជុំវិសាមញ្ញលើកទី...៣... ថ្ងៃ...សុក្រ...៧...កើត...
ខែ...ផល្គុន... ឆ្នាំ រកា នព្វស័ក ព.ស ២៥៦១ ត្រូវនឹង ថ្ងៃទី...២៣... ខែ...មីនា... ឆ្នាំ ២០១៨



ផែនទី ឃុំស្វាយទាប
ឃុំចំការអណ្ដូង
ស្រោងចាន់
ស្វាយទាប
សញ្ញាសំគាល់
សាលាស្រុក
សាលាឃុំ
ភូមិ
មណ្ឌលសុខភាព
មន្ទីរពេទ្យ
វត្ត
សាលារៀន
ព្រំប្រទល់ខេត្ត
ព្រំប្រទល់ស្រុក
ព្រំប្រទល់ឃុំ
ផ្លូវ ចាក់កៅស៊ូ
ផ្លូវ គ្រួសក្រហម ឬ ក្រាលថ្ម
ផ្លូវជីស ឬ ផ្លូវលំ
ផ្លូវរទេះ ឬ ផ្លូវដើរ
ស្ទឹង/អូរមានទឹកជាប្រចាំ
ស្ទឹង/អូរមានទឹកនៅរដូវវស្សា
ប្រឡាយ
ប្រឡាយ មេ
ទំនប់
ដីលំនៅដ្ឋាន
កសិកម្ម
វាលស្មៅ វាលស្បូវ
តំបន់ប្រជុំជន
តំបន់ភូមិ
Kilometers
0
1
2
UTM (Universal Transvers Mecator)
48
(Reference Datum) GWS1984
Everest
ខេត្តកំពង់ធំ
ឃុំបឹងណាយ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

---

## កំណត់ហេតុ
## ស្តីពីការអនុម័តសៀវភៅផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ

ពុទ្ធសករាជ ពីរពាន់ប្រាំរយហុកសិបប្រាំមួយ ឆ្នាំរកា នព្វស័ក ខែ ចេត្រ ប្រាំពីរកើត ថ្ងៃ សុក្រ ត្រូវនឹង ឆ្នាំពីរពាន់ដប់ប្រាំបី ខែ មីនា ថ្ងៃទី ម្ភៃបី វេលាម៉ោង ប្រាំពីរ និងសាមសិបនាទីព្រឹក នៅសាលាឃុំស្វាយទាប បានបើកកិច្ចប្រជុំ ស្តីពីការពិនិត្យ និងអនុម័តសៀវភៅផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ ក្រោមអធិបតីភាព លោក **តឹង យ៉ាត** ប្រធានក្រុមប្រឹក្សាឃុំ ។

I . <u>សមាសភាពចូលរួម</u>

| | | | |
|---|---|---|---|
| ១- លោក | តឹម | ប៊ុនឡុង | ជំទប់ទី១ |
| ២- លោកស្រី | ទេព | ដាទី | ជំទប់ទី២ |
| ៣- លោក | ស្វាន់ | ប៊ុនជា | សមាជិកក្រុមប្រឹក្សាឃុំ |
| ៤- លោក | ឃិន | យ៉ុន | សមាជិកក្រុមប្រឹក្សាឃុំ |
| ៥- លោក | តឹក | ឡេង | សមាជិកក្រុមប្រឹក្សាឃុំ |
| ៦- លោកស្រី | ជិន | ប៉ាប | សមាជិកក្រុមប្រឹក្សាឃុំ |
| ៧- លោកស្រី | សយ | ណារឿន | សមាជិកក្រុមប្រឹក្សាឃុំ |
| ៨- លោក | ស៊ិន | វ៉ានី | សមាជិកក្រុមប្រឹក្សាឃុំ |
| ៩- លោក | លី | សុខលាង | សមាជិកក្រុមប្រឹក្សាឃុំ |
| ១០-លោក | ងិន | ចាន់ | សមាជិកក្រុមប្រឹក្សាឃុំ |

បញ្ជីវត្តមានជូនភ្ជាប់

II. <u>របៀបវារៈនៃអង្គប្រជុំ</u>

១- មតិស្វាគមន៍បើកអង្គប្រជុំរបស់ប្រធាន

២- ពិនិត្យកូរ៉ុម

៣- ពិនិត្យ និងអនុម័ត្យសេចក្តីព្រាងសៀវភៅផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ

៤- ផ្សេងៗ

III .<u>ដំណើរការប្រជុំ</u>

របៀបវារៈទី១ , លោក តឹង យ៉ាត ប្រធានអង្គប្រជុំ បានជម្រាបជូនសមាជិក សមាជិកានៃអង្គប្រជុំនូវរបៀបវារៈ ក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ អាណត្តិទី៤ ។

របៀវារៈទី២ , កូរ៉ុមប្រជុំ មានចំនួន ១១/១១ គ្រប់កូរ៉ុម អង្គប្រជុំដំណើរការបាន ។

របៀបវារៈទី៣, ពិនិត្យ និងអនុម័តសេចក្តីព្រាងសៀវភៅផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ

ដោយបានការអនុញ្ញាតពីលោកប្រធានអង្គប្រជុំ ស្មៀនឃុំ បានអានសេចក្តីព្រាងសៀវភៅផែនការអភិវឌ្ឍន៍ប្រាំឆ្នាំ ដែលមានបួន ជំពូក ក្នុងនោះ ជំពូកទី១ បរិយាយអំពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច ,ជំពូកទី២ បរិយាយអំពីក្របខ័ណ្ឌអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ ,ជំពូកទី៣ បរិយាយអំពីកម្មវិធីអភិវឌ្ឍន៍ មូលដ្ឋានរយៈពេល ប្រាំឆ្នាំ និងជំពូកទី៤ បរិយាយអំពីការតាមដាន និងវាយតម្លៃនៃការអនុវត្តផែនការអភិវឌ្ឍន៍ ។

តារាង ២.៥ ៖ តារាងក្របខ័ណ្ឌតាមដាន និងវាយតម្លៃការអនុវត្តក្របខ័ណ្ឌអភិវឌ្ឍន៍

| គោលបំណង និងគោលដៅ | សូចនាករ | | | | អ្នកទទួលបន្ទុក | ប្រភពព័ត៌មាន | វិធីសាស្ត្រ |
|---|---|---|---|---|---|---|---|
| | ការបរិយាយ | ឯកតា | គ្រោង | ជាក់ស្តែង | | | |
| **១.ផ្នែកសេដ្ឋកិច្ច** | | | | | | | |
| **១.១.គោលបំណង៖** ក្នុងរយៈនៅក្នុងរយៈពេល ប្រាំឆ្នាំ (២០១៧-២០២២) របស់ ក្រុមប្រឹក្សាឃុំស្វាយទាប អាណត្តិទី៤នេះ ឃុំធ្វើឲ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធនានាដូចជា៖ ការកែលម្អផ្លូវលំជនបទនានា អោយមានភាពប្រសើរឡើង ទូទាំងឃុំ ស្ពាន ប្រព័ន្ធ ធារាសាស្ត្រ ទំនប់ ប្រឡាយ អាងស្តុកទឹក ការបង្កើនការដាំដុះ ការផលិតនិងការរកទីផ្សារលក់ផលិតផល ការតភ្ជាប់បណ្តាញអគ្គីសនីតាមបណ្តាភូមិទាំង ក្នុងឃុំ សម្រាប់ ប្រជាពលរដ្ឋប្រើប្រាស់ និងប្រកបអាជីវកម្មនានាដើម្បីបង្កើនសេដ្ឋកិច្ចក្នុងគ្រួសារ ។ | | | | | | | |
| **១.១.១.គោលដៅ៖** នៅឆ្នាំ២០២២ ប្រជាពលរដ្ឋ ៩០%មានផ្លូវល្អសម្រាប់ប្រើប្រាស់ | ផ្លូវបេតុង | គ.ម | ៥ | | | | |
| | ផ្លូវគ្រួសក្រហម | គ.ម | ២៣ | | | | |
| | ផ្លូវដីស | គ.ម | ១០ | | | | |
| | ផ្លូវក្រាលកៅស៊ូ | គ.ម | ៦ | | | | |
| | ប្រឡាយអមសងខាងផ្លូវ | គ.ម | ៦ | | | | |
| | លូកាត់ផ្លូវ | កន្លែង | ២០ | | | | |
| **១.១.២.គោលដៅ៖** នៅឆ្នាំ២០២២ ប្រជាពលរដ្ឋមានប្រព័ន្ធស្រោចស្រពផលដំណាំបាន ៨០% | ប្រឡាយស្រោចស្រព | ម | ៧,៥ | | | | |
| | ទំនប់ទឹក | កន្លែង | ១ | | | | |
| **១.១.៣.គោលដៅ៖** នៅឆ្នាំ២០២២ ប្រជាពលរដ្ឋចំនួន៨០ %នឹងចេះពីបច្ចេកទេសក្នុងការដាំដំណាំ | ស្រែបង្ហាញដំណាំស្រូវ | វគ្គ | ៥ | | | | |
| | កែប្រែគុណភាពដី | វគ្គ | ៥ | | | | |
| | ដីកំប៉ុស្តិ៍ | វគ្គ | ១៥ | | | | |
| | ប្រើប្រាស់ជីគីមី និងថ្នាំពុល | វគ្គ | ១៥ | | | | |
| | បច្ចេកទេសដំណាំបន្លែ | វគ្គ | ២០ | | | | |
| **១.១.៤.គោលដៅ៖** នៅឆ្នាំ២០២២ ប្រជាពលរដ្ឋចំនួន ៨០% មានបច្ចេកទេសចញ្ចឹម និងថែទាំសត្វ | ចាក់សាំងសត្វ | ក្បាល | ១,០០០ | | | | |
| | ភ្នាក់ងារសុខភាពសត្វភូមិ | វគ្គ | ៥ | | | | |
| | បច្ចេកទេសចិញ្ចឹមសត្វ | វគ្គ | ១០ | | | | |
| | អណ្តូងទឹក | អណ្តូង | ២០ | | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១.១.៥.គោលដៅ៖ នៅឆ្នាំ២០២២ ប្រជាពលរដ្ឋចំនួន ៨០% មានបណ្ដាញទឹកស្អាតប្រើប្រាស់ | ទឹកគ្មានជាតិអាសេនិច | ដង | ៥ | | | | |
| | បណ្ដាយទឹកស្អាត | ភូមិ | ១៤ | | | | |

**២.ផែ្នកសង្គមកិច្ច**

២.១.គោលបំណង៖ យៈពេលប្រាំឆ្នាំ(២០១៧-២០២២) ក្នុងអាណត្តិទី៤របស់ក្រុមប្រឹក្សាឃុំ ប្រជាពលរដ្ឋទទួលបាននូវសេវា សង្គមនានា ដូចជា ៖ ចំណេះដឹងមូលដ្ឋានក្នុងការលើកកម្ពស់សុខភាពមាតា និងទារក ការកាត់បន្ថយ អត្រា អនក្ខរភាព ពង្រីកសាលារៀនឆ្លងកាត់ ប្រជាពលរដ្ឋយល់ដឹងពីសារសំខាន់នៃកាសិក្សារបស់កូន ជម្រុញការលើក កម្ពស់សមភាពយេនឌ័រ ទប់ស្កាត់បានអំពើហិង្សាក្នុងគ្រួសារ ទទួលបានសុវត្ថិភាពក្នុងការធ្វើចំណាកស្រុក ការ រំលោភបំពានលើកម្លាំងពលកម្មកុមារត្រូវបានកាត់បន្ថយ ។ បង្កើនការយល់ដឹងពីសុខភាពអនាម័យ នៅតាម សហគមន៍ ជនបទ ។

| | | | | | | | |
|---|---|---|---|---|---|---|---|
| ២.១.១.គោលដៅ៖ នៅឆ្នាំ២០២២ កុមារចំនួន៩០% បានចូលរៀន និងមានការអប់រំតាមផ្ទះ | សាងសង់អគារសិក្សា | ខ្នង | ៥ | | | | |
| | កុមារបានចូលរៀន | លើក | ២០ | | | | |
| | អប់រំកុមារតូចតាមផ្ទះ | វគ្គ | ២៥ | | | | |
| | អាហារូបករណ៍សិស្សក្រីក្រ | នាក់ | ១០០ | | | | |
| | គណៈកម្មការទ្រទ្រង់សាលា | ប្រជុំ | ១៥ | | | | |
| ២.១.២.គោលដៅ៖ នៅ ឆ្នាំ២០២២ប្រជាពលរដ្ឋ ៨០% យល់ដឹងពីសារៈសំខាន់នៃការពិនិត្យសុខភាព នៅមណ្ឌលសុខភាព | ផ្សព្វផ្សាយពីការទទួលសេវានៅមណ្ឌលសុខភាព | លើក | ២០ | | | | |
| | ជម្រុញការពិនិត្យផ្ទៃពោះមុននិងក្រោយសម្រាល | លើក | ២០ | | | | |
| | មានការគាំពារ | នាក់ | ២៥០ | | | | |
| | សុខភាពផ្លូវចិត្ត | លើក | ១៥ | | | | |
| | ការព្យាបាលជំងឺអេដស៍ | នាក់ | ១០ | | | | |
| | វ៉ាក់សាំង ស្ត្រីនិង កុមារ | លើក | ២០ | | | | |
| ២.១.៣.គោលដៅ៖ នៅឆ្នាំ២០២២កុមារកំព្រាក្រីក្រ និងអ្នកជំងឺអេដស៍មានការគាំទ្រពីអង្គការដៃគូ | កុមារកំព្រា | នាក់ | ២៥ | | | | |
| | អ្នកផ្ទុកជំងឺអេដស៍ | នាក់ | ១០ | | | | |
| | កុមារក្រីក្រ | នាក់ | ៥០ | | | | |

– ប្រកាសស្ដីពីការទទួលស្គាល់សមាសភាពប្រធានក្រុមប្រឹក្សាឃុំ មេឃុំ ជំទប់ និងសមាជិកក្រុមប្រឹក្សាឃុំ នៃឃុំស្វាយទាប ស្រុកចំការលើ ខេត្តកំពង់ចាម, *លេខ ៧៦០៥ ប្រក, ចុះនៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ ២០១៧។*



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ: ៧៦០៥ ប្រក

**ប្រកាស**
**ស្ដីពីការទទួលស្គាល់សមាសភាពប្រធានក្រុមប្រឹក្សាឃុំ មេឃុំ ជំទប់**
**និងសមាជិកក្រុមប្រឹក្សាឃុំ នៃឃុំស្វាយទាប ស្រុកចំការលើ ខេត្តកំពង់ចាម**

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៥ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៧/០១២ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ១៨១ អនក្រ.បក ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៦ ស្ដីពីការកំណត់ចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៤
- យោងលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នៅឃុំស្វាយទាប លេខកូដ ០៣-០១៨ នៃខេត្តកំពង់ចាម(ទម្រង់បែបបទ១១១៨)របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៧
- យោងសេចក្ដីសម្រេចលេខ ៧២៥ គ.ជ.ប.ស.ស.រ ចុះថ្ងៃអង្គារ ៩ រោច ខែមិគសិរ ឆ្នាំរកា ព.ស ២៥៦១ ត្រូវនឹងថ្ងៃទី១២ ខែធ្នូ គ.ស ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ស្ដីពីបញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ និងបេក្ខជនជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ បន្ទាប់ពីការបែងចែកអាសនៈដែលនៅទំនេរអនុលោមតាមមាត្រា២០ថ្មី និងមាត្រា២១ថ្មី នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

# សម្រេច

**ប្រការ ១.-**

ទទួលស្គាល់សមាសភាពជាប្រធានក្រុមប្រឹក្សាឃុំ និងសមាជិកក្រុមប្រឹក្សាឃុំស្វាយទាប ស្រុកចំការលើ ខេត្តកំពង់ចាម ផ្អែកលើលទ្ធផល នៃការបែងចែកអាសនៈដែលនៅទំនេររបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដូចមានរាយនាមខាងក្រោម ៖

| | | | |
|---|---|---|---|
| ១- | លោក | គឹង យ៉ាត | ជាប្រធានក្រុមប្រឹក្សាឃុំ |
| ២- | លោក | គឹម ប៊ុនឡុង | ជាសមាជិកក្រុមប្រឹក្សាឃុំ |
| ៣- | លោកស្រី | ទេព ដាទី | ជាសមាជិកក្រុមប្រឹក្សាឃុំ |
| ៤- | លោក | ស្វាន់ ប៊ុនប៉ា | ជាសមាជិកក្រុមប្រឹក្សាឃុំ |
| ៥- | លោកស្រី | សយ ណារឿន | ជាសមាជិកក្រុមប្រឹក្សាឃុំ |
| ៦- | លោក | លី សុខលាង | ជាសមាជិកក្រុមប្រឹក្សាឃុំ |
| ៧- | លោក | ស៊ិន វ៉ាន់នី | ជាសមាជិកក្រុមប្រឹក្សាឃុំ |
| ៨- | លោក | តឹក ឡេង | ជាសមាជិកក្រុមប្រឹក្សាឃុំ |
| ៩- | លោក | យិន យ៉ុន | ជាសមាជិកក្រុមប្រឹក្សាឃុំ |
| ១០- | លោក | ងិន ចាន់ | ជាសមាជិកក្រុមប្រឹក្សាឃុំ |
| ១១- | លោកស្រី | ជិន ហ៊ាប | ជាសមាជិកក្រុមប្រឹក្សាឃុំ។ |

**ប្រការ ២.-**

ទទួលស្គាល់សមាសភាពជាមេឃុំ ជំទប់ទី១ និងជំទប់ទី២ នៃឃុំស្វាយទាប ស្រុកចំការលើ ខេត្តកំពង់ចាម ដូចមានរាយនាមខាងក្រោម ៖

| | | | |
|---|---|---|---|
| ១- | លោក | គឹង យ៉ាត | ជាមេឃុំ |
| ២- | លោក | គឹម ប៊ុនឡុង | ជាជំទប់ទី១ |
| ៣- | លោកស្រី | ទេព ដាទី | ជាជំទប់ទី២។ |

**ប្រការ ៣.-**

ការអនុវត្តការងារ ប្រធានក្រុមប្រឹក្សាឃុំ សមាជិកក្រុមប្រឹក្សាឃុំ មេឃុំ ជំទប់ទី១ និងជំទប់ទី២ នៃឃុំស្វាយទាប ត្រូវអនុវត្តតាមរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋាននានាជាធរមាន។

**ប្រការ ៤.-**

ប្រកាសរបស់ក្រសួងមហាផ្ទៃលេខ ២៧៣០ ប្រក ចុះថ្ងៃ២៧ ខែមិថុនា ឆ្នាំ២០១៧ ស្តីពីការទទួលស្គាល់សមាសភាពសមាជិកក្រុមប្រឹក្សាឃុំ ប្រធានក្រុមប្រឹក្សាឃុំ នៃឃុំស្វាយទាប ស្រុកចំការលើ ខេត្តកំពង់ចាម ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៥.-**

ប្រកាសនេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ៣កើត ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស.២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែ វិច្ឆិកា ឆ្នាំ២០១៧

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្តេចក្រឡាហោម ស ខេង

**កន្លែងទទួល**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- អគ្គលេខាធិការ...
- អគ្គ...
- អង្គភាពប្រឆាំងអំពើពុករលួយ
  ដើម្បីជូនជ្រាប
- សាលាខេត្ត ស្រុក
  ដូចក្នុងប្រការ៤
  ដើម្បីអនុវត្ត
- កាលប្បវត្តិ
- ឯកសារ-កាលប្បវត្តិ

ចំលងត្រឹមត្រូវតាមច្បាប់ដើម

លេខ ...៤៥៨....ចល.កប

កំពង់ចាម ថ្ងៃទី...២៥..ខែ..វិច្ឆិកា...ឆ្នាំ២០១៧

ជ.អភិបាលខេត្ត

អភិបាលរងរដ្ឋបាល

ម៉ុន-ដារ៉ា

# ឧបសម្ព័ន្ធទី៣

## របាយការណ៍

– របាយការណ៍ស្តីពីសមិទ្ធផលការងាររបស់ក្រុមប្រឹក្សាឃុំស្វាយទាបអាណត្តិទី៤ ខែមករា ឆ្នាំ ២០២២។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្តកំពង់ចាម
ស្រុកចំការលើ
រដ្ឋបាលឃុំស្វាយទាប
លេខ ១៣៥/២២

# របាយការណ៍ស្តីពីសមិទ្ធផលការងារ
# របស់ក្រុមប្រឹក្សាឃុំស្វាយទាប
# អាណត្តិទី៤

*ខែមករា ឆ្នាំ២០២២*

# ផ្នែកទី១

## សមិទ្ធផលការងារ

### ១.១. ស្ថិតិប្រជាពលរដ្ឋ (ព័ត៌មានលម្អិតមាននៅក្នុងតារាងឧបសម្ព័ន្ធទី១)

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| 1 | 2 | 3 |
| ១ | គ្រួសារសរុប | 5,508 |
| ២ | គ្រួសារអចិន្ត្រៃយ៍ | 5,491 |
| ៣ | គ្រួសារបណ្ដោះអាសន្ន | 17 |
| ៤ | ប្រជាពលរដ្ឋសរុប | 23,163 |
| ៥ | ប្រជាពលរដ្ឋជាស្ត្រី | **11,**860 |
| ៦ | ប្រជាពលរដ្ឋដែលមានអាយុ១៨ឆ្នាំឡើង | 15,089 |
| ៧ | ប្រជាពលរដ្ឋចំណាកស្រុក | 53 |

**សេចក្ដីពន្យល់ ៖**

- កូឡោនទី២ ត្រូវរក្សាព័ត៌មានតាមទម្រង់ទាំងស្រុង មិនត្រូវបន្ថែម ឬបន្ថយឡើយ។
- កូឡោនទី៣ ត្រូវស្រង់ចេញពីស្ថិតិប្រជាពលរដ្ឋ ក្នុងតារាងឧបសម្ព័ន្ធទី១ ដែលមានភ្ជាប់មកជាមួយក្នុងរបាយការណ៍នេះ។

### ១.២. ស្ថិតិក្រុមប្រឹក្សា និងបុគ្គលិក

| លរ | ការបរិយាយ | សរុប | ស្រី |
|---|---|---|---|
| 1 | 2 | 3 | 4 |
| ១ | សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ | 11 | 03 |
| ២ | សមាជិកក្រុមប្រឹក្សាដែលបានផ្លាស់ប្តូរក្នុងរយៈពេល៥ឆ្នាំ | 1 | 0 |
| ៣ | មេឃុំ ចៅសង្កាត់ | 1 | 0 |
| ៤ | ជំទប់ទី១ ចៅសង្កាត់រងទី១ | 1 | 0 |
| ៥ | ជំទប់ទី២ ចៅសង្កាត់រងទី២ | 1 | 1 |
| ៦ | ស្មៀនឃុំ សង្កាត់ | 1 | 0 |
| ៧ | បុគ្គលិកកិច្ចសន្យា | **2** | 0 |
| ៨ | មេភូមិ | 14 | 1 |
| ៩ | អនុប្រធានភូមិ | 14 | **1** |
| ១០ | សមាជិកភូមិ | 14 | 14 |
| ១១ | អ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារដែលមិនមែនជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ | 0 | 0 |
| ១២ | ជនបង្គោលតាមដានត្រួតពិនិត្យ និងវាយតម្លៃឃុំ សង្កាត់ | 2 | 1 |

**សេចក្តីពន្យល់ ៖**

- កូឡោនទី២ ត្រូវរក្សាព័ត៌មានតាមទម្រង់ទាំងស្រុង មិនត្រូវបន្ថែម ឬបន្ថយឡើយ។
- កូឡោនទី៣ ជាចំនួនសរុបជាក់ស្តែងនៃសមាសភាពនីមួយៗ។
- កូឡោនទី៤ ជាចំនួនស្ត្រីជាក់ស្តែងនៃសមាសភាពនីមួយៗ។

### ១.៣. ដីកា សេចក្តីសម្រេច និងលិខិតរដ្ឋបាល

| ល.រ | ការបរិយាយ | ចំនួន | | | | | |
|---|---|---|---|---|---|---|---|
| | | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | សរុប |
| 1 | 2 | 3 | 4 | 5 | 6 | 7 | 8 |
| ១ | ដីកាដែលបានដាក់ចេញ | 2 | 0 | 0 | 0 | 0 | 2 |
| ២ | សេចក្តីសម្រេចដែលបានដាក់ចេញ | 8 | 21 | 17 | 18 | 16 | 80 |
| ៣ | លិខិតរដ្ឋបាលដែលបានដាក់ចេញ | 1,523 | 1,689 | 1,893 | 2,129 | 2,290 | 9,524 |
| ៤ | លិខិតដែលបានទទួល | 171 | 145 | 83 | 79 | 84 | 562 |

**សេចក្តីពន្យល់ ៖**

- កូឡោនទី២ ត្រូវរក្សាព័ត៌មានតាមទម្រង់ទាំងស្រុង មិនត្រូវបន្ថែម ឬបន្ថយឡើយ។
- កូឡោនទី៣ ទី៤ ទី៥ ទី៦ និងទី៧ ស្រង់ចេញពីកូឡោនទី៣ នៃតារាងក្នុងចំណុច១.១.៣ នៃរបាយការណ៍ប្រចាំឆ្នាំរបស់រដ្ឋបាលឃុំ សង្កាត់ពីឆ្នាំ២០១៧ ដល់ឆ្នាំ២០២១។
- កូឡោនទី៨ ជាផលបូកនៃកូឡោនទី៣ ទី៤ ទី៥ ទី៦ និងទី៧។

### ១.៤. កិច្ចប្រជុំក្រុមប្រឹក្សា និងគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ(គ.ក.ន.ក.)

| ល.រ | ការបរិយាយ | ចំនួន | | | | | |
|---|---|---|---|---|---|---|---|
| | | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | សរុប |
| 1 | 2 | 3 | 4 | 5 | 6 | 7 | 8 |
| ១ | កិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សា | 12 | 12 | 12 | 12 | 12 | 60 |
| ២ | កិច្ចប្រជុំវិសាមញ្ញរបស់ក្រុមប្រឹក្សា | 11 | 13 | 7 | 13 | 16 | 60 |
| ៣ | កិច្ចប្រជុំសម្ងាត់របស់ក្រុមប្រឹក្សា | 0 | 0 | 0 | 0 | 0 | 0 |
| ៤ | កិច្ចប្រជុំ គ.ក.ន.ក. | 12 | 12 | 12 | 12 | 12 | 60 |

**សេចក្តីពន្យល់ ៖**

- កូឡោនទី២ ត្រូវរក្សាព័ត៌មានតាមទម្រង់ទាំងស្រុង មិនត្រូវបន្ថែម ឬបន្ថយឡើយ។
- កូឡោនទី៣ ទី៤ ទី៥ ទី៦ និងទី៧ ស្រង់ចេញពីកូឡោនទី៣នៃតារាងក្នុងចំណុច១.១.៤ នៃរបាយការណ៍ប្រចាំឆ្នាំរបស់រដ្ឋបាលឃុំ សង្កាត់ពីឆ្នាំ២០១៧ ដល់ឆ្នាំ២០២១។
- កូឡោនទី៨ ជាផលបូកនៃកូឡោនទី៣ ទី៤ ទី៥ ទី៦ និងទី៧។

## ១.៥. គម្រោងវិនិយោគដែលមានការសន្យាគាំទ្រដោយថវិកាឃុំ សង្កាត់

| ល.រ | ការបរិយាយ | ២០១៧ | | ២០១៨ | | ២០១៩ | | ២០២០ | | ២០២១ | | សរុប | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ចំនួន | តម្លៃ | ចំនួន | តម្លៃ | ចំនួន | តម្លៃ | ចំនួន | តម្លៃ | ចំនួន | តម្លៃ | ចំនួន | តម្លៃ |
| 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 13 | 14 |
| ១ | សេដ្ឋកិច្ច | 1 | 51755000 | 1 | 115653386 | 2 | 175550100 | 1 | 259825000 | 2 | 371350000 | 7 | 974,133,486 |
| ២ | សង្គមកិច្ច | 5 | 10300000 | 3 | 11380000 | 3 | 9600000 | 3 | 23600000 | 0 | | 14 | 54,880,000 |
| ៣ | ធនធានធម្មជាតិ និងបរិស្ថាន | 1 | 4000000 | 1 | 4200000 | 1 | 6000000 | 1 | 6000000 | 0 | | 4 | 20,200,000 |
| ៤ | សេវារដ្ឋបាល និង សន្តិសុខ | 0 | | 0 | | 0 | 0 | 0 | | 0 | | 0 | |
| សរុប | | 7 | 66055000 | 5 | 131233386 | 6 | 191150100 | 5 | 289425000 | 2 | 371425000 | 25 | 1,029,213,486 |

**សេចក្តីពន្យល់ ៖**

- កូឡោនទី២ ត្រូវរក្សាព័ត៌មានតាមទម្រង់ទាំងស្រុង មិនត្រូវបន្ថែម ឬបន្ថយឡើយ។
- កូឡោនទី៣ ទី៥ ទី៧ ទី៩ និងទី១១ ស្រង់ចេញពីកូឡោនទី៣ នៃតារាងក្នុងចំណុច១.២.១ នៃរបាយការណ៍ប្រចាំឆ្នាំរបស់រដ្ឋបាលឃុំ សង្កាត់ពីឆ្នាំ២០១៧ ដល់ឆ្នាំ២០២១។
- កូឡោនទី៤ ទី៦ ទី៨ ទី១០ និងទី១២ ស្រង់ចេញពីកូឡោនទី៤ នៃតារាងក្នុងចំណុច១.២.១ នៃរបាយការណ៍ប្រចាំឆ្នាំរបស់រដ្ឋបាលឃុំ សង្កាត់ពីឆ្នាំ២០១៧ ដល់ឆ្នាំ២០២១។
- កូឡោនទី១៣ ជាផលបូកនៃកូឡោនទី៣ ទី៥ ទី៧ ទី៩ និងទី១១។
- កូឡោនទី១៤ ជាផលបូកនៃកូឡោនទី៤ ទី៦ ទី៨ ទី១០ និងទី១២។

## ១.៦. គម្រោងវិនិយោគដែលបានអនុវត្តជាក់ស្តែង( ព័ត៌មានលម្អិតមាននៅក្នុងតារាងឧបសម្ព័ន្ធទី២ )

| ល.រ | ការបរិយាយ | ២០១៧ | | ២០១៨ | | ២០១៩ | | ២០២០ | | ២០២១ | | សរុប | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ចំនួន | តម្លៃ | ចំនួន | តម្លៃ | ចំនួន | តម្លៃ | ចំនួន | តម្លៃ | ចំនួន | តម្លៃ | ចំនួន | តម្លៃ |
| 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 13 | 14 |
| ១ | សេដ្ឋកិច្ច | 1 | 41755000 | 1 | 105653386 | 2 | 175550100 | 1 | 259825000 | 2 | 371350000 | 7 | 954,133,486 |
| ២ | សង្គមកិច្ច | 5 | 10300000 | 3 | 11380000 | 3 | 9600000 | 3 | 23600000 | 0 | | 14 | 54,880,000 |
| ៣ | ធនធានធម្មជាតិ និងបរិស្ថាន | 1 | 4000000 | 1 | 4200000 | 1 | 6000000 | 1 | 6000000 | 0 | | 4 | 20,200,000 |
| ៤ | សេវារដ្ឋបាល និង សន្តិសុខ | 0 | | 0 | | 0 | 0 | 0 | | 0 | | 0 | |
| សរុប | | 7 | 56055000 | 5 | 121233386 | 6 | 191150100 | 5 | 289425000 | 2 | 371425000 | 25 | 1,029,213,486 |

# ឧបសម្ព័ន្ធទី៤

## រូបភាព

- សាលាឃុំ ស្វាយទាប




សាលាឃុំ ស្វាយទាប
យន្តការច្រកចេញចូលតែមួយ
ONE WINDOW SERVICE MECHANISM
OPPO Reno7